**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការដោះស្រាយវិវាទដីធ្លីនៅកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ធឿន ឆាវ៉ា**

**សៀង សុវណ្ណមុនីនាថ**

សាស្ត្រាចារ្យណែនាំ

**ភង ស៊ីផាន់ណាវ៉ា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២២

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា២០២២

# អារម្ភកថា

ប្រទេសកម្ពុជាយើង គឺជាប្រទេសមួយក្នុងចំណោមប្រទេសដទៃទៀតដែលធ្លាប់មានសង្គ្រាមកើតឡើង ដែលនាំឱ្យមនុស្សស្លាប់រាប់លាននាក់ បាត់បង់សេដ្ឋកិច្ចនិងខូចខាតហេដ្ឋារចនាសម្ព័ន្ធស្ទើរតែទាំងអស់។ ក្រោយមកមានការដឹកនាំដោយសម្តេចនាយករដ្ឋមន្ត្រី ដែលមានយុត្តិសាស្រ្ត បញ្ញាញាណឈ្លាសវៃ និងពោរពេញដោយទេពកោសល្យ បានរំដោះប្រទេសឱ្យរួចផុតពីសង្គ្រាម នឹងស្តារប្រទេសជាតិឡើងវិញ ហើយបង្កើតឱ្យមាននូវលក្ខណៈសម្បូរបែបលើគ្រប់វិស័យទាំងអស់ ដែលធ្វើឱ្យប្រទេសកម្ពុជាយើងរស់នៅបានដោយសុខសន្តិភាពរហូតដល់សព្វថ្ងៃ។ ក្រោយពីប្រទេសជាតិមានសន្តិភាពហើយ យើងសង្កេតឃើញថាវិស័យអចលនទ្រព្យបានរីកដុះដាលយ៉ាងខ្លាំងនៅក្នុងប្រទេសកម្ពុជាយើង។ ហេតុនេះហើយទើបយើងខ្ញុំបានសម្រេចចិត្តជ្រើសរើសយកប្រធានបទ " ការដោះស្រាយវិវាទដីធ្លីនៅកម្ពុជា" មកសរសេរជាសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររបស់យើងខ្ញុំ គឺដើម្បីរួមចំណែកជាឯកសារសម្រាប់ការស្រាវជ្រាវ ដល់អ្នកសិក្សាទាំងឡាយដែលចង់ស្វែងយល់ពីបញ្ហាដីធ្លីនេះ រួមទាំងយើងខ្ញុំផ្ទាល់ក៏ចង់យល់ដឹងពីបញ្ហានេះដូចគ្នា។

សារណាបញ្ចប់ការសិក្សានេះនិយាយពី " ការដោះស្រាយវិវាទដីធ្លីនៅកម្ពុជា " បានពន្យល់បកស្រាយ និងវែកញែកពីបញ្ហាវិវាទដីធ្លី និងយន្តការក្នុងការដោះស្រាយ ជាមួយស្ថាប័នដែលមានសមត្ថកិច្ចក្នុងការដោះស្រាយវិវាទដីធ្លីនៅក្នុងប្រទេសកម្ពុជា។ ម្យ៉ាងវិញទៀត នេះក៏ជាការរួមចំណែកមួយក្នុងការជួយកាត់បន្ថយបញ្ហាវិវាទដីធ្លីនៅកម្ពុជា និងយន្តការយ៉ាងល្អប្រសើរក្នុងការឈានទៅរកការលុបបំបាត់នូវវិវាទដីធ្លីក្នុងព្រះរាជាណាចក្រកម្ពុជានាពេលអនាគត។

សារណាបញ្ចប់ការសិក្សាខាងលើនេះ ពិតជាមានចំណុចខ្វះខាត និងកំហុសឆ្គងពាក្យពេចន៍ អក្ខរាវិរុទ្ធ អត្ថន័យ ជាក់ជាមិនខាន។ យើងខ្ញុំសង្ឃឹមថារបាយការណ៍នេះនឹងមានជាប្រយោជន៍ដល់ការសិក្សាស្រាវជ្រាវរបស់សិស្សនិស្សិត និងមិត្តអ្នកសិក្សាទាំងឡាយដែលចង់យល់ដឹងពីបញ្ហាដីធ្លីនេះ។ ហើយយើងខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយ និងស្វាគមន៍នូវរាល់មតិរិះគន់ កែលំអក្នុងន័យស្ថាបនាពីសំណាក់សាស្ត្រាចារ្យមិត្តនិស្សិតអ្នកអាន អ្នកសិក្សាស្រាវជ្រាវ ដែលបានអានរបាយការណ៍នេះ ដើម្បីធ្វើការកែលំអ និងញ៉ាំងឱ្យរបាយការណ៍នេះកាន់តែមានអត្ថន័យល្អប្រសើរ។

សូមអរគុណ!

# សេចក្តីថ្លែងអំណរគុណ

ក្នុងនាមយើងខ្ញុំ ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ជំនាន់ទី២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ យើងខ្ញុំសូមធ្វើការថ្លែង អំណរគុណ និងសូមសម្តែងនូវការដឹងគុណ កត្តញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុតជូនចំពោះអ្នកមានគុណដូចជា៖

- លោកឪពុក និងអ្នកម្តាយ ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សាកូន តាំងពីចាប់កំណើតរហូតដល់ធំពេញវ័យ ដោយមិនខ្លាចនឿយហត់ និងពុំមានត្អូញត្អែរពីទុក្ខលំបាក ដែលលោកទាំងពីរបានធ្វើដើម្បីកូនឡើយ។គុណលោកទាំងពីរមិនអាចកាត់ថ្លៃបានឡើយ។លោកទាំងពីរបានលះបង់ច្រើនឥតគណនាទាំងកំលាំងកាយ កំលាំងចិត្ត ពេលវេលាដ៏ថ្លៃថ្លា ធនធាន និងដំបូន្មានល្អៗ ក្នុងការប្រៀនប្រដៅកូនដើម្បីឱ្យកូនក្លាយជាពលរដ្ឋល្អក្នុងសង្គម ជំរុញលើកទឹកចិត្តឱ្យកូនស្រលាញ់ការសិក្សា ឧស្សាហ៍ព្យាយាម និងតស៊ូក្នុងជីវិត។
- ឯកឧត្តមបណ្ឌិត **លុយ ចណ្ណា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានអនុញ្ញាតឱ្យយើងខ្ញុំបានចូលរៀន និងថ្នាក់ដឹកនាំ ព្រមទាំងបុគ្គលិក សាកលវិទ្យាល័យទាំងអស់ដែលតែងតែជួយសម្រួលគ្រប់កិច្ចការរដ្ឋបាលក្នុងរយៈពេលកន្លងមកនេះ ។
- លោកសាស្ត្រាចារ្យ **គង់ ស៊ីផាន់ណារ៉ា** ដែលជាសាស្ត្រាចារ្យណែនាំសារណា លោកបានចំណាយពេលដ៏មានតម្លៃក្នុងការពន្យល់ណែនាំ ផ្តល់ជាយោបល់ រួមទាំងបទពិសោធន៍ល្អៗ និងកែសម្រួលនូវការធ្វើសារណាបញ្ចប់ការសិក្សានេះ រហូតបានសម្រេចជារូបរាងឡើងដោយរលូន។

ជាទីបញ្ចប់នេះ យើងខ្ញុំសូមគោរពជូនពរដល់ លោកអ្នកមានគុណ សាកលវិទ្យាធិការ និងសាស្ត្រាចារ្យ ទាំងអស់ សូមឱ្យជួបតែសេចក្តីសុខ សុខភាពល្អ សុភមង្គល និងជោគជ័យគ្រប់ភារកិច្ច។

# អំណះអំណាង

ក្រុមយើងខ្ញុំសូមធានា និងទទួលខុសត្រូវទាំងស្រុងថា ខ្លឹមសារនៃនិក្ខេបបទនេះ គឺជាស្នាដៃដែលបានស្រាវជ្រាវផ្ទាល់របស់ក្រុមយើងខ្ញុំ ដោយគ្មានពាក់ព័ន្ធជាមួយនឹងនិក្ខេបបទអ្នកផ្សេងឡើយ។ លទ្ធផល នៃការស្រាវជ្រាវដែលបានលើកឡើងនៅក្នុងអត្ថបទនេះ គឺថ្មី ដោយពុំមានការលួចចម្លងលើអត្ថន័យ និងខ្លឹមសារពីក្នុងនិក្ខេបបទរបស់បុគ្គលណាម្នាក់ឡើយ។

# មាតិកា


ទំព័រ

**សេចក្តីផ្តើម** ........ ១

១.លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១

២.ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ២

៣.គោលបំណងនៃការស្រាវជ្រាវ ........ ២

៤.ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........ ២

៥.សារៈសំខាន់នៃការស្រាវជ្រាវ ........ ២

៦.វិធីសាស្រ្តនៃស្រាវជ្រាវ ........ ៣

៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៣

**ជំពូកទី១៖ ប្រវត្តិនៃការគ្រប់គ្រងដីធ្លី និងទិដ្ឋភាពទូទៅនៃវិវាទដីធ្លី** ........ ៤

**១.១.ប្រវត្តិនៃការគ្រប់គ្រងដីធ្លី** ........ ៤

**១.២.ទិដ្ឋភាពទូទៅនៃវិវាទដីធ្លី** ........ ៥

១.២.១.វិវាទដីធ្លី ........ ៦

១.២.២.ប្រភេទដីមានវិវាទ ........ ៦

១.២.៣.ប្រភេទនៃករណីវិវាទ ........ ៩

**១.៣.មូលហេតុនៃវិវាទដីធ្លី** ........ ៩

១.៣.១.សម្បទានដីសេដ្ឋកិច្ច ........ ១០

១.៣.២.ការផ្ទេរសិទ្ធិដោយមិនស្របច្បាប់ ........ ១៤

១.៣.៣.ការរំលោភ និងការចាប់ដីខុសច្បាប់ ........ ១៦

១.៣.៤.កត្តាកើតចេញពីប្រជាពលរដ្ឋ ........ ១៩

១.៣.៥.ការចុះបញ្ជី និងដំណើរការការផ្តល់ប័ណ្ណកម្មសិទ្ធិមិនគ្រប់គ្រាន់ ........ ២០

**ជំពូកទី២៖ យន្តការដោះស្រាយវិវាទដីធ្លី** ........ ២១

**២.១.ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ** ........ ២៣

២.១.១.ការចរចារ ........ ២៤

២.១.២.សន្ទានកម្ម ឬការសម្រុះសម្រួល ........ ២៤

២.១.៣.ការដោះស្រាយវិវាទដោយគណៈកម្មការសុរិយោដីថ្នាក់ស្រុក/ខណ្ឌ ...................... ២៥

២.១.៤.ការដោះស្រាយវិវាទដោយគណៈកម្មការសុរិយោដីថ្នាក់រាជធានី/ខេត្ត...................... ២៧

២.១.៥ ការដោះស្រាយវិវាទដោយគណៈកម្មការសុរិយោដីថ្នាក់ជាតិ ................................ ២៨

២.១.៦.អាជ្ញាកណ្តាល........................................................................................ ៣០

២.៣.៧.គុណសម្បត្តិ និងគុណវិបត្តិនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ.................. ៣០

**២.២.ការដោះស្រាយវិវាទដីធ្លីតាមប្រព័ន្ធតុលាការ** ................................................. ៣១

២.២.១.នីតិវិធីនៃបណ្តឹង............................................................................................ ៣៣

២.២.១.១.ការដាក់ពាក្យបណ្តឹង .................................................................................. ៣៣

២.២.១.២.ការបង់ពន្ធលើពាក្យបណ្តឹង............................................................................ ៣៤

២.២.១.៣.ការពិនិត្យពាក្យបណ្តឹង និងការបញ្ជូនពាក្យបណ្តឹង............................................ ៣៤

២.២.២.ដំណាក់កាលការដោះស្រាយវិវាទ ...................................................................... ៣៥

២.២.២.១.នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលផ្ទាល់មាត់ ............................................ ៣៦

២.២.២.២.នីតិវិធីទាញហេតុផលផ្ទាល់មាត់ .................................................................. ៣៧

២.២.២.៣.ការចេញសាលក្រម........................................................................................ ៣៨

២.២.៣.បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ............................................................. ៣៩

២.២.៣.១.បណ្តឹងឧទ្ធរណ៍............................................................................................ ៣៩

២.២.៣.២.បណ្តឹងសាទុក្ខ ............................................................................................ ៤០

២.២.៣.៣.គុណសម្បត្តិ និងគុណវិបត្តិនៃការដោះស្រាយវិវាទដីធ្លីតាមប្រព័ន្ធតុលាការ.............. ៤១

**សេចក្តីសន្និដ្ឋាន**................................................................................................. ៤៣

**អនុសាសន៍**........................................................................................................ ៤៤

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រវត្តិសាស្ត្រនៃសង្គ្រាមដ៏ជូរចត់ ដែលបានកើតឡើងចាប់តាំងពីឆ្នាំ ១៩៧៥ រហូតដល់ឆ្នាំ១៩៩១ ទើបមានការចុះហត្ថលេខាលើកិច្ចព្រមព្រៀងទីក្រុងប៉ារីស ដែលបានផ្តល់ក្របខណ្ឌលទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងសិទ្ធិមនុស្សនៅកម្ពុជា។ ក្នុងរយៈពេលនៃសង្គ្រាម អ្វីៗត្រូវបំផ្លាញស្ទើរតែទាំងស្រុង ដោយរួមមានទាំងហេដ្ឋារចនាសម្ព័ន្ធ និងឯកសារនានាដែលបញ្ជាក់ពីសិទ្ធិលើកម្មសិទ្ធិ ។ បន្ទាប់ពីឆ្នាំ១៩៧៩ ទោះបីជាប្រទេសជាតិបានរួចផុតពីរបបប្រល័យពូជសាសន៍ក៏ដោយ ការស្តារប្រទេសឡើងវិញគឺពិតជាមានការលំបាកយ៉ាងខ្លាំង ហើយការផ្តល់ប័ណ្ណកម្មសិទ្ធិលើដីធ្លីក៏ជាបញ្ហាមួយក្នុងចំណោមបញ្ហាជាច្រើន ដែលត្រូវអភិវឌ្ឍរហូតមកទល់បច្ចុប្បន្ន ហើយវានៅតែជាបញ្ហាដ៏ស្រួចស្រាល់ដែលធ្វើឱ្យប្រជាជនជាជនរងគ្រោះ មានការតវ៉ាធ្វើបាតុកម្មជាបន្តបន្ទាប់ ដើម្បីរកយុត្តិធម៌ ពាក់ព័ន្ធនឹងការរំលោភលើសិទ្ធិកម្មសិទ្ធិ ហើយបញ្ហានេះដាច់ខាតតម្រូវឱ្យរដ្ឋាភិបាលស្វែងរកវិធានដោះស្រាយឱ្យបានសមស្រប និងយុត្តិធម៌ ។

រាជរដ្ឋាភិបាលកម្ពុជា បានយកចិត្តទុកដាក់ខ្ពស់ក្នុងការគោរពនូវសិទ្ធិមនុស្ស ជាពិសេសសិទ្ធិឯកជនភាពរបស់បងប្អូនប្រជាពលរដ្ឋ។ ជាក់ស្តែងនៅអំឡុងឆ្នាំ១៩៩២ កម្ពុជាបានអនុវត្តច្បាប់ភូមិបាលមួយ ដែលច្បាប់នេះបានបញ្ជាក់ពីការទទួលបាននូវសិទ្ធិកម្មសិទ្ធិនៅលើដីធ្លីតាមរយៈសន្តតិកម្ម កិច្ចសន្យា ឬ ដោយការផ្លាស់ប្តូរពី "ការកាន់កាប់បណ្តោះអាសន្ន" ទៅជា "កម្មសិទ្ធិពេញលេញ" ជាអាទិ៍ ។ ក្រោយមកនៅឆ្នាំ ២០០១ ច្បាប់ភូមិបាលបច្ចុប្បន្នត្រូវបានប្រកាសឱ្យប្រើ ដែលច្បាប់នេះអនុញ្ញាតឱ្យមានកម្មសិទ្ធិឯកជនលើដីធ្លីពេញលេញនៅកម្ពុជា ព្រមទាំងបានបង្កើតឱ្យមាននូវប្រព័ន្ធបញ្ជីឈ្មោះដីធ្លី និងមានប័ណ្ណកម្មសិទ្ធិដីធ្លីជូនប្រជាពលរដ្ឋ ។ ទន្ទឹមនឹងនោះ កម្ពុជាបានទទួលជំនួយពីធនាគារពិភពលោកក្នុងការរៀបចំការចុះបញ្ជីដីធ្លីលក្ខណៈជាប្រព័ន្ធ ដើម្បីចេញប័ណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋផងដែរ។ នៅក្នុងអំឡុងពេលចុះបញ្ជីដីធ្លីនេះ យើងបានប្រឈមនឹងបញ្ហាចម្បងធំ គឺវិវាទដីធ្លីដែលទាមទារចាំបាច់ឱ្យមានការដោះស្រាយជាបន្ទាន់ជូនបងប្អូនប្រជាពលរដ្ឋផងដែរ។

តាមរយៈអនុក្រឹត្យលេខ ៤៧ អនក្រ បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី គឺជាយន្តការថ្មីមួយដើម្បីដោះស្រាយវិវាទដីធ្លីដែលគណៈកម្មការនេះមានបេសកម្ម និងតួនាទីជាអ្នកសម្រេចចំពោះវិវាទដីភោគៈមុនបញ្ជូនទៅតុលាការសម្រេចចាត់ការបន្តនោះ។ វិវាទដីធ្លីកាន់តែមានភាពរីករាលដាលមានលក្ខណៈស្មុគស្មាញ និងតម្រូវឱ្យស្ថាប័នជំនាញយកចិត្តទុកដាក់ដើម្បី ដោះស្រាយឱ្យបានទាន់ពេលវេលា។ បញ្ហាក្របខណ្ឌគតិយុត្តទាក់ទងនឹងដីធ្លី ជាពិសេសការកសាងឯកសារគតិយុត្តសម្រាប់អនុវត្តច្បាប់ភូមិបាលឆ្នាំ២០០១ មានលក្ខណៈរីកចម្រើនផងដែរ ម្យ៉ាងដោយសារកេរតំណែលជាប្រវត្តិសាស្ត្រនៃការផ្លាស់ប្តូរគោលនយោបាយដីធ្លី បានបន្សល់ទុកឱ្យសង្គមកម្ពុជាបច្ចុប្បន្ននៅតែប្រឈមនឹងបញ្ហាជាច្រើនដែល

ទាក់ទងនឹងដីធ្លី គឺវិវាទដីធ្លីនេះតែម្តង។ ដំណោះស្រាយអាចប្រព្រឹត្តទៅបានលុះត្រាតែមានគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា ហើយស្ថាប័នអនុវត្តច្បាប់ទាំងនោះត្រូវមានធនធានមនុស្ស សម្ភារៈ និងថវិកាគ្រប់គ្រាន់ ព្រមទាំងមានឆន្ទៈក្នុងការដោះស្រាយផងនោះ ទើបវិវាទដីធ្លីអាចត្រូវបានថយចុះ។

## ២.ចំណោទបញ្ហា

ផ្អែកទៅលើមូលដ្ឋាននៃបទដ្ឋានគតិយុត្ត ដោយមានច្បាប់ភូមិបាល ក្រមរដ្ឋប្បវេណី អនុក្រឹត្យ និងព្រះរាជក្រឹត្យ និងច្បាប់ជាច្រើនដែលពាក់ព័ន្ធនឹងបញ្ហានេះ។ អ្វីដែលពិសេសនោះគឺ ផលប៉ះពាល់ដែលកើតឡើងទាក់ទិននឹងប្រភពនៃវិវាទនិងយន្តការក្នុងការដោះស្រាយវិវាទដីធ្លីនៅកម្ពុជា។ ហើយដើម្បីសម្រេចបាននូវកម្មវត្ថុនៃប្រធានបទនេះ ខ្ញុំសូមលើកចំណោទបញ្ហាទាក់ទងនឹងបញ្ហាវិវាទដីធ្លី យន្តការក្នុងការដោះស្រាយវិវាទដីធ្លីនៅកម្ពុជាថា៖

១.តើកត្តាអ្វីដែលជាហេតុនាំឱ្យកើតមានវិវាទដីធ្លី?

២.តើមានវិធីសាស្ត្របែបណាដើម្បីដោះស្រាយវិវាទដីធ្លីទាំងនោះ?

៣.តើប្រសិទ្ធិភាពក្នុងការដោះស្រាយវិវាទដីធ្លីមានលក្ខណៈយ៉ាងណាដែរ?

## ៣.គោលបំណងនៃការស្រាវជ្រាវ

គោលបំណងចម្បងក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទនេះ គឺដើម្បីរួមចំណែកកាត់បន្ថយផលប៉ះពាល់លើដីធ្លី និងធ្វើការឈ្វេងយល់ពីស្ថានភាពវិវាទនិងយន្តការក្នុងការដោះស្រាយវិវាទដីធ្លីដែលប្រជាពលរដ្ឋមានសិទ្ធិអាចតតាំង ប្រើប្រាស់នូវសិទ្ធិរបស់ខ្លួនស្របតាមច្បាប់ និង សិក្សាពីនីតិវិធីនៃការដោះស្រាយវិវាទដីធ្លីនៅកម្ពុជា។

## ៤.ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

សារណាបញ្ចប់ការសិក្សានេះគ្រប់ដណ្តប់លើយន្តការដោះស្រាយវិវាទដីធ្លីនៅកម្ពុជា។ ការសិក្សានេះបានផ្តោះទៅលើនីតិវិធីច្បាប់ភូមិបាល និង ក្រមរដ្ឋប្បវេណីនៅកម្ពុជា និងលិខិតបទដ្ឋាននានាដែលពាក់ព័ន្ធ។ ទន្ទឹមនឹងនេះ ដើម្បីសិក្សាពីប្រសិទ្ធិភាពក្នុងការទទួលបានដំណោះស្រាយវិវាទដីធ្លីសមស្របមួយ និងដោយស្របច្បាប់នៅកម្ពុជា។

## ៥.សារៈសំខាន់នៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះ នឹងផ្តល់សារៈសំខាន់ដល់សង្គមជាតិគឺជួយកាត់បន្ថយបាននូវករណីវិវាទដីធ្លីនៅកម្ពុជា រកច្រកចេញពីបញ្ហាប្រឈមដោយសារវិវាទដីធ្លីតាមយន្តការឈ្នះៗទាំងអស់គ្នា។ ប្រធានបទនេះនឹងអាចជួយឱ្យប្រជាពលរដ្ឋនិងអ្នកសិក្សាយល់ដឹងពីប្រភពនៃបញ្ហាវិវាទដីធ្លី និងយន្តការក្នុងការដោះស្រាយវិវាទដីធ្លីដោយស្របច្បាប់ និងជួយដល់ខ្លួនឯងនិងអ្នកស្រាវជ្រាវផ្សេងទៀត ជាឯកសារក្នុងការជួយបំភ្លឺបន្ថែមដល់អ្នកសិក្សាអ្នកស្រាវជ្រាវជំនាន់ក្រោយយកទៅសិក្សាបន្ត។

## ៦.វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសរសេរសារណាបញ្ចប់ការសិក្សានេះបានសម្រេចជាស្ថាពរបាន គឺយើងខ្ញុំបានស្រាវជ្រាវឯកសារនៅបណ្ណាល័យដែលចងក្រងដោយសាស្ត្រាចារ្យ សិស្សនិស្សិត និងតាមប្រព័ន្ធអ៊ីនធឺណែត និងច្បាប់ដែលពាក់ព័ន្ធផ្សេងៗទៀត។ ជាពិសេស នោះគឺមានការណែនាំពីសាស្ត្រាចារ្យ កង ស៊ីផាន់ណារ៉ា ដែលជាសាស្ត្រាចារ្យដឹកនាំសរសេរសារណានេះផ្ទាល់តែម្តង ដែលបានជួយតម្រង់ទិសរហូតបានសម្រេចជាសមទ្ធិផលប្រធានបទ "ការដោះស្រាយវិវាទដីធ្លីនៅកម្ពុជា" ។

## ៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណាបញ្ចប់ការសិក្សានេះ ចែកចេញជាពីរជំពូកៈ

សេចក្តីផ្តើម

ជំពូកទី១៖ ប្រវត្តិនៃការគ្រប់គ្រងដីធ្លី និងទិដ្ឋភាពទូទៅនៃវិវាទដីធ្លី

ជំពូកទី២៖ យន្តការដោះស្រាយវិវាទដីធ្លី

សេចក្តីសន្និដ្ឋាន

អនុសាសន៍

ឧបសម្ព័ន្ធ។

# ជំពូកទី១

# ប្រវត្តិនៃការគ្រប់គ្រងដីធ្លី និងទិដ្ឋភាពទូទៅនៃវិវាទដីធ្លី

នៅក្នុងជំពូកនេះចំណុចសំខាន់ៗមួយចំនួននឹងត្រូវលើកឡើង អំពីទិដ្ឋភាពទូទៅពាក់ព័ន្ធនឹងទំនាក់ទំនងរវាងមនុស្សជាមួយដីធ្លី និងទ្រឹស្តីពាក់ព័ន្ធវិវាទ។

## ១.១.ប្រវត្តិនៃការគ្រប់គ្រងដីធ្លី

នៅមុនពេលកម្ពុជាស្ថិតក្រោមអាណានិគមបារាំង នៅឆ្នាំ១៨៦៣ ដីធ្លីទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ជារបស់ព្រះមហាក្សត្រ។ សញ្ញាណនៃកម្មសិទ្ធិដីធ្លី ត្រូវបាននាំយកមកប្រទេសកម្ពុជា នៅសម័យអាណាព្យាបាលបារាំង និងនៅបន្តយកមកអនុវត្តនៅសម័យក្រោយឯករាជ្យ រហូតមកដល់ការលុបបំបាត់ទ្រព្យសម្បត្តិឯកជនដោយរបបខ្មែរក្រហម។ កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសឆ្នាំ១៩៩១ បានបញ្ចប់ការកាន់កាប់របស់វៀតណាមមកលើកម្ពុជា និងបានបង្កើតឱ្យមានរបបសេដ្ឋកិច្ចទីផ្សារ ដែលនាំឱ្យមានការស្តាររបបកម្មសិទ្ធិឯកជនលើដីឡើងវិញនៅក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ។ កសិកម្ម គឺជាមុខរបរចម្បងមួយសម្រាប់ប្រជាជនកម្ពុជាប្រមាណ ៨០% ប៉ុន្តែភាគច្រើន នៃពួកគេរស់ក្នុងតំបន់ទីជនបទ និងពឹងផ្អែកលើវិស័យកសិកម្មតែមួយមុខ ឬផ្សេងទៀត។ ផលិតកម្មដំណាំស្រូវ គឺពឹងផ្អែកលើលទ្ធភាពនៃដី បង្កបង្កើនផល និងប្រព័ន្ធស្រោចស្រព។

ចាប់តាំងពីឆ្នាំ២០០១មក នៅពេលដែលច្បាប់ភូមិបាលត្រូវបានអនុម័ត រាជរដ្ឋាភិបាលកម្ពុជាបានធ្វើឱ្យមានការរីកចម្រើនក្នុងការអភិវឌ្ឍគោលនយោបាយ បទប្បញ្ញត្តិ និងការគ្រប់គ្រងក្របខ័ណ្ឌគតិយុត្តសម្រាប់រៀបចំដែនដី។ច្បាប់ភូមិបាលបានណែនាំអំពីការបែកចែកកម្មសិទ្ធិដីជាបីប្រភេទធំៗ៖

- **កម្មសិទ្ធិរដ្ឋ ចែកចេញជាពីរអនុប្រភេទគឺ៖**

  **១.កម្មសិទ្ធិសាធារណៈរបស់រដ្ឋ** មានតម្លៃជាប្រយោជន៍សាធារណៈរួមមានបឹង ភ្នំ ផៃ អាកាស យាន្តដ្ឋាន ផ្លូវ សួនសាធារណៈ សាលារៀន មន្ទីរពេទ្យ តំបន់ការពារ ស្ថានីយ៍ ប្រវត្តិសាស្ត្រ និងកម្មសិទ្ធិជាផ្លូវការរបស់ព្រះរាជវង្សានុវង្ស[1]។ ដីសាធារណៈរបស់រដ្ឋមិនអាចទិញដូរ ឬធ្វើសម្បទានដីសេដ្ឋកិច្ចនោះទេ ទោះកម្មសិទ្ធិទាំងនោះអាចជួលបានរហូតដល់៥០ឆ្នាំក៏ដោយ។

  **២.កម្មសិទ្ធិឯកជនរបស់រដ្ឋ** ពុំមានតម្លៃជាប្រយោជន៍សាធារណៈដូចបានបរិយាយនៅចំណុចខាងលើឡើយ។កម្មសិទ្ធិនេះអាចលក់ដូរនិងជួលសម្រាប់ពាណិជ្ជកម្មឧស្សាហកម្មខ្នាតធំបាន ដោយរាប់បញ្ចូលទាំងការជួលរយៈពេលវែង និងសម្បទានដីផងដែរ[2]។

- **កម្មសិទ្ធិសមូហភាព ចែកចេញជាពីរអនុប្រភេទ៖**

[1] ច្បាប់ភូមិបាលឆ្នាំ២០០១៖ មាត្រា១៥ និងអនុក្រឹតលេខ ១១៨ ស្តីពីការគ្រប់គ្រងដីសម្បត្តិរដ្ឋ ០៧ តុលា ឆ្នាំ២០០៤៖ មាត្រា៤។

[2] ច្បាប់ភូមិបាលឆ្នាំ២០០១៖ មាត្រា១៧

**១.កម្មសិទ្ធិវត្តអារាមព្រះពុទ្ធសាសនា៖** ដី និងសំណង់នៅក្នុង និងក្រៅបរិវេណវត្តអារាមព្រះពុទ្ធសាសនា។

**២.កម្មសិទ្ធិសមាគមជនជាតិដើមភាគតិច៖**កម្មសិទ្ធិប្រភេទនេះត្រូវបានប្រើប្រាស់សម្រាប់ការតាំងលំនៅ និងការធ្វើកសិកម្មបែបប្រពៃណីដោយសមាគមន៍ជនជាតិដើមភាគតិច។

- **កម្មសិទ្ធិឯកជន** កាន់កាប់ដោយ ឬមានម្ចាស់កម្មសិទ្ធិដោយស្របច្បាប់ជាបុគ្គល ឬក្រុមហ៊ុន។

## ១.២.ទិដ្ឋភាពទូទៅនៃវិវាទដីធ្លី

បើយើងពិនិត្យមើលចាប់ពីក្រោយឆ្នាំ១៩៩៣មក រដ្ឋធម្មនុញ្ញថ្មីមួយត្រូវប្រកាសថា កម្ពុជាក្លាយទៅជាព្រះរាជាណាចក្រកម្ពុជាទី២ និងបង្កើតបាននូវរដ្ឋាភិបាលថ្មីមួយឡើង ក្នុងនោះរដ្ឋធម្មនុញ្ញថ្មីសម្រាប់ព្រះរាជាណាចក្រកម្ពុជាត្រូវបានបង្កើតឡើងដូចត្រង់មាត្រា៤៤ នៃរដ្ឋធម្មនុញ្ញបានបញ្ជាក់ពីសិទ្ធិក្នុងការធ្វើម្ចាស់លើដីធ្លី ប៉ុន្តែការកំណត់សិទ្ធិនេះ គឺចំពោះតែជនជាតិខ្មែរតែប៉ុណ្ណោះ។ ទាំងនេះជាកត្តាមួយជំរុញឱ្យមានការបង្កើតឡើងនូវច្បាប់ភូមិបាលថ្មី ជំនួសច្បាប់ភូមិបាលឆ្នាំ១៩៩១ និងការតាក់តែងនូវលិខិតបទដ្ឋានគតិយុត្តជាច្រើនលើវិស័យដីធ្លីនេះ។

ពាក្យថា "វិវាទ" មានន័យថា ដំណើរទាស់ទែងគ្នា ដំណើរឈ្លោះប្រកែកគ្នា។ ចំណែកពាក្យថា"ទំនាស់" មានន័យថា វិវាទអំពើទាស់ដែលផ្ទុយគ្នា ដែលទីទៃពីគ្នា រីឯពាក្យ "ជម្លោះ" មានន័យថា វិវាទ ដំណើរឈ្លោះ កើតជម្លោះ។ សរុបមកឃើញថា អត្ថន័យនៃពាក្យ វិវាទ ទំនាស់ និងជម្លោះ មានន័យ ស្រដៀងគ្នា។

ចំពោះការប្រើពាក្យ "វិវាទ" និង "ទំនាស់" របស់រដ្ឋាភិបាលមានអត្ថន័យខុសគ្នា គឺថាវិវាទ មានលក្ខណៈស្រាលជាងទំនាស់ នេះបើផ្អែកតាម មាត្រា៣ នៃអនុក្រឹត្យស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី និង មាត្រា៣នៃព្រះរាជក្រឹត្យស្តីពីការបង្កើតអាជ្ញាធរដោះស្រាយទំនាស់ដីធ្លី ដោយផ្តល់អំណាចទៅឲ្យអាជ្ញាធរជាតិដោះស្រាយទំនាស់ទាំងឡាយណាដែលហួសពីសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដី ដែលគណៈកម្មការនេះដោះស្រាយវិវាទទាក់ទងនឹងអចលនវត្ថុ ដែលមិនទាន់បានចុះបញ្ជីសុរិយោដី។

ចំណែកលោក Barringer បានឱ្យនិយមន័យនៃពាក្យ "វិវាទ" នេះមានអត្ថន័យខុសគ្នាអំពី វចនានុក្រមភាសាខ្មែររបស់សម្តេចព្រះសង្ឃរាជ ជួន ណាត ។ ន័យរបស់ពាក្យ វិវាទ ទំនាស់ និង ជម្លោះ របស់ខ្មែរ គឺស្មើនឹងពាក្យ Dispute ជាអំពើទាស់ទែងនូវកម្រិត (ទីមួយ) ជាពាក្យសំដី។ ចំណែកវិវាទឈានដល់កម្រិតធ្ងន់ (ទីពីរ) គេប្រើពាក្យ Conflict ដែលយើងតែងបកប្រែមកខេមរភាសាថាជា "ទំនាស់" ឬ "វិវាទ" ដដែលនោះ តែតាមពិតវាមានន័យធ្ងន់ជាង គឺការប្រឆាំងតបជា សកម្មភាពយ៉ាងខ្លាំងក្លា។ ចំណែកឯវិវាទកម្រិត (ទីបី) វិញគេប្រើពាក្យ Hostilities គឺជាសកម្មភាព ប្រឆាំងដោយអំពើហិង្សា ឬសកម្មភាពឈានដល់សង្គ្រាម។ វិវាទដីធ្លីនៅកម្ពុជាបាន នឹងកំពុងកើតឡើងឥតឈប់ឈរ រវាងប្រជាកសិករក្រីក្រជាមួយនឹងមន្ត្រីរាជការ ដែលនេះបានជះឥទ្ធិពលយ៉ាងខ្លាំងដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលដែលដឹកនាំ ដោយសម្តេចនាយក

រដ្ឋមន្ត្រី បានដាក់បញ្ហាវិវាទដីធ្លី ចូលទៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាលកម្ពុជា ដូចបានបញ្ជាក់នៅក្នុងសុន្ទរកថាខាងក្រោម៖

> ភាពអាណាធិបតេយ្យក្នុងការកាន់កាប់ដីយដោខុសច្បាប់ និង បទបញ្ញត្តិការរំលោភយកដីរដ្ឋ ការកាន់កាប់រានទន្ទ្រានដីព្រៃក្នុងតំបន់ការពារធម្មជាតិទៅធ្វើជាកម្មសិទ្ធិឯកជន និងការកាប់ឈើដោយខុសច្បាប់ នៅតែមានជាអន្លើៗនៅឡើយ។ ទន្ទឹមនឹងនេះ ភាពក្រីក្រ និងបាតុភូតចំណាកស្រុកទៅរានដីថ្មីល្មើសនឹងច្បាប់បានធ្វើឱ្យធនធានធម្មជាតិ រងសម្ពាធការបំផ្លាញ[3] ។

## ១.២.១.វិវាទដីធ្លី

វិវាទដីធ្លីបង្កឱ្យកើតមានឡើងនូវអំពើហិង្សាបង្ករបួសស្នាម និងអាចឈានទៅដល់ការសម្លាប់មនុស្សទៀតផង។ ពេលខ្លះអំហិង្សានេះបានប្រព្រឹត្តឡើងដោយកងកម្លាំងប្រដាប់អាវុធទៅលើប្រជាពលរដ្ឋក្រីក្រ ដែលជាជនរងគ្រោះនៅកន្លែងដែលមានជម្លោះស្រួចស្រាល់ខ្លះ។ ជាងនេះទៅទៀត ពេលខ្លះអ្នកប្រព្រឹត្តមិនត្រូវបានផ្តន្ទាទោសក្នុងការទទួលខុសត្រូវរបស់ខ្លួនលើការបង្កឱ្យមានរបួស ឬស្លាប់មនុស្សនោះទេ ។ តែផ្ទុយទៅវិញ ប្រជាពលរដ្ឋរងគ្រោះមួយចំនួន ដែលជាប់ពាក់ព័ន្ធនឹងវិវាទដីធ្លី ពួកគេត្រូវបង្ខំឱ្យចាកចេញពីទីកន្លែងដីទំនាស់ ដើម្បីជាថ្នូរក្នុងការដោះលែងពួកគេពីការឃុំឃាំង។ ប្រជាពលរដ្ឋភាគច្រើនកាន់កាប់ដីតាមទម្លាប់ ដោយមិនមានប័ណ្ណកម្មសិទ្ធិ ពីព្រោះពួកគាត់មិនមានលទ្ធភាពបង់ថ្លៃធ្វើប័ណ្ណ និងបង់ពន្ធដារ ។ ក៏ប៉ុន្តែតាមច្បាប់ភូមិបាលឆ្នាំ២០០១ មាត្រា៣០ ក្នុងករណីដែលពួកគាត់រស់នៅលើដីនោះដោយសុចរិត លើសពីប្រាំឆ្នាំមុនច្បាប់នេះចូលជាធរមាន ពួកគាត់ទទួលបានសិទ្ធិកម្មសិទ្ធិលើដីដោយស្របច្បាប់ ។ ការប្រើអំពើហិង្សាដើម្បីដកហូត អចលនវត្ថុដោយអាជ្ញាធរ អចលនវត្ថុនោះត្រូវប្រគល់មករដ្ឋវិញ ហើយមិនអាចជាកម្មវត្ថុនៃការកាប់ថ្មីទេ[4] ។ តាមការស្រាវជ្រាវនិងយល់ដឹងជាសាកលបញ្ហាអំពើហិង្សានៃវិវាទដីនេះ កើតមានក្រោយរដ្ឋាភិបាលអនុញ្ញាតឱ្យមានកម្មសិទ្ធិឯកជនលើដីធ្លីតាមរយៈនេះមន្ត្រីខិលខូចជាស៊ីវិលនិងយោធា មួយចំនួនបានឆ្លៀតឱកាសពីភាពចន្លោះប្រហោងនៃការគ្រប់គ្រងរបស់រដ្ឋាភិបាលរឹបអូសយកដីធ្លីរបស់កសិករ។ ការណ៍នេះបណ្តាលឱ្យប្រជាពលរដ្ឋបាត់បង់អ្វីៗទាំងអស់។ ម៉្យាងទៀតប្រព័ន្ធយុត្តិធម៌មិនទាន់មានលក្ខណៈល្អប្រសើរនៅឡើយ។ ការប្រឆាំងតបរបស់ប្រជាពលរដ្ឋជាច្រើនករណីវាអាចជារឿងដែលបង្កប់នូវអំពើអយុត្តិធម៌ បើមិនមានការដោះស្រាយឱ្យបានទាន់ពេលវេលាទេនោះនឹងអាចនាំឱ្យកើតនូវអសន្តិសុខសង្គមផងដែរ ។ ម៉្យាងវិញទៀត គម្លាតរវាងអ្នកមាននិងអ្នកក្រ និងស្ថានភាពប្រឈមមុខនៃភាពក្រីក្ររបស់ប្រជាពលរដ្ឋធ្លាប់ជាមូលហេតុមួយនៃការកើតចលាចលនៅក្នុងសង្គម ។

[3] សន្ទរកថាស្តីពីយុត្តិសាស្ត្រចតុកោណដំណាក់កាលទី២ ថ្លែងនៅក្នុងអង្គប្រជុំគណៈរដ្ឋមន្ត្រីលើកទី១ សម្រាប់អាណត្តិទី៤ នៃរដ្ឋសភា នៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៨ ទំព័រ១៣ ។

[4] ច្បាប់ភូមិបាល, លេខ នស/រកម/០៨០១/១៤,៣០ សីហា ២០០១ មាត្រា៣៣ ។

### ១.២.២.ប្រភេទដីមានវិវាទ

វិវាទដីធ្លីដែលតែងតែកើតមាននៅក្នុងសង្គមកម្ពុជា មិនចេះចប់មិនចេះហើយបែបនេះ គឺបណ្តាលមកពីមូលហេតុមិនមានប័ណ្ណកម្មសិទ្ធិសម្រាប់សម្គាល់ការកាន់កាប់ស្របច្បាប់ ដែលចេញដោយប្រធានមន្ទីរសុរិយោដីខេត្ត/ក្រុង នៅមានកម្រិត ពោលគឺពុំទាន់បានគ្រប់ជ្រុងជ្រោយនៅឡើយ ។ រាល់ការគ្រប់គ្រងផ្ទះសម្បែងនិងដីធ្លីត្រូវបានរដ្ឋផ្តល់ជូនប្រជាពលរដ្ឋកាន់កាប់ដែលចាប់ផ្តើមតាំងពីឆ្នាំ១៩៨៨ មកម្ល៉េះ។ រហូតមកដល់ឆ្នាំ២០០១ ទើបមានច្បាប់ភូមិបាលត្រូវបានអនុម័តដោយឱ្យប្រើប្រាស់ជាផ្លូវការ។

ការគ្រប់គ្រងនិងបែកចែកដី ដែលជាកម្មសិទ្ធិឯកជននិងរដ្ឋមិនមានភាពច្បាស់លាស់ត្រឹមត្រូវដូចជាការផ្តល់សម្បទានដីសេដ្ឋកិច្ចទៅឱ្យអ្នកវិនិយោគក្នុងស្រុក និងក្រៅប្រទេសដោយមិនគោរពច្បាប់និងគោលការណ៍ផ្តល់សម្បទានដីសេដ្ឋកិច្ច ជាពិសេសមិនបានចុះសហការជាមួយនឹងអាជ្ញាធរដែលពាក់ព័ន្ធសហគមន៍ និងអង្គការស៊ីវិលដទៃទៀត មួយវិញទៀតអាចមានការឃុំឃិតពាក់ព័ន្ធ នឹងអំពើពុករលួយដែលប្រព្រឹត្តឡើងដោយមន្ត្រីពាក់ព័ន្ធនិងក្រុមហ៊ុនមួយចំនួនដើម្បីទទួលបានអាជ្ញាប័ណ្ណពីរាជរដ្ឋាភិបាល។

ជាទូទៅក្នុងសកលលោក វិវាទដីធ្លីចែកចេញជា ៤ផ្នែក ហើយផ្នែកនីមួយៗចែកចេញជា ៣៥ប្រភេទ និងក្នុងប្រភេទទាំងនោះចែកចេញជា ៤០ អនុប្រភេទទៀត ។ ប្រព័ន្ធនៃចំណាត់ថ្នាក់វិវាទដីធ្លីនេះកើតឡើងពាក់ព័ន្ធលើដីរដ្ឋ ដីឯកជន ឬដីសមាគមន៍[5] ។

- វិវាទដែលកើតឡើងលើគ្រប់ប្រភេទនៃទ្រព្យដែលមានជាអាទិ៍ដូចខាងក្រោម៖

  ១. វិវាទព្រំប្រទល់

  ២. វិវាទលើកេរមត៌ក

  ៣. វិវាទលើកម្មសិទ្ធិដោយសារច្បាប់ (ភាពផ្ទុយគ្នារវាងច្បាប់នឹងប្រពៃណី)

  ៤ .វិវាទលើកម្មសិទ្ធិដោយសារមិនមានការចុះបញ្ជីដីធ្លី

  ៥. វិវាទរវាងដីកម្មសិទ្ធិរបស់រដ្ឋនិងដីឯកជន

  ៦. ការលក់ដីច្រើនលើកច្រើនសារ

  ៧. អលទ្ធភាពទទួលបានដីដោយសារច្បាប់ ប្រពៃណី ឬការអនុវត្តមានការរើសអើង

  ៨. លទ្ធកម្មដីក្រៅផ្លូវការដោយមិនមានការបណ្តេញ

  ៩. លទ្ធកម្មដីដោយអំពើហិង្សា រួមទាំងការប៉ះទង្គិច និងសង្គ្រាមដីធ្លី

  ១០. ការបណ្តេញចេញដោយម្ចាស់ដី

[5] Bebette Wehrmann : Land Conflict : A practical guide to dealing with land disputes, GTZ, Eschborn 2008 page14

១១. ការបណ្តេញចេញដោយខុសច្បាប់ដោយអាជ្ញាធររដ្ឋធ្វើសកម្មភាពដោយគ្មានកំណត់

១២. ការបណ្តេញចេញតាមទីផ្សារនិងកើនតម្លៃទីផ្សារដីក្នុងតំបន់

១៣. វិវាទលើការបង់ថ្លៃសម្រាប់ការប្រើប្រាស់ ទិញដី

១៤. វិវាទលើតម្លៃដី

១៥. វិវាទលើការប្រើប្រាស់របស់មនុស្ស វប្បធម៌ និងធម្មជាតិ

១៦.ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ

- វិវាទពិសេសលើទ្រព្យសម្បត្តិឯកជន៖

១៧. ការដកហូតដីដោយគ្មានសំណងពីរដ្ឋ

១៨. លក់អចលនទ្រព្យដែលមិនមែនជារបស់ខ្លួន

១៩. ជួលឱ្យខ្ចីលើទ្រព្យដែលមិនមែនជារបស់ខ្លួន

២០. ការដកហូតដីដោយមិនមានលក្ខណៈត្រឹមត្រូវតាមច្បាប់ដោយធនាគារ

២១. វិវាទដីធ្លីដោយសារដីជាប់ពាក់ព័ន្ធលើការកែទម្រង់ដីកសិកម្ម

២២. វិវាទលើការទាមទារដីក្នុងស្ថានភាពក្រោយសង្គ្រាម

២៣. ការប្រើប្រាស់ដីឯកជនដោយខុសច្បាប់

២៤. វិវាទរវាងគ្រួសារនិងគ្រួសារ ជាពិសេសករណីលើភាពមានប្តី ឬប្រពន្ធច្រើន

- វិវាទពិសេសលើទ្រព្យរួម៖

២៥. ការប្រជែងគ្នាប្រើប្រាស់លើទ្រព្យរួម

២៦. ការប្រើប្រាស់ទ្រព្យរួមដោយខុសច្បាប់

២៧. ការលក់ទ្រព្យរួមដោយគ្មានការអនុញ្ញាត

២៨. វិវាទលើការបែងចែកដីនៃចំណូលពីដីតាមប្រពៃណី

- វិវាទពិសេសលើទ្រព្យរដ្ឋ៖

២៩. ការប្រើប្រាស់ដីរដ្ឋដោយខុសច្បាប់

៣០. ការប្រជែងគ្នាលើការប្រើប្រាស់សិទ្ធិលើទ្រព្យរបស់រដ្ឋ

៣១.ការចាប់យកដីដោយខុសច្បាប់ដោយមន្ត្រីជាន់ខ្ពស់សាធារណៈ

៣២. លក់ដីរដ្ឋខុសច្បាប់

៣៣. ជួលដីរដ្ឋខុសច្បាប់ (រួមទាំងសម្បទានដីធ្លី ព្រៃឈើ និងរ៉ែ)

៣៤. វិវាទលើផលចំណូលនៃរដ្ឋពីការជួល លក់ និងផ្ទេរការប្រើប្រាស់ដីរដ្ឋ

៣៥. ការធ្វើឯកជនូបនីយកម្មមិនត្រឹមត្រូវ (ឧ.ការបែងចែកដី ឬការផ្តល់ប័ណ្ណមិនត្រឹមត្រូវ)។

## ១.២.៣.ប្រភេទនៃករណីវិវាទដីធ្លី

ជាទូទៅទំនាស់ដីធ្លីតែងតែកើតមានជាហូរហែរពាសពេញផ្ទៃប្រទេសជាពិសេសតំបន់អភិវឌ្ឍ ផ្នែកសេដ្ឋកិច្ច និងការផ្តល់សម្បទានដីសេដ្ឋកិច្ចរួមមាន ខេត្តបាត់ដំបង ខេត្តព្រះសីហនុ ខេត្តបន្ទាយមានជ័យ និងខេត្តកណ្តាល។ ភាគច្រើនវិវាទនេះកើតមានឡើងរវាងប្រជាពលរដ្ឋតាមសហគមន៍ និងក្រុមហ៊ុនដែលទទួលបានសម្បទានដីសេដ្ឋកិច្ចពីរដ្ឋាភិបាល លើសពីនេះករណីវិវាទដីធ្លីជាច្រើន ជាប់ទាក់ទងនិងភាពមិនច្បាស់លាស់នៃម្ចាស់កម្មសិទ្ធិលើអចលនទ្រព្យ ដែលភាគីវិវាទធ្វើការទាមទាររវាងសិទ្ធិលើកម្មសិទ្ធិដោយកំណត់លើលិខិតគតិយុត្ត និងសិទ្ធិលើកម្មសិទ្ធិដោយកំណត់លើការកាន់កាប់ប្រើប្រាស់ជាក់ស្តែងជាលក្ខណៈប្រពៃណី។

វិវាទដីធ្លីអាចកើតមាននៅគ្រប់តំបន់ផ្សេងៗគ្នា ដែលមាននៅលើដីកសិកម្មរួមមានដីសម្រាប់បង្កបង្កើនផលដីចម្ការ ដីលំនៅដ្ឋាន ដីព្រៃ និងដីផ្សេងៗទៀតដូចជាត្រពាំងសហគមន៍ ព្រៃលិចទឹក ជាដើម។ តែទោះជាយ៉ាងណាក៏ដោយ វិវាទដីធ្លីភាគច្រើនមាននៅលើប្រភេទដីកសិកម្ម ដីព្រៃ ដីលំនៅដ្ឋាន និងដីផ្សេងៗទៀតដូចជាត្រពាំងសហគមន៍ ព្រៃលិចទឹក ជាដើម ។ ករណីវិវាទដីធ្លីបានកើតមានជាយូរមកហើយ អាចនិយាយបានថាតាំងពីឆ្នាំ ១៩៩០ នៅពេលដែលមានរបបនយោបាយឈានទៅរកឯកជនភាវូបនីយកម្ម ទីផ្សារសេរី និងសកលភាវូបនីយកម្ម រហូតមកដល់បច្ចុប្បន្នដែលមានករណីវិវាទដីធ្លីមួយចំនួនធំត្រូវបានដោះស្រាយ និងមួយចំនួនធំនៅមិនទាន់បានដោះស្រាយនៅឡើយទេ ដែលបញ្ហានេះនាំទៅដល់ការបណ្តេញចេញ ការបង្ខាំង ការកាត់ទោសរហូតដល់ការដាក់គុកជាដើម។

## ១.៣.មូលហេតុនៃវិវាទដីធ្លី

ចាប់តាំងពីមួយទសវត្សចុងក្រោយនេះ ដោយសារការកើនឡើងនៃតម្លៃដីធ្លី វិវាទភាគច្រើនគឺពាក់ព័ន្ធនិងកម្មសិទ្ធិដីធ្លីបានកើតឡើងរវាងប្រជាពលរដ្ឋ និងភូមិទាំងឡាយ។ ហើយមានទំនោរនៃវិវាទដីធ្លីនាំទៅដល់ការកើតឡើងអំពើហិង្សាដែលពាក់ព័ន្ធនឹងប្រជាពលរដ្ឋ អាជ្ញាធររដ្ឋាភិបាល និងក្រុមហ៊ុនឯកជនដែលទទួលបានដីសម្បទានសម្រាប់ប្រកបមុខរបរកសិកម្ម ដោយសារពួកគាត់ខ្វះការយោគយល់អាធ្យាស្រ័យរវាងគ្នានិងគ្នា ការចង់បានរបស់បុគ្គលម្នាក់ៗមិនចេះឈប់ឈរ ទោះជាដឹងថាការធ្វើបែបនេះវាខុស ក៏ដោយតែបុគ្គលទាំងនោះនៅតែព្យាយាមធ្វើ ព្រោះតែអំណាចនៃការចង់បានមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ដោយមិនខ្វល់ថាអ្នកណាខ្លះទទួលរងនូវផលប៉ះពាល់នោះឡើយ។ ចាប់តាំងពីឆ្នាំ១៩៨៩ ទោះបីជារដ្ឋាភិបាល បានព្យាយាមស្ថាបនានិងពង្រឹងការគ្រប់គ្រងដីធ្លីយ៉ាងណា ក៏នៅតែមានបញ្ហាប្រព័ន្ធច្បាប់ និងការអនុវត្តន៍។ មូលហេតុនៃវិវាទមួយទៀតនោះ កើតឡើងដោយសារតែកត្តា ប្រវត្តិសាស្ត្រ នយោបាយ សង្គម និងសេដ្ឋកិច្ច ដែលក្នុងនោះរួមមានកង្វះលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងដីធ្លី កំណើនប្រជាពលរដ្ឋ កំណើនសេដ្ឋកិច្ច និងតម្រូវការដីធ្លីចេះតែកើនឡើង។ តាម

ការយល់ឃើញរបស់ប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី គឺថាបញ្ហាទំនាស់ដីធ្លីនៅតែបន្តកើតមាននេះ បានចេញពីការមិនយល់ច្បាស់ ជាពិសេសកម្រិតនៃទណ្ឌកម្ម ដែលមានចែងក្នុងទោសបញ្ញត្តិនៃច្បាប់នីមួយៗ[6]។ ទោះបីជាយ៉ាងណាវាមានកត្តារួមផ្សំជាច្រើនទៀត ដែលបណ្តាលឱ្យមានកើតមានវិវាទដីធ្លី។

វិវាទដីធ្លីទាំងអស់ដែលបង្កើតជាបញ្ហាចាក់ស្រេះក្នុងសង្គមកម្ពុជា ក៏មានមូលហេតុរបស់វាផ្ទាល់ផងដែរ។ វិវាទដីធ្លីអាចបណ្តាលមកពីមូលហេតុជាច្រើនយ៉ាង តែមូលហេតុចម្បង គឺទាក់ទងទៅនឹងកង្វះសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី និងកង្វះការអនុវត្តលិខិតបទដ្ឋានគតិយុត្តឱ្យបានត្រឹមត្រូវ។ មូលហេតុទាំងនេះហើយដែលជាមូលហេតុបណ្តាលឱ្យមានជម្លោះដីធ្លីរហូតមកដល់បច្ចុប្បន្ននេះ។

### ១.៣.១.សម្បទានដីសេដ្ឋកិច្ច

សម្បទានដី គឺជាសិទ្ធិស្របច្បាប់ដែលមានចែងនៅក្នុងឯកសារគតិយុត្តចេញដោយអាជ្ញាធរមានសមត្ថកិច្ចអំណាចឆន្ទានុសិទ្ធិឱ្យទៅរូបវន្តបុគ្គល ឬនីតិបុគ្គល ឬក្រុមមនុស្សដើម្បីកាន់កាប់ដីនិងប្រើប្រាស់សិទ្ធិលើដីនោះតាមការកំណត់របស់ច្បាប់[7]។ រូបភាពនៃសម្បទានដីនៅក្នុងន័យនេះមានសម្បទានដីធ្លីឆ្លើយតបទៅនឹងប្រយោជន៍សង្គម និងសម្បទានដីឆ្លើយតបនឹងប្រយោជន៍សេដ្ឋកិច្ច។ ប៉ុន្តែសម្បទានដីទាំងនេះមិនស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ភូមិបាលទេ។ ជាសំខាន់នោះ សម្បទានដីមិនអាចឈានទៅដល់ការបង្កើតសិទ្ធិកម្មសិទ្ធិបានទេ (លើកលែងតែសម្បទានដែលឆ្លើយតបនឹងប្រយោជន៍សង្គម) ហើយសម្បទានដីអាចមានរយៈពេល៩៩ឆ្នាំយ៉ាងយូរ[8] និងមានទំហំច្រើនបំផុតត្រឹមតែ ១០,០០០ហិកតា ប៉ុណ្ណោះ[9]។

សម្បទានដីសេដ្ឋកិច្ច គឺជាការចុះបញ្ជីកិច្ចសន្យាជួលដីឯកជនដែលជាដីរបស់រដ្ឋ ឬការបែងចែកដី ប្រភេទនេះដោយរដ្ឋាភិបាលទៅឱ្យក្រុមហ៊ុន ឬប្រជាពលរដ្ឋ។ សម្បទានដីសេដ្ឋកិច្ចត្រូវរដ្ឋផ្តល់ទៅក្រុមហ៊ុនជាច្រើនកន្លែងក្នុងគោលបំណងឆ្លើយនឹងប្រយោជន៍សង្គមឬទៅនឹងប្រយោជន៍សេដ្ឋកិច្ច។ សម្បទានដីឆ្លើយតបទៅនឹងប្រយោជន៍សង្គម អនុញ្ញាតឱ្យអ្នកទទួលប្រយោជន៍រៀបចំដីដើម្បីសង់លំនៅឋាន ដាំដំណាំ កាប់ឆ្ការ ទាញយកផលដោយការធ្វើអាជីវកម្មនៅលើដីដែលជាកម្មសិទ្ធិរបស់រដ្ឋដើម្បីធានាការចិញ្ចឹមជីវិត។ រដ្ឋអាចធ្វើអំណោយជាអចលនវត្ថុ

---

[6] អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី, ស្វែងយល់អំពីទោសបញ្ញត្តិស្តីពីបទល្មើសដែលពាក់ព័ន្ធនឹងច្បាប់ភូមិបាល ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល និងច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ (ភ្នំពេញ៖ ២០០៧)។

[7] មាត្រា៤៨ នៃច្បាប់ភូមិបាលឆ្នាំ២០០១

[8] មាត្រា៦១ នៃច្បាប់ភូមិបាលឆ្នាំ២០០១

[9] មាត្រា៥៩ នៃច្បាប់ភូមិបាលឆ្នាំ២០០១

ចំពោះតែរូបវន្តបុគ្គលដោយហេតុផលសង្គមកិច្ច ដើម្បីឱ្យស្នាក់នៅ ឬដាំដំណាំចិញ្ចឹមជីវិត[10]។ តម្លៃអចលនវត្ថុដែលផ្តល់ឱ្យត្រូវបានកំណត់សមស្របទៅនឹងគោលដៅណាមួយដែលចង់បាន និងមិនអនុញ្ញាតឱ្យកេងយកកម្រៃ ឬធ្វើមានបានមិនស្របទៅនឹងកម្រិតជីវភាពសង្គមនៃអ្នកទទួល។ ការផ្តល់ដីតាមរយៈកិច្ចសន្យាជួលដីដើម្បីធ្វើអាជីវកម្មកសិឧស្សាហកម្មសម្រាប់រយៈពេលវែង។ រដ្ឋាភិបាលអាចផ្តល់សម្បទានដីសេដ្ឋកិច្ចបានចំពោះតែដីកម្មសិទ្ធិដែលជារបស់រដ្ឋមួយគត់ និងទំហំដីច្រើនបំផុតត្រឹមតែ ១០,០០០ហិកតា។ សម្បទានដីនេះមានរយៈពេលត្រឹមតែ៩៩ឆ្នាំយ៉ាងច្រើន។ សម្បទានិកត្រូវតែចាប់ធ្វើអាជីវកម្មលើដីសម្បទាននេះ ក្នុងរយៈពេល១២ខែក្រោយពីបានទទួលដី ប៉ុន្តែរាល់សម្បទានទាំងឡាយណាដែលមិនគោរពតាមច្បាប់ភូមិបាលឆ្នាំ២០០១ទេត្រូវចាត់ទុកជាមោឃៈ។

អនុក្រឹត្យស្តីពី សម្បទានដីសេដ្ឋកិច្ចបានបន្ថែមនូវលក្ខខណ្ឌពិសេសមួយចំនួន សម្រាប់ការអនុវត្ត និងការផ្តល់សម្បទានដីសេដ្ឋកិច្ចនេះ។ លក្ខណៈវិនិច្ឆ័យសម្រាប់ការផ្តល់សម្បទានដីសេដ្ឋកិច្ចមាន[11]៖

- ដីដែលបានចុះបញ្ជី និងធ្វើចំណាត់ថ្នាក់ជាដីឯកជនជារបស់រដ្ឋ ស្របតាមអនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ អនុក្រឹត្យស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លីឬអនុក្រឹត្យស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដាដុំ នៅចំណុចនេះ គេសង្កេតឃើញថាមានសម្បទានដីជាច្រើន នៅតាមតំបន់ដែលស្ថិតនៅក្នុងតំបន់នោះបានបាត់បង់ផលប្រយោជន៍ជាសាធារណៈ ហើយត្រូវធ្វើចំណាត់ថ្នាក់ដីឡើងវិញថាជាទ្រព្យសម្បត្តិរបស់រដ្ឋ។
- ដីដែលមានផែនការប្រើប្រាស់ដី អនុម័តដោយគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្ត ក្រុងហើយការប្រើប្រាស់មានលក្ខណៈស្របតាមផែនការ។
- ដីដែលបានធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមចំពោះការប្រើប្រាស់ ហើយនិងការអភិវឌ្ឍន៍ដីសម្រាប់គម្រោងសម្បទាន។
- ដីដែលមានដំណោះស្រាយចំពោះបញ្ហាតាំងទីលំនៅថ្មី ស្របតាមលក្ខខណ្ឌគតិយុត្ត និងនីតិវិធី ជាធរមាន។ អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាត្រូវបានធានា មិនមានការបង្ខំឱ្យធ្វើការតាំងទីលំនៅថ្មីដោយគ្មានការស្ម័គ្រចិត្តពីអ្នកកាន់កាប់ដីស្របច្បាប់ និងត្រូវធានាចំពោះការគោរពសិទ្ធិមានច្រកចេញចូលទៅកាន់ដីឯកជន។

---

[10] មាត្រា៥៣ នៃច្បាប់ភូមិបាលឆ្នាំ២០០១

[11] អនុក្រឹត្យលេខ ១៤៦ អនក្របក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច៖ មាត្រា៤

- ដីដែលមានការពិគ្រោះយោបល់ជាសាធារណៈ អំពីគម្រោងឬសំណើសម្បទានដីសេដ្ឋកិច្ច ជាមួយអាជ្ញាធរដែនដី និងប្រជាពលរដ្ឋដែលនៅក្នុងតំបន់។

ចំពោះអ្នកមានសិទ្ធិផ្តល់ដីសម្បទានសេដ្ឋកិច្ចបានមានតែ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអ្នកទទួលខុសត្រូវក្នុងការផ្តល់ដីសម្បទាន ដែលមានទុនវិនិយោគចាប់ពី ១០,០០០,០០០,០០០ (ដប់ពាន់) លានរៀលឡើង ឬមានទំហំដីសម្បទានចាប់ពី ១០,០០០ហិកតា[12] តែទោះជាយ៉ាងណាក៏ដោយមិនឱ្យលើសពីចំនួន១០,០០០ហិកតា បានឡើយ ដើម្បីធ្វើយ៉ាងណាឱ្យស្របតាមគោលការណ៍ដែលមានចែងនៅក្នុងច្បាប់ភូមិបាលឆ្នាំ២០០១ ត្រង់មាត្រា៥៩ នោះដែរ។ អភិបាលខេត្ត ក្រុង មានសិទ្ធិ និងទទួលខុសត្រូវក្នុងការផ្តល់ដីសម្បទានសេដ្ឋកិច្ច ដែលមាន ទុនវិនិយោគក្រោម ១០,០០០,០០០,០០០ (ដប់ពាន់) រៀល និងមានទំហំដីសម្បទានក្រោម ១០,០០០ហិកតា[13] ។ ក៏ប៉ុន្តែសិទ្ធិ និងអំណាចថ្នាក់ខេត្តក្រុងត្រូវលប់ចោលនៅក្នុងឆ្នាំ២០០៨[14] ដោយមានមូលហេតុ គឺដោយសារវិវាទដីធ្លីកើតឡើងពីបញ្ហាសម្បទានសេដ្ឋកិច្ចនេះច្រើនពេក។ នាពេលបច្ចុប្បន្ននេះ មានតែក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តែមានគត់ជាអ្នកមានសិទ្ធិផ្តល់នូវសម្បទានដីសេដ្ឋកិច្ច ក្នុងការវិនិយោគទុន និងជួយដល់ប្រជាពលរដ្ឋក្រីក្រនៅកម្ពុជា។

សម្បទានដីសេដ្ឋកិច្ច គឺជាយន្តការផ្ទេរដីឯកជនដែលជាកម្មសិទ្ធិរបស់រដ្ឋតាមផ្លូវច្បាប់សម្រាប់ជាទិសដៅសេដ្ឋកិច្ចដល់ប្រជាពលរដ្ឋក្រីក្រ ដែលពួកគាត់ខ្វះដីសម្រាប់ធ្វើជាជម្រកក្នុងការសង់លំនៅដ្ឋាន និងធ្វើកសិកម្មដែលជាលក្ខណៈគ្រួសារដើម្បីចិញ្ចឹមជីវិត[15]។ តាមការបញ្ជាក់របស់ច្បាប់ភូមិបាល ឆ្នាំ២០០១ ដែលនៅក្នុងច្បាប់នេះបានបញ្ញត្តិថា រដ្ឋបានផ្តល់ដីសម្បទានសម្រាប់គោលបំណងប្រើផលប្រយោជន៍សង្គម[16] ដែលមូលហេតុទាំងនេះគឺជាប្រភេទនៃសម្បទានដីសេដ្ឋកិច្ចដែលរដ្ឋបានផ្តល់ឱ្យ។ សម្បទានដីនេះ មិនដូចជាដីដូចជាដីសម្បទានផ្សេងៗទៀតទេ បុគ្គលដែលទទួលបានដីអាចក្លាយជាម្ចាស់កម្មសិទ្ធិដីធ្លីដោយស្របច្បាប់ បើពួកគេបានបំពេញតាមលក្ខខណ្ឌដែលបានកំណត់នៅក្នុងច្បាប់។ ជាការពិតណាស់រដ្ឋមានបំណងផ្តល់កម្មសិទ្ធិដីធ្លីដល់ប្រជាពលរដ្ឋក្រីក្រ តាមរយៈយន្តការសម្បទានដីសង្គមកិច្ចនេះ។

[12] អនុក្រឹត្យលេខ ១៤៦ អនក្របក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពី សម្បទានដីសេដ្ឋកិច្ច៖ មាត្រា២៩ កថាខណ្ឌទី១
[13] អនុក្រឹត្យលេខ ១៤៦ អនក្របក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពី សម្បទានដីសេដ្ឋកិច្ច៖ មាត្រា២៩ កថាខណ្ឌទី២
[14] អនុក្រឹត្យលេខ ១៣១ អនក្របក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពី ការកែសម្រួលនៃអនុក្រឹត្យ ស្តីពីសម្បទានដីសេដ្ឋកិច្ច៖ មាត្រា១
[15] អនុក្រឹត្យលេខ ១៩ អនក្របក ចុះថ្ងៃទី១៩ ខែមិនា ឆ្នាំ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច៖ មាត្រា២
[16] ព្រះរាជក្រមលេខ នសរកម០៨០១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ស្តីពី ច្បាប់ភូមិបាលឆ្នាំ២០០១៖ មាត្រា៤៩

ឧទាហរណ៍៖ ជាក់ស្តែងមានករណីមួយបានកើតឡើងនៅខេត្តព្រះវិហារ ដោយយោងតាមប្រភពព័ត៌មាន VOD ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២២ បានចុះផ្សាយទាក់ទងនឹងវិវាទដីធ្លីដែលប្រជាពលរដ្ឋមានជម្លោះដីធ្លីរ៉ាំរ៉ៃជាមួយក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ចនៅខេត្តព្រះវិហារ គ្រោងដាក់ញ្ញត្តិសុំអន្តរាគមន៍ពីអភិបាលខេត្តថ្មីឱ្យជួយដោះស្រាយ ក្រោយជម្លោះនោះអូសបន្លាយជាង១០ឆ្នាំមកហើយ។ ដោយករណីនេះកើតឡើងជាមួយប្រជាពលរដ្ឋរស់នៅក្នុងភូមិស្រយ៉ង់ ឃុំស្រយ៉ង់ ស្រុកគូលែន ខេត្តព្រះវិហារ លោក "ក" បានប្រាប់ប្រភពព័ត៌មាន វីអូឌីថា អ្នកភូមិចំនួន១៣១គ្រួសារ នៅឃុំស្រយ៉ង់ និងឃុំត្បែងពីរ កំពុងបារម្ភពីការបណ្តេញចេញទាំងបង្ខំក្រោយអាជ្ញាធរប្រកាសថា ពួកគាត់រស់នៅនិងអាស្រ័យផលលើដីរបស់ក្រុមហ៊ុន "ខ" ដោយខុសច្បាប់។ ប៉ុន្តែប្រជាពលរដ្ឋបានអះអាងថា អ្នកភូមិបានចូលទៅរស់នៅនិងអាស្រ័យផលលើដីកំពុងមានជម្លោះនេះតាំងពីឆ្នាំ២០១២មក ដោយបានបង្កបង្កើនផលដាំដំណាំហូបផ្លែ ដូចជា ចេក ស្វាយ ខ្នុរ ដំឡូងមី ធ្វើស្រែ និងដាំផ្សេងៗទៀត រហូតមកដល់ពេលបច្ចុប្បន្ន។ ដោយការអាស្រ័យផលរបស់ពលរដ្ឋកន្លងមក គឺមិនធ្លាប់មានបញ្ហាអ្វីនោះទេ ទើបតែនៅដើមខែមីនា ឆ្នាំ២០២២នេះ អាជ្ញាធរខេត្តព្រះវិហារ និងក្រុមហ៊ុន បានដាក់គ្រឿងចក្រឈូសឆាយផ្ទះពលរដ្ឋអស់ប្រហែល៦០ខ្នង និងផលដំណាំប្រហែល៤៥០ហិកតា។ លើសពីអាជ្ញាធរបានគំរាមគំហែងចាប់ និងប្ដឹងប្រជាពលរដ្ឋទៅតុលាការ ប្រសិនបើពលរដ្ឋហ៊ានតវ៉ា និងថតរូបភាពអំពីសកម្មភាពឈូសឆាយនោះ ប៉ុន្តែអ្នកភូមិបានត្រៀមយកញ្ញត្តិទៅដាក់នៅរដ្ឋបាលខេត្តព្រះវិហារជាថ្មីទៀត នៅសប្តាហ៍ក្រោយ ដើម្បីសុំឱ្យអភិបាលខេត្តថ្មី ជួយដោះស្រាយក្រោយគ្មានដំណោះស្រាយពីអភិបាលខេត្តចាស់ លោក ប្រាក់ សុវណ្ណនោះ។ ពលរដ្ឋម្នាក់ទៀតដែលមានវិវាទទាក់ទងទៅនឹងករណីដែលដូចទៅនឹងករណីខាងលើនេះបានបន្តទៀតថា នៅភូមិព្យូជ្រូក ឃុំគូលេន លោក ផេង ផល មានប្រសាសន៍ថា ពលរដ្ឋប្រមាណ១៣០គ្រួសារ នៅឃុំគូលែន មានជម្លោះដីធ្លីរ៉ាំរ៉ៃដូចពលរដ្ឋនៅភូមិខាងលើដែរ តែដោយវិវាទនេះកើតឡើងរវាងពលរដ្ឋជាមួយក្រុមហ៊ុន "គ" តាំងពីឆ្នាំ២០១៣ រហូតមកដល់បច្ចុប្បន្ន នៅមិនទាន់មានដំណោះស្រាយនៅឡើយ។ លោកថា ក្រុមហ៊ុននេះទទួលបានដីសម្បទានសេដ្ឋកិច្ចពីរដ្ឋាភិបាលកាលពីឆ្នាំ២០១២ ខណៈពលរដ្ឋបានចូលទៅអាស្រ័យផលលើដីនោះតាំងពីឆ្នាំ២០០០មកម្ល៉េះ ដោយគ្រួសារមានដីចន្លោះពី៣ទៅ៦ហិកតាប៉ុណ្ណោះ។ ប៉ុន្តែនៅជុំវិញជម្លោះដីក្នុងករណីទាំងពីរនេះ មន្ត្រីសម្របសម្រួលគម្រោងធុរកិច្ច និងសិទ្ធិមនុស្ស នៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា លោក វណ្ណ សុផាត ធ្លាប់មានប្រសាសន៍ថា អាជ្ញាធរ និងភាគីក្រុមហ៊ុន ហាក់មិនបានព្យាយាមសម្របសម្រួលដោះស្រាយតាមនីតិវិធីជូនពលរដ្ឋទេ គឺតែងតែប្រើប្រាស់កម្លាំង និងប្រព័ន្ធតុលាការប្ដឹងប្រឆាំងពលរដ្ឋ ដើម្បីបង្ក្រាប និងបំបាក់ស្មារតី កុំឱ្យហ៊ានតវ៉ាបន្តទៀត។

### ១.៣.២.ការផ្ទេរសិទ្ធិដោយមិនស្របច្បាប់

នៅពេលដែលមានការលក់ ទិញដីធ្លីមួយកើតឡើងរវាងភាគីអ្នកលក់ និងភាគីអ្នកទិញនោះ ដែលកម្មវត្ថុជាដីធ្លីដែលយើងហៅថា ការលក់អចលនវត្ថុ។ ការលក់អចលនវត្ថុ គឺជាកិច្ចសន្យាដែលអនុញ្ញាតឱ្យផ្ទេរសិទ្ធិជាកម្មសិទ្ធិនៃអចលនវត្ថុពីការអ្នកលក់ទៅឱ្យអ្នកទិញ ដោយអ្នកទិញត្រូវមានកាតព្វកិច្ចបង់ថ្លៃទៅលើអចលនវត្ថុដែលខ្លួនបានទិញនោះឱ្យអ្នកលក់[17] ហើយអ្នកលក់ត្រូវមានកាតព្វកិច្ចប្រគល់អចលនវត្ថុទៅឱ្យអ្នកទិញ។ ការផ្ទេរសិទ្ធិនេះមិនអាចជំទាស់បានពីតតិយជន លុះត្រាតែកិច្ចសន្យាលក់អចលនវត្ថុនេះត្រូវបានធ្វើជាលាយលក្ខណ៍អក្សរ ឬតាមទម្រង់លិខិយថាភូត ដោយអាជ្ញាធរមានសមត្ថកិច្ច ហើយត្រូវបានចុះបញ្ជីនៅអង្គភាពសុរិយោដីច្បាស់លាស់។ ចំពោះកិច្ចសន្យាលក់ដែល ភាគីទាំងពីរធ្វើឡើងដោយឯកឯងដោយគ្មានការដឹងលឺ ឬសមស្របតាមការកំណត់របស់ច្បាប់បានគ្រប់លក្ខខណ្ឌនោះទេ កិច្ចសន្យាលក់មួយនោះមិនអាចចាត់ទុកថា ជាការផ្ទេរកម្មសិទ្ធិទ្រព្យនោះបានឡើយ។ដូចនេះ ការផ្ទេរកម្មសិទ្ធិតាមលក្ខណៈច្បាប់ និងតតិយជនជំទាស់លែងបាន គឺនៅពេលដែលកិច្ចសន្យាលក់ត្រូវបានធ្វើជាលាយលក្ខណ៍អក្សរតាមទម្រង់លិខិតយថាភូត និងត្រូវបានចុះបញ្ជីនៅអង្គភាពសុរិយោដី។

គេសង្កេតឃើញថា ការអនុវត្តជាក់ស្តែង ភាគច្រើនការលក់ទិញទៅលើប្រភេទអចលនវត្ថុនៅក្នុងព្រះរាជាណាចក្រកម្ពុជា គឺមិនត្រូវបានគេគោរពតាមគោលការណ៍ដែលមានចែងក្នុងច្បាប់ភូមិបាលនោះទេ ពោលគឺមិនបានធ្វើជាលាយលក្ខណ៍អក្សរតាមទម្រង់យថាភូតនៅចំពោះអាជ្ញាធរមានសមត្ថកិច្ច និងមិនបានចុះបញ្ជីនៅក្នុងអង្គភាពសុរិយោដី។ ការដែលពួកគាត់ធ្វើបែបនេះក៏ព្រោះតែពួកគាត់មិនចង់ចំណាយប្រាក់ទៅលើការបង់ពន្ធដែលមានថ្លៃប្រថាប់ត្រា ការរង់ចាំមានរយៈពេល និងការចំណាយទៅលើអ្វីផ្សេងៗទៀត។ ការដែលពួកគាត់នាំគ្នាធ្វើបែបនេះហើយដែលជាមូលហេតុនៃការបង្កឱ្យមានជម្លោះកើតឡើងនៅពេលក្រោយទៀត។

រាជរដ្ឋាភិបាលក៏បានយកចិត្តទុកចំពោះបញ្ហាដែលប្រជាពលរដ្ឋកំពុងជួបប្រទះដែរ។ ដោយរាជរដ្ឋាភិបាលនៅតែបន្តការអនុវត្តគោលនយោបាយមិនយកពន្ធលើដីធ្លីកសិកម្មរបស់កសិករ ដែលបង្កបង្កើនផលលក្ខណៈគ្រួសារក៏ដោយ ក៏ប៉ុន្តែក្នុងគោលបំណងដើម្បីទប់ស្កាត់ការទិញដីទុកឡើងថ្លៃកេងប្រវញ្ចយកចំណេញហួសហេតុ ដោយគ្មានការអភិវឌ្ឍនឹងធ្វើឱ្យរដ្ឋបាត់បង់ចំណូលជាតិ។ ការអនុវត្តច្បាប់ជាកត្តាសំខាន់ណាស់ បើរដ្ឋអនុវត្តច្បាប់នោះដីមិនប្រើប្រាស់ជាច្រើនដែលបានបង់ពន្ធនឹងត្រូវក្លាយជាទ្រព្យសម្បត្តិរបស់រដ្ឋ។ អចលនវត្ថុនោះមិនត្រឹមតែជាទ្រព្យសម្បត្តិរបស់រដ្ឋប៉ុណ្ណោះទេ ម្ចាស់ដីនឹងត្រូវទទួលរងនូវបទល្មើសព្រហ្មទណ្ឌទាក់ទងនឹងការប្រព្រឹត្តអំពើ គេចវេសពន្ធ

[17] មាត្រា៦៤ នៃច្បាប់ភូមិបាលឆ្នាំ២០០១ និងមាត្រា៥១៥ នៃក្រមរដ្ឋប្បវេណី២០០៧

និងត្រូវរងការផ្តន្ទាទោសពិន័យជាប្រាក់ពី ១០,០០០,០០០ រៀល (ដប់លានរៀល) ដល់ ២០,០០០,០០០ (ម្ភៃលានរៀល) ឬជាប់ពន្ធធានាគារពី ១ឆ្នាំ ដល់៥ឆ្នាំ ឬត្រូវទទួលទាំងពីរនោះ[18]។

ជាក់ស្តែង ការលក់ច្រើនតែធ្វើនៅចំពោះមុខប្រធានភូមិ ឬមេឃុំ ហើយកម្រធ្វើនៅចំពោះមុខ សមត្ថកិច្ចមន្ត្រីសុរិយោដីណាស់។ ការលក់ដូរដីធ្លី ដែលច្រើនតែត្រូវបានធ្វើឡើងនៅរដ្ឋបាលដែលមានកម្រិតទាប តាមរយៈការប្តូរឈ្មោះលើចុងសន្លឹកសុំកាន់កាប់ដីធ្លី ឬក៏ការធ្វើកិច្ចសន្យាជាលាយលក្ខណ៍អក្សរអម រវាងអ្នកទិញ និងអ្នកលក់បែបនេះ គឺមិនស្របតាមច្បាប់បានឡើយ។ ការអនុវត្តបែបនេះ ហើយក៏ធ្វើឱ្យគេអាចលក់អចលនវត្ថុតែមួយទៅឱ្យអ្នកទិញច្រើនបន្តបន្ទាប់គ្នាបាន។

### ១.៣.៣.ការរំលោភ និងការចាប់ដីខុសច្បាប់

- **ការរំលោភយកដីដោយខុសច្បាប់**

ការរំលោភយកដីធ្លីតែងតែមានកើតឡើងមានជាញឹកញាប់ និងជាបញ្ហាធ្ងន់ធ្ងរដែលប្រទេសកម្ពុជាជួបប្រទះនាពេលបច្ចុប្បន្ន។ ករណីទាំងនេះច្រើនតែជាប់ពាក់ព័ន្ធនឹងបុគ្គលឯកជន ឬក្រុមហ៊ុនមកពីក្រៅសហគមន៍ ឬមន្ត្រីយោធា និងអាជ្ញាធរមានឋានៈខ្ពស់[19]។ ការរំលោភយកដីធ្លី អាចកើតមានក្រោមរូបភាពជាច្រើន ផ្សេងៗគ្នាទៅតាមករណីវិវាទនីមួយៗ។ ការរំលោភយកដីធ្លីជាច្រើនតែងតែកើតមានកសិកម្មផ្លាស់ទី។ ការណ៍នេះដោយសារដីរបស់រដ្ឋភាគច្រើនមិនទាន់បានធ្វើអត្តសញ្ញាណកម្មឱ្យបានច្បាស់លាស់មិនថា ដីឯកជនរបស់រដ្ឋ ឬដីសាធារណៈរបស់ភាគច្រើនមិនបានចុះបញ្ជីតាមលក្ខណៈបច្ចេកទេស ឱ្យបានត្រឹមត្រូវតាមការកំណត់ដែលមានចែងនៅក្នុងច្បាប់នៅឡើយនោះទេ។ ដីប្រភេទនេះត្រូវបានទុកចោលទំនេរ ប៉ុន្តែនៅមូលដ្ឋានដែលគេទទួលស្គាល់ថា វាជាទ្រព្យសម្បត្តិរបស់កសិករ និងសហគមន៍របស់ពួកគេ។ ប៉ុន្តែចំពោះអ្នកមកពីខាងក្រៅដីទុកចោលទំនេរគ្មានផលិតផលបែបនេះ គេគិតថាអាចចំណេញយកបាន។ ការរំលោភយកដីអាចកើតមានឡើងផងដែរ នៅលើដីដែលអ្នកស្រុកកំពុងប្រើប្រាស់ជាក់ស្តែង ប៉ុន្តែគ្មានប័ណ្ណបញ្ជាក់ពីសិទ្ធិស្របច្បាប់ពីសិទ្ធិស្របតាមច្បាប់ការកំណត់ដែលមានចែងនៅក្នុងច្បាប់របស់ខ្លួន។

ឧទាហរណ៍ ៖ មានករណីរំលោភយកដីធ្លីរបស់ប្រជាពលរដ្ឋនៅក្នុងខេត្តព្រៃវែង បើតាមព័ត៌មានរបស់ RFA នៅថ្ងៃទី២៣ ខែមិនា ឆ្នាំ២០០៩ បានដកស្រង់ពាក្យសំដីរបស់ប្រជាពលរដ្ឋដែលបានតវ៉ាពីការរំលោភយកដីរបស់ពួកគាត់ដូច្នេះថា៖ ដីរបស់ពួកគាត់ ដែលពួកគាត់បានកាន់កាប់ជាង២០ឆ្នាំមកហើយ ស្រាប់តែមន្ត្រីនគរបាល និង

[18] ព្រះរាជក្រមលេខ នស រកម០២៩៧.០៣ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៧ ស្តីពី សារពើព័ន្ធ៖ មាត្រា១៣៥

[19] អនុក្រឹត្យលេខ៤៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី៖ មាត្រា១០

អាជ្ញាធរបានមកបង្ខំឱ្យពួកគាត់ផ្តិតមេដៃប្រគល់ដី ដែលជាកម្មសិទ្ធិរបស់ពួកគាត់កាន់កាប់តាំងពីយូរមកហើយនេះដើម្បីប្រគល់ដីនេះទៅឱ្យពួកគេ។

ករណីមួយចំនួនកើតឡើងរវាងអាជ្ញាធរមានឋានៈខ្ពស់ និងអ្នកមានទ្រព្យសម្បត្តិ ច្រើនតែប្រើឥទ្ធិពលរបស់ខ្លួនទៅធ្វើបាបប្រជាពលរដ្ឋក្រីក្រ ដែលពួកគាត់ជាប្រជាពលរដ្ឋទន់ខ្សោយគ្មានសមត្ថភាពក្នុងការតវ៉ានោះ។ ហើយមិនតែប៉ុណ្ណោះបុគ្គលទាំងនេះក៏បានប្រើឥទ្ធិពលដោយទាក់ទងឃុបឃិតជាមួយអាជ្ញាធរភូមិ ឃុំ ដើម្បីសម្រួលឯកសារឱ្យស្របតាមច្បាប់ ដែលនាំឱ្យមានការលំបាកក្នុងការដោះស្រាយវិវាទដីធ្លីនៅក្នុងប្រព័ន្ធតុលាការ។ នៅក្នុងករណីខ្លះដីទាំងនោះភាគច្រើនត្រូវបានជនឆ្លៀតឱកាសមួយចំនួននាំគ្នាចូលធ្វើការកាន់កាប់យ៉ាងស្ញប់ស្ញាត់ ហាក់ដូចជាពួកគេប្រើប្រាស់លិខិត ឬឯកសារក្លែងក្លាយក្នុងដៃដែលជាទន់ក្នុងការទទួលបានសិទ្ធិកាន់កាប់លើដីដែលបុគ្គលទាំងនោះ ចង់បានមកធ្វើជាកម្មសិទ្ធិរបស់ខ្លួនដោយមិនស្របច្បាប់។ ហេតុដូច្នេះហើយទើបធ្វើឱ្យប្រជាពលរដ្ឋមួយចំនួនបាត់បង់ដីដែលជាកម្មសិទ្ធិរបស់គាត់ក្នុងការស្នាក់អាស្រ័យ និងការប្រកបរបរចិញ្ចឹមជីវិតរបស់ពួកគាត់ ដោយសារតែពួកគាត់គ្មានសមត្ថភាពក្នុងការតវ៉ា ព្រោះវាត្រូវការចំណាយលុយច្រើន និងពេលវេលាច្រើន ជាពិសេសពួកគាត់ដឹងថាពួកគាត់គ្មានសង្ឃឹមថានឹងតវ៉ាឈ្នះក្នុងរឿងក្តីនោះទេ ដូច្នេះហើយពួកគាត់បង្ខំចិត្តប្រគល់ដីនោះទៅឱ្យទៅបុគ្គលទាំងនោះដោយគ្មានលាក់ខណ្ឌ។

ចាប់តាំងពីឆ្នាំ ១៩៩២ នៅពេលដែលប្រទេសកម្ពុជាបានយកចិត្តទុកដាក់អនុវត្តច្បាប់ និងបទបញ្ញានានា ដោយក្រុមប្រឹក្សារដ្ឋមន្ត្រីបានទទួលស្គាល់ថា ពិតជាមានជនល្មើសមួយចំនួនកំពុងតែរំលោភចូលទៅបោះបង្គោល ឬធ្វើសំណង់នៅលើដីសាធារណៈរបស់រដ្ឋ ហើយពួកក្រុមទុច្ចរិតទាំងនោះសុទ្ធសឹងតែមានលំនៅឋានត្រឹមត្រូវរួចទៅហើយ តែពួកគេនៅតែចង់បានរបស់ដែលមិនមានជាកម្មសិទ្ធិរបស់ខ្លួនយកមកកាន់កាប់បន្ថែមទៀតដោយមិនបានគិតថា អំពីរបស់ខ្លួនកំពុងតែធ្វើត្រឹមត្រូវតាមច្បាប់កំណត់ឬអត់ទេ។ ភាពអនាធិបតេយ្យក្នុងការកាន់កាប់ដីដោយខុសច្បាប់ និងការរំលោភយកដីដែលជាកម្មសិទ្ធិរបស់រដ្ឋមកធ្វើជាកម្មសិទ្ធិឯកជននោះ គឺនៅតែមានជារឿយៗនៅឡើយ ហាក់ដូចជាមានការចាត់តាំងពីមេដឹកនាំត្រឹមត្រូវ ដើម្បីធ្វើជាមុខរបររកស៊ី។ ម្យ៉ាងទៀតថ្វីបើភោគៈត្រូវបានបញ្ចប់[20] ដោយច្បាប់ភូមិបាលឆ្នាំ ២០០១ ប៉ុន្តែនៅតែមានប្រជាពលរដ្ឋបន្តធ្វើការរំលោភយកដីនៅឡើយ។ ទង្វើបែបនេះច្រើនតែកើតចេញឡើយពីពួកឈ្មួញ និងបុគ្គលមានអំណាចដែលប្រមូលផ្តុំដីធ្លី ដើម្បីបង្កើនប្រាក់ចំណូល និងពង្រីកឥទ្ធិពលអំណាចរបស់ខ្លួនកាន់តែធំជាងមុន ដោយមិនខ្វល់ថាអ្នកណាខ្លះត្រូវទទួលរងផលប៉ះពាល់នោះឡើយ សំខាន់ឱ្យតែជាតម្រូវការរបស់ខ្លួន គឺត្រូវធ្វើទាំងអស់។

[20]ព្រះរាជក្រមលេខ នស រកម ០៨០១១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ស្តីពីច្បាប់ភូមិបាលៈ មាត្រា២៩

- **ការចាប់យកដីធ្លីដោយខុសច្បាប់**

ការចាប់យកដីធ្លីដោយខុសច្បាប់ គឺច្រើនតែមានឡើងចំពោះប្រជាពលរដ្ឋក្រីក្រដែលជាកម្មសិទ្ធិរបស់រដ្ឋ ឬដីរបស់ក្រុមហ៊ុនឯកជនពាណិជ្ជកម្មធំៗ ដោយសារតែពួកគាត់គ្មានដីសម្រាប់ការស្នាក់អាស្រ័យ ព្រោះពួកគាត់គ្មានលំនៅឋានពិតប្រាកដ ដោយមានបញ្ហាជីវភាពលំបាកខ្លាំងទើបធ្វើឱ្យពួកគាត់ប្រមូលផ្តុំគ្នាដើររកដីលំនៅឋាន នៅតំបន់ដែលអាចរកចំណូលបានច្រើនជាងមុន ដែលជាហេតុនាំឱ្យពួកគាត់បង្ខំចិត្តចាប់យកដីរបស់រដ្ឋ។ ប៉ុន្តែប្រជាពលរដ្ឋមួយចំនួនពួកគាត់មិនត្រឹមតែចង់បានដីនោះមកស្នាក់នៅបណ្តោះអាសន្នប៉ុណ្ណោះទេ តែពួកគាត់ចង់បានដីនោះមកធ្វើជាកម្មសិទ្ធិរបស់ខ្លួនថែមទៀត នៅដែលពួកគាត់បានអះអាងថាដីមួយកន្លែងនឹងជាដីរបស់ខ្លួន ដោយសារតែមានការលើកឡើងបែបនេះ ហើយទើបធ្វើឱ្យការចាប់យកដីរបស់រដ្ឋ នៅតែជាបញ្ហាក្នុងការរកដំណោះស្រាយដដែល។

កន្លងមក ដីរដ្ឋ ទាំងដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋភាគច្រើនមិនទាន់បានធ្វើអត្តសញ្ញាណកម្មធ្វើផែនទីកំណត់ទីតាំង និងព្រំប្រទល់ច្បាស់លាស់ ធ្វើចំណាត់ថ្នាក់ និងការចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីធ្លីនៅឡើយ ដែលនាំឱ្យអាជ្ញាធរគ្រប់ជាន់ថ្នាក់ប្រឈមនិងការលំបាកក្នុងការគ្រប់គ្រង ដូចជាការទប់ស្កាត់ ការទន្ទ្រានកាន់កាប់ដីរដ្ឋដោយខុសច្បាប់ជាដើម។

ការចូលកាន់កាប់ដីតាមរូបភាពភោគៈ ត្រូវបានបញ្ចប់បន្ទាប់ពីច្បាប់ភូមិបាលឆ្នាំ២០០១ ចូលជាធរមាន ក្នុងពេលដែល រដ្ឋមិនទាន់បានអនុវត្តទូលំទូលាយនៅឡើយនូវកម្មវិធីសម្បទានដីសង្គមកិច្ច សម្រាប់ជនក្រីក្រ និងងាយរងគ្រោះ ដើម្បីដោះស្រាយសេចក្តីត្រូវការដីរបស់ប្រជាពលរដ្ឋ ដែលចេះតែកើនឡើងជារៀងរាល់ថ្ងៃ ដោយសារកំណើនប្រជាជន ការរំសាយកងទ័ព ការបាត់បង់ដីដោយសារគ្រោះធម្មជាតិជាដើម ដែលជាហេតុនាំឱ្យមានការចូលកាន់កាប់ដីរដ្ឋ ដោយអនាធិបតេយ្យ។ ទន្ទឹមនេះ ក៏មានជនឆ្លៀតឱកាស ពួកឈ្មួញដី និងអ្នកមានអំណាចមួយចំនួនបានចូលកាន់កាប់ដីរដ្ឋដោយខុសច្បាប់តាមរូបភាពផ្សេងៗ។

ម្យ៉ាងវិញទៀតការទន្ទ្រានយកដីដោយខុសច្បាប់ ក៏កើតមានឡើងទៅលើតំបន់ការពារធម្មជាតិ ចំនួន២៦ តំបន់ដែលស្ថិតនៅក្រោមការគ្រប់គ្រង និងទទួលខុសត្រូវដោយក្រសួងបរិស្ថាន ដោយមានការគំរាមគំហែងដល់ជីវចម្រុះ និងព្រៃឈើការពារជម្រកសត្វព្រៃទៀតផង។ ការទន្ទ្រានដែលធ្វើឡើងពីសំណាក់ប្រជាពលរដ្ឋ ក្រុមហ៊ុនរុករករ៉ែ និងអាជ្ញាធរដែលមានឋានៈខ្ពស់ ដោយមានកងកម្លាំងប្រដាប់អាវុធជាបង្អែក ទើបធ្វើឱ្យពួកគាត់ហានប្រព្រឹត្តអំពីខុសច្បាប់បែបនេះ ដោយពួកគាត់មិនបានគិតអំពីផលប៉ះពាល់ទៅថ្ងៃក្រោយអំពីបទល្មើសដែលគាត់បានកំពុងធ្វើនេះឡើយ។

ឧទាហរណ៍៖ ជាក់ស្តែងមានករណីមួយបានកើតនៅខេត្តព្រះសីហនុ យោងតាមប្រភពព័ត៌មានភ្នំពេញប៉ុស្តិ៍ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២២ បានចុះផ្សាយទាក់ទងនឹងសាលាដំបូងខេត្តព្រះសីហនុ នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ ២០២២ បានចេញដីកាឃុំខ្លួនមេខ្យល់ ចំនួន ០៦ នាក់ និង ០៦នាក់ ទៀតស្ថិតក្នុងការត្រួតពិនិត្យរបស់តុលាការ ក្រោយពីពួកគេដឹកនាំប្រជាពលរដ្ឋជិត ៣០០នាក់ ទៅទន្ទ្រានកាន់កាប់ដីរដ្ឋ ក្នុងដែនឧទ្យានជាតិជួរភ្នំក្រវាញខាងត្បូង ស្ថិតនៅគីឡូ១៥ ភូមិចាំ ឃុំពង់សីលា ស្រុកកំពង់សីលា ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៣ ខែមីនា ឆ្នាំ ២០២២ ។

លោក សាមុត សុធារិទ្ធិ ប្រធានមន្ទីរបរិស្ថានខេត្តព្រះសីហនុ ប្រាប់ភ្នំពេញ-ប៉ុស្តិ៍ នៅថ្ងៃទី២០ ខែមីនា ឆ្នាំ ២០២២ ក្រោយពីសមត្ថកិច្ចខេត្តព្រះសីហនុ បានចុះទៅបង្ក្រាបករណីក្រុមអនាធិបតេយ្យ ប្រមាណជា២៩៥នាក់ ក្នុងនោះស្រី១១៣នាក់ ចូលទន្ទ្រានកាន់កាប់ដីរដ្ឋស្ថិតនៅចំណុចគីឡូ១៥ ភូមិចាំ ឃុំពង់សីលា ស្រុកកំពង់សីលា ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២២ មកទល់បច្ចុប្បន្ន មន្ត្រីនគរបាលយុត្តិធម៌នៃមន្ទីរបរិស្ថានខេត្តព្រះសីហនុបានកសាងសំណុំរឿងបញ្ជូនជនសង្ស័យចំនួន ១២នាក់ ទៅសាលាដំបូងខេត្តព្រះសីហនុ ពាក់ព័ន្ធនឹងករណីចូលទន្ទ្រានកាន់កាប់ដីរដ្ឋនេះ។

សេចក្តីប្រកាសព័ត៌មានរបស់មន្ទីរបរិស្ថានខេត្តព្រះសីហនុ កាលពីថ្ងៃទី២០ ខែមីនា ឆ្នាំ២០២២ បានឲ្យដឹងថាឧទ្យានជាតិជួរភ្នំក្រវ៉ាញខាងត្បូង ត្រូវបានបង្កើតឡើងដោយ អនុក្រឹត្យលេខ៨៩ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ ២០១៦ ដែលជាប់ព្រំប្រទល់រវាងភូមិសាស្ត្រខេត្តកោះកុង ខេត្តព្រះសីហនុ ខេត្តពោធិ៍សាត់ និងខេត្តកំពង់ស្ពឺ ដើម្បីធានាកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព។ កន្លងមកសកម្មភាពបទល្មើសរុករានកាប់ឆ្ការព្រៃដាំដំណាំ សង់ខ្ទម និងបោះបង្គោលរបងហ៊ុមព័ទ្ធកាន់កាប់ជាកម្មសិទ្ធិដោយខុសច្បាប់ ស្ថិតក្នុងតំបន់ឧទ្យានជាតិជួរភ្នំក្រវាញខាងត្បូងត្រូវបានសមត្ថកិច្ចចុះអនុវត្តវិធានការទប់ស្កាត់ជាបន្តបន្ទាប់ នេះបើតាមសេក្តីប្រកាសព័ត៌មាន។ សេចក្តីប្រកាសបញ្ជាក់ថា យោងលើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ត្រង់មាត្រា៥៦ និងមាត្រា៦២ ដែលបានចែងថា បុគ្គលណាដែលធ្វើសកម្មភាពកាប់គាស់ រុករានព្រៃ ឆ្ការដុត និងឈូសឆាយដីព្រៃ ដើម្បីយកដីធ្វើជាកម្មសិទ្ធិ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគាពី៥ឆ្នាំ ទៅ១០ឆ្នាំ និងពិន័យជាប្រាក់ពី ១៥លានរៀល ទៅ១៥០លានរៀល។ ចំពោះបុគ្គលប្រព្រឹត្តជានីតិបុគ្គល នឹងត្រូវពិន័យជាប្រាក់ពី ១៥០ លានរៀល ទៅ ២៥០លានរៀល។ វត្ថុតាងត្រូវរឹបអូសជាសម្បត្តិរដ្ឋ ក្នុងករណីមិនរាងចាលត្រូវផ្តន្ទាទោសទ្វេរដង។

## ១.៣.៤.កត្តាកើតចេញពីប្រជាពលរដ្ឋ

ការដែលបណ្តាលឱ្យមានវិវាទដីធ្លី ដែលជាមូលហេតុកើតចេញពីប្រជាពលរដ្ឋ សំដៅទៅលើសកម្មភាពរបស់ប្រជាពលរដ្ឋដែលបានចូលកាន់កាប់ដីរដ្ឋ និងដីធ្លីឯកជនដោយខុសច្បាប់។ ហើយមូលហេតុដែលជំរុញឱ្យមានការទន្ទ្រានកាន់កាប់ដីធ្លីទាំងអស់នេះមានដូចជា ភាពក្រីក្រ និងមូលហេតុមួយចំនួនដូចជាចំណេះដឹងរបស់ពួកគាត់នូវមានកម្រិតនៅឡើយជាដើម។ គួរបញ្ជាក់ផងដែរ ទាក់ទងនឹងបញ្ហាការកាន់កាប់ដីធ្លីរបស់រដ្ឋដោយខុសច្បាប់នេះដូចដែលបានរៀបរាប់នូវចំណុចខាងលើនេះរួចហើយ ដែលសកម្មភាពនៃការចូលកាន់កាប់ដីធ្លីរដ្ឋជាបញ្ហាប្រឈមដែលគួរឱ្យកត់សម្គាល់។ដូចនេះការបង្ហាញនេះអាចបញ្ជាក់បានថា ភាពក្រីក្រ និងគ្មានដីធ្លីអាចជាមូលហេតុជំរុញឱ្យប្រជាពលរដ្ឋក្រីក្រដែលគ្មានដីធ្លីនោះ បានធ្វើឱ្យពួកគាត់ចូលកាន់កាប់ដីដោយខុសច្បាប់ និងរួមផ្សំនឹងការធ្វេសប្រហែសក្នុងការគ្រប់គ្រងដីធ្លី ឬអាចនិយាយបានថា វិវាទមួយផ្នែកបានកើតចេញពីអាជ្ញាធរផងដែរ។

ឧទាហរណ៍៖ ជាក់ស្តែងមានករណីវិវាទមួយកើតនៅខេត្តឧត្តរមានជ័យ ដោយយោងតាមប្រភពព័ត៌មានភ្នំពេញប៉ុស្តិ៍ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ បានចុះផ្សាយទាក់ទងជាមួយពលរដ្ឋ១គ្រួសារបានស្ម័គ្រចិត្តប្រគល់ដីចំនួន ១៦ហិកតា ដែលស្ថិតនៅភូមិបន្ទាយជ័រ ឃុំពង្រ ស្រុកចុងកាល ខេត្តឧត្តរមានជ័យ ជូនរដ្ឋវិញ ដើម្បីបញ្ចៀសពីវិធានការច្បាប់ ខណៈមន្ត្រីជំនាញរដ្ឋបាលព្រៃឈើអះអាងថា អ្នកពាក់ព័ន្ធផ្សេងទៀតដែលមិនចូលខ្លួនមកធ្វើកិច្ចសន្យាបញ្ឈប់កាន់កាប់អាស្រ័យផលលើដីរដ្ឋ ត្រូវបញ្ជូនសំណុំរឿងទៅតុលាការចាត់ការតាមច្បាប់។ ប៉ុន្តែ លោក អ៊ឹង សៅរិទ្ធ នាយកខណ្ឌរដ្ឋបាលព្រៃឈើខេត្តឧត្តរមានជ័យបានឱ្យដឹងនៅថ្ងៃទី២៦ ខែធ្នូថា ពលរដ្ឋ១គ្រួសារ ដែលបានទន្ទ្រានចូលដាំដុះអាស្រ័យផលលើដីស្ថានីយផ្សព្វផ្សាយ និងស្ថានីយស្តារព្រៃឈើពង្រចុងកាល់បានស្ម័គ្រចិត្តប្រគល់ដីជូនរដ្ឋវិញ កាលពីថ្ងៃទី២៣ ខែធ្នូ ដើម្បីកុំឱ្យពាក់ព័ន្ធនឹងផ្លូវច្បាប់នោះ។

លោកបានបន្តថា ចំពោះអ្នកពាក់ព័ន្ធទាំងនោះ មន្ត្រីជំនាញបានបញ្ជូនសំណុំរឿងទៅតុលាការ ដើម្បីចាត់ការតាមច្បាប់ ប៉ុន្តែបើពលរដ្ឋស្ម័គ្រចិត្តធ្វើកិច្ចសន្យាឈប់ប្រើប្រាស់ដីរដ្ឋនោះ មន្ត្រីជំនាញអាចស្នើសុំដកឈ្មោះចេញវិញដើម្បីកុំឱ្យមានជាប់ក្នុងចំណាត់ការណាមួយ។ លោកថា៖ " យើងមានចំណាត់ការហើយ គឺយើងអត់មានត្រូវផ្សព្វផ្សាយអីទៀតទេ ប៉ុន្តែបើគាត់ភ្ញាក់រឭកមកធ្វើពលរដ្ឋចូលខ្លួនកាលពីថ្ងៃមុនគឺយើងអាចនឹងស្នើសុំទៅថ្នាក់ដឹកនាំ ដើម្បីស្នើសុំដកឈ្មោះពួកគាត់ចេញពីចំណាត់ការផ្សេងៗ " ។

កាលពីថ្ងៃទី២៦ ខែធ្នូ បើយោងតាមកិច្ចសន្យារបស់ពលរដ្ឋឈ្មោះ "ក" និងប្រពន្ធ "ខ" រស់នៅភូមិបន្ទាយថ្មី ឃុំចុងកាល់ ស្រុកចុងកាល់ ខេត្តឧត្តរមានជ័យ បានឱ្យដឹងថា ក្រុមគ្រួសាររបស់គាត់បានចូលទៅអាស្រ័យផល

លើដីកម្មសិទ្ធិរបស់រដ្ឋ ដោយសារតែចាញ់បោកក្រុមជនខិលខូចដោយទិញលក់តែគ្នាឯងខាតបង់ពេលវេលា និងទ្រព្យសម្បត្តិជាច្រើន។ ប៉ុន្តែលោក មេឃុំពង្រ បានប្រាប់ថា៖ មានពលរដ្ឋ៦០គ្រួសារបានចូលទៅអាស្រ័យផលនៅទីតាំងដី បើគិតជាផ្ទៃដីមានប្រមាណជាង ១០០ហិកតា ដោយក្នុងនោះធ្វើទៅបាន។ លោកថា ពលរដ្ឋខ្លះបានអាស្រ័យផលរយៈពេល ២ឆ្នាំ និងខ្លះទៀតបានប្រមាណ ៣ឆ្នាំ នៅលើទីតាំងនោះ។

## ១.៣.៥.ការចុះបញ្ជី និងដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិមិនគ្រប់គ្រាន់

មានរបបសិទ្ធិចំនួនពីរលើលើទ្រព្យសម្បត្តិឯកជន នៅក្រោមច្បាប់ភូមិបាលគឺ សិទ្ធិកម្មសិទ្ធិ និងសិទ្ធិភោគៈ។ ក្នុងករណីពុំមានប័ណ្ណរឹងភោគីមានសិទ្ធិលើដីធ្លីរបស់ខ្លួន ប្រសិនបើលក្ខន្តិកៈច្បាស់លាស់ត្រូវបានបំពេញ ភោគីនោះបានកាន់កាប់ដីនោះនៅមុនខែសីហា ឆ្នាំ២០០១ ហើយភោគៈនោះត្រូវបានកាន់កាប់ដោយពិតប្រាកដ គ្មានហិង្សា ដឹងឮជាសាធារណៈ គ្មានអាក់ខាន ឬដោយសុចរិត[21]។ ដីភោគៈនោះត្រូវចុះបញ្ជីនៅភ្នាក់ងាររដ្ឋាភិបាលថ្នាក់មូលដ្ឋាន មិនមែនចុះបញ្ជីនៅថ្នាក់ជាតិនោះទេ។ បុគ្គលឯកជនអាចទាមទារសិទ្ធិកាន់កាប់ដីធ្លីរបស់ខ្លួនដោយពេញលេញ ក្នុងករណីដីនោះបានត្រូវបានចុះបញ្ជីនៅថ្នាក់ជាតិ ហើយគណៈកម្មាធិការសុរិយោដីត្រូវចេញប័ណ្ណកម្មសិទ្ធិឱ្យត្រឹមត្រូវ។ ទោះបីជាដីឯកជនការការពារពីបណ្តាញចេញនោះក្តី ក្រុមហ៊ុនពាណិជ្ជកម្មដែលស្វែងរកដីវិនិយោគ កំពុងតែបង្កឱ្យមានបញ្ហាប្រឈមដល់ភូមិដែលពុំមានប័ណ្ណកម្មសិទ្ធិដីធ្លីសម្រាប់ទូទាំងប្រទេស។ បន្ថែមពីនេះ ម្ចាស់ដីដែលអាចនឹងក្លាយជាកម្មសិទ្ធិករភាគច្រើនពុំមានឯកសារណាមួយដែលពួកគេត្រូវការដើម្បីអាចទទួលបានប្លង់រឹងទាំងនោះទេ ហើយភាគីច្រើនពួកគាត់ពុំមានលទ្ធភាពក្នុងការចំណាយតម្លៃផ្សេងៗបន្ថែម ដើម្បីទទួលបានប្លង់រឹងនោះទេ ដែលទាំងអស់នេះហើយជាមូលហេតុបណ្តាលឱ្យមានវិវាទដីធ្លីកើតឡើង។

ជារួមដីមានសារសំខាន់ណាស់ដែលមិនថាទាំងមនុស្ស និងសត្វនោះទេ ពួកគេត្រូវការដីដោយខ្វះមិនបានឡើយ ហើយដីក៏ជាធាតុសំខាន់សម្រាប់ប្រជាពលរដ្ឋកម្ពុជាច្រើនជាង៨០% ពឹងអាស្រ័យទៅលើដីដើម្បីចិញ្ចឹមជីវិត។ ដោយសារដីជាកត្តាសំខាន់បែបនេះហើយ ដែលធ្វើឱ្យអ្នកណាក៏ចង់បានមកធ្វើជាកម្មសិទ្ធិគ្រប់គ្នានោះ ដែលជាហេតុធ្វើឱ្យវិវាទដីធ្លីនៅតែជាបញ្ហានៅកម្ពុជាដដែល។ ជាការពិតណាស់មូលហេតុដែលបណ្តាលឱ្យមានវិវាទដីធ្លីនោះ គឺដោយសារ កត្តានយោបាយ កត្តាសេដ្ឋកិច្ច កត្តាប្រវត្តិសាស្ត្រ កត្តាសង្គម និងការកង្វះចំណេះដឹងនូវច្បាប់ដែលពាក់ព័ន្ធទៅនឹងដីធ្លីជាដើម។ បញ្ហាមួយចំនួនទៀត គឺជាការកើនឡើងនូវតម្លៃដី ធ្វើឱ្យជនខិលខូចមួយចំនួនតូចឆ្លៀតឱកាសរំលោភយកដីធ្លី ខណៈដែលប្រជាពលរដ្ឋក្រីក្រគ្មានលទ្ធភាពធ្វើប័ណ្ណ ដើម្បីធានានូវសុវត្ថិភាពដីធ្លីរបស់ពួកគាត់បាន ទើបជាឱកាសនៃការឈ្លានពានរបស់ជនខិលខូចទាំងនោះ ហើយវិវាទដីធ្លីក៏កើនឡើងជា

[21] ច្បាប់ភូមិបាលឆ្នាំ២០០១ មាត្រា៣៨

បន្តបន្ទាប់ និងក្លាយជាបញ្ហាស្មុគស្មាញកាន់តែខ្លាំងឡើងពីមួយថ្ងៃទៅមួយថ្ងៃ។ ប៉ុន្តែបើផ្អែកតាមទិន្នន័យរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ វិវាទដីធ្លី ដែលកើតមាននូវឆ្នាំ២០០៣ មានចំនួន១,២៤៥ ករណី វាមានការកើនឡើងជាលំដាប់ប្រចាំឆ្នាំរហូតដល់ ៥,០៣៨ ករណី នៅឆ្នាំ២០០៨។ វិវាទដីធ្លីនេះអាចបង្កឱ្យមានកើតមានឡើងនូវអំពើហិង្សា បង្កជារបួសស្នាម និងអាចឈានទៅដល់ការកាប់សម្លាប់មនុស្សបន្ថែមទៀត ដោយសារតែភាពចង់បានរៀងៗខ្លួននេះឯង។

វិវាទដីធ្លីកើតឡើងជាច្រើនសណ្ឋាន វិវាទខ្លះកើតឡើងពាក់ព័ន្ធរវាង ប្រជាពលរដ្ឋនិងប្រជាពលរដ្ឋ ប្រជាពលរដ្ឋនិងក្រុមហ៊ុនឯកជន ហើយនិងប្រជាពលរដ្ឋនិងអាជ្ញាធរ។ ប្រជាពលរដ្ឋរាប់ពាន់គ្រួសាររងផលប៉ះពាល់ពីវិវាទដីធ្លី ដោយសារការផ្តល់ដីសម្បទានសេដ្ឋកិច្ច ដែលមិនមានការសិក្សាពីផលប៉ះពាល់ខាងសង្គមឱ្យបានត្រឹមត្រូវនិងល្អិតល្អន់។ ចំពោះការកាន់កាប់របស់ប្រជាពលរដ្ឋទៅលើដីដែលមានប័ណ្ណកាន់កាប់ដីធ្លីស្របច្បាប់មានត្រឹមតែ២០%តែប៉ុណ្ណោះ ដែលហេតុនាំឱ្យជនពុករលួយមួយចំនួនមានការឃុបឃិតគ្នាក៏បង្កឱ្យមានវិវាទដីធ្លីនោះ កើតមានឡើងមិនចេះចប់ មកពីដីធ្លីជាប្រភពចម្បងនៃអំណាច ទ្រព្យសម្បត្តិ និងក៏នាំមកនូវជម្លោះផងដែរ។

ឧទាហរណ៍៖ ជាក់ស្តែងមានករណីវិវាទមួយកើតឡើងនៅរាជធានីភ្នំពេញ ដោយយោងតាមប្រភពព័ត៌មាន VOD ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២២ បានចុះផ្សាយទាក់ទងនឹង ប្រជាពលរដ្ឋប្រមាណ៤០នាក់ តំណាងឱ្យជាង៨០គ្រួសារ រស់នៅសង្កាត់ជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញ បាននាំគ្នាទៅប្រមូលផ្តុំនៅមុខរដ្ឋបាលរាជធានីភ្នំពេញ ដើម្បីជំរុញដល់អាជ្ញាធរពន្លឿនការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីជូនពួកគាត់ ខណៈពួកគាត់បារម្ភពីការបណ្តេញចេញដោយបង្ខំ។ អ្នកស្រី "ក" ជាប្រជាពលរដ្ឋរស់នៅភូមិដូនឪ សង្កាត់ជើងឯក បានឱ្យដឹងថា ចាប់ពីឆ្នាំ២០២០មក ពួកគាត់បានដាក់លិខិតទៅរដ្ឋបាលរាជធានីភ្នំពេញ និងអាជ្ញាធរពាក់ព័ន្ធដើម្បីស្នើសុំប័ណ្ណកម្មសិទ្ធិដីធ្លី ប៉ុន្តែមកដល់ពេលនេះ ពួកគាត់នៅមិនទាន់ទទួលបានប័ណ្ណកម្មសិទ្ធិនៅឡើយទេ។ អ្នកស្រីបន្តថា ការដែលពួកគាត់ទៅប្រមូលផ្តុំនៅរដ្ឋបាលរាជធានីភ្នំពេញជាថ្មីទៀត គឺដើម្បីជំរុញជាថ្មីទៅអាជ្ញាធរឱ្យជួយពន្លឿនការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីដល់ពួកគាត់ ដោយសារតែបច្ចុប្បន្ន មានក្រុមហ៊ុនឯកជនបានទៅអភិវឌ្ឍចាក់ដីលុបបឹងនៅក្បែរៗតំបន់ដែលពួកគាត់រស់នៅធ្វើឱ្យពួកគាត់បារម្ភខ្លាចមានការបណ្តេញចេញទាំងបង្ខំនៅពេលខាងមុខនោះ។

## ជំពូកទី២

## យន្តការដោះស្រាយវិវាទដីធ្លី

ការដោះវិវាទដីធ្លី គឺផ្តោតសំខាន់ទៅលើដីថា តើដីនោះបានចុះបញ្ជី ឬមិនទាន់បានចុះបញ្ជី។ ចំពោះយន្តការបែបនេះតើយើងត្រូវប្រើយន្តការបែបណាខ្លះ ដើម្បីការពារនិងធានាសិទ្ធិដីធ្លីរបស់ប្រជាពលរដ្ឋឱ្យបានសមស្រប

តាមការកំណត់របស់ច្បាប់ និងជៀសវាងការកើតមានជម្លោះនោះ។ សិទ្ធិលើដីធ្លីគឺជាប្រធានបទដ៏ក្តៅគគុកនៅប្រទេសកម្ពុជា ដដែល។ ប៉ុន្តែរាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ទៅលើបញ្ហាគ្រប់គ្រងដីធ្លី ដើម្បីទប់ស្កាត់មិនឱ្យមានបាតុភាពសង្គមទាក់ទងនឹងបញ្ហាទាំងនេះដោយមានការបង្កើតជាលិខិតបទដ្ឋានគតិយុត្តជាច្រើន។ តែទោះបីជាមានលិខិតបទដ្ឋានគតិយុត្តជាច្រើនហើយក៏ដោយក៏វិវាទដីធ្លី នៅតែជាបញ្ហាចោទក្នុងការដោះស្រាយដដែល។ ការណ៍នេះ ដោយសារបទដ្ឋានទាំងនោះ និងនីតិវិធីពាក់ព័ន្ធក្នុងការគ្រប់គ្រង និងដោះស្រាយវិវាទនៅមានកម្រិត និងម្យ៉ាងភាពមិនច្បាស់លាស់នៃការកំណត់ដែនសមត្ថកិច្ច និងនីតិវិធីឱ្យមានការអនុវត្តកាន់តែចោទជាបញ្ហាថែមទៀត ហើយជួបការពិបាកផងដែរក្នុងកិច្ចប្រតិបត្តិការរបស់ខ្លួននោះ។

លើសពីនេះ យើងនូវស្វែងរកភាពខ្វះចន្លោះ និងការមិនស៊ីចង្វាក់គ្នារវាងច្បាប់ពាក់ព័ន្ធដែលកំណត់ដែនសមត្ថកិច្ច និងបញ្ហាជាច្រើនដែលត្រូវបានជួបប្រទះមានដូចជា ៖ ភាពមិនច្បាស់លាស់រវាងសមត្ថកិច្ចនៃគណៈកម្មការសុរិយោដីនឹងតុលាការ និងអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និងគណៈកម្មការសុរិយោដីជាដើម។ ប៉ុន្តែការវិភាគលំអិតទៅលើក្របខណ្ឌគតិយុត្ត និងភាពសមស្រប និងផ្ទុយគ្នាទៅនឹងច្បាប់រដ្ឋធម្មនុញ្ញកម្ពុជា លើបទដ្ឋានគតិយុត្តក្រោមច្បាប់មួយចំនួនពាក់ព័ន្ធដីធ្លី ដូចជាព្រះរាជក្រឹត្យស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី អនុក្រឹត្យស្តីពីគណៈកម្មការសុរិយោដី និងការប្រកាសអន្តរក្រសួង ដើម្បីរលេចឱ្យឃើញកាន់តែច្បាស់បន្ថែមទៀត។

ដោយសារកត្តាមនុស្ស តម្រូវការនៃភាពស្មើគ្នា យុត្តិធម៌ សិទ្ធិលើកម្មសិទ្ធិដែលចេះតែកើនឡើង និងរបត់សង្គម ព្រមទាំងនយោបាយពិភពលោកឈានទៅរកឯកជនភាពភាវូបនីយកម្ម ផ្នែកសេដ្ឋកិច្ច ពាណិជ្ជកម្ម ក៏ដូចជាទីផ្សារសេរី រដ្ឋាភិបាលកម្ពុជាក៏បានចាប់ផ្តើម កែប្រែ និងផ្តួចផ្តើមឱ្យមានសិទ្ធិលើកម្មសិទ្ធិជាបន្តបន្ទាប់ដោយសម្រេចបែងចែកកម្មសិទ្ធិដាច់ឱ្យគ្រួសារជាពលរដ្ឋកម្ពុជា លើលំនៅឋាន។ ជាពិសេសរាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់ខ្ពស់ក្នុងការគោរពនូវសិទ្ធិមនុស្ស ដែលបានផ្តោតសំខាន់លើសិទ្ធិឯកជនរបស់បងប្អូនប្រជាពលរដ្ឋ។

ជាក់ស្តែងនៅក្នុងអំឡុងឆ្នាំ ១៩៩២ កម្ពុជាបានអនុវត្តច្បាប់ភូមិបាលមួយ ដែលច្បាប់នេះបានបញ្ជាក់ពីការទទួលខុសត្រូវបាននូវសិទ្ធិកម្មសិទ្ធិនៅលើដីធ្លីតាមរយៈសន្តតិកម្ម កិច្ចសន្យា ឬដោយផ្លាស់ប្តូរពី **«ការកាន់កាប់បណ្តោះអាសន្ន»** ទៅជា **«កម្មសិទ្ធិពេញលេញ»** ជាដើម។ ក្រោយមកនៅឆ្នាំ២០០១ ច្បាប់ភូមិបាលដែលកំពុងប្រើប្រាស់បច្ចុប្បន្នត្រូវបានប្រកាសឱ្យប្រើ ដែលច្បាប់នេះអនុញ្ញាតឱ្យមានកម្មសិទ្ធិឯកជនលើដីធ្លីពេញលេញនៅកម្ពុជា ព្រមទាំងបានបង្កើតឱ្យមាននូវប្រព័ន្ធបញ្ជីឈ្មោះដីធ្លី និងមានប័ណ្ណកម្មសិទ្ធិដីធ្លីជូនប្រជាពលរដ្ឋ។ ដោយអនុលោមតាមការប្រកាសរបស់អន្តរក្រសួងលេខ ៤៧ អនក្រ.បក ដែលបានចុះនៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ ២០០២ ដែលក្នុងនោះរួមមានគណៈកម្មការសុរិយោដី ៣ថ្នាក់ គឺ គណៈកម្មការសុរិយោដីថ្នាក់ក្រុងស្រុក/ខណ្ឌ

គណៈកម្មការសុរិយោដីថ្នាក់រាជធានី/ខេត្ត និងគណៈកម្មការសុរិយោដីថ្នាក់ជាតិ។ ដោយនៅក្នុងនោះ គណៈកម្មការសុរិយោដីមានបេសកម្មដោះស្រាយវិវាទដីធ្លី (ចំពោះដីដែលគ្មានប័ណ្ណចេញដោយរដ្ឋបាលសុរិយោដី) ដែលមិនទាន់បានចុះបញ្ជីសុរិយោដីដែលស្ថិតនៅក្រៅតំបន់វិនិច្ឆ័យ ឬក្នុងតំបន់វិនិច្ឆ័យដែលមិនអាចសម្រុះសម្រួលបានដោយគណៈកម្មការរដ្ឋបាល និងមិនមែនជាវិវាទដែលពាក់ព័ន្ធនឹង បណ្ដឹងទាមទារការបែងចែកមរតក ឬវិវាទអំពីកិច្ចសន្យា ទិញលក់ ជួល ឬបញ្ចាំ ជាដើមនោះ។ ដោយគណៈកម្មការសុរិយោដីធ្វើការដោះស្រាយវិវាទនីមួយៗដោយចាប់ផ្ដើមពីថ្នាក់ ស្រុក/ខណ្ឌ រាជធានី/ខេត្ត និងចុងក្រោយទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិ។

## ២.១.ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

ការដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការ គឺជាការធ្វើឡើងដោយមានការស្ម័គ្រចិត្ត នៅក្នុងកិច្ចសន្យាអ្វីមួយដែលភាគីត្រូវតែមានខសន្យានោះបញ្ជាក់ថា ភាគីត្រូវយល់ព្រមប្រើការដោះស្រាយវិវាទនោះក្រៅប្រព័ន្ធតុលាការតាំងពីដើមមកម៉េស។ ប៉ុន្តែកាលអំឡុងឆ្នាំ២០០២ រាជរដ្ឋាភិបាលក៏បានបង្កើតគណៈកម្មការសុរិយោដី ដោយស្របតាមមាត្រា៤៧ នៃច្បាប់ភូមិបាលឆ្នាំ២០០១ ដែលជាយន្តការមួយសម្រាប់ការដោះស្រាយវិវាទដែលកើតឡើងក្រៅប្រព័ន្ធតុលាការ។ យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ សំដៅដល់ការដោះស្រាយវិវាទដីធ្លី ដោយមន្ត្រីជំនាញ នៃគណៈកម្មការសុរិយោដីដែលបានបង្កើតឡើងដោយអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២។ ការដោះស្រាយវិវាទនេះ គឺពាក់ព័ន្ធស្ថិតនៅក្រៅតំបន់បានចុះបញ្ជីសុរិយោដី ឬក្នុងតំបន់វិច្ឆ័យ ហើយមិនមែនជាវិវាទដីធ្លីដែលពាក់ព័ន្ធនឹងបណ្ដឹងទាមទារបែងចែកមរតក ឬវិវាទអំពីកិច្ចសន្យា ទិញលក់ ជួល ឬបញ្ចាំ ជាដើមនោះទេ។ តែការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ អាចយកមកប្រើប្រាស់បាន តែចំពោះវិវាទត្រូវយមកដោះស្រាយក្នុងករណីវិវាទដែលពាក់ព័ន្ធនឹងព្រហ្មទណ្ឌបានឡើយ ព្រោះវិវាទបែបនឹងជាវិវាទទាក់ទងនឹងរឿងឯកជន ដោយសារតែបទល្មើសព្រហ្មទណ្ឌ ជាប្រភេទបទល្មើសដែលពាក់ព័ន្ធ រឿងសង្គម ដែលប៉ះពាល់ទៅដល់សេរីរាង្គកាយបុគ្គល សណ្ដាប់ធ្នាប់សាធារណៈសន្តិសុខ របៀប*រៀប*យសង្គម ដែលករណីនេះតម្រូវឱ្យមានវិធីអនុវត្តយ៉ាងតឹងរឹង។ ប៉ុន្តែនៅក្នុងករណីខ្លះ ភាគីអនុម័តយកដំណោះស្រាយក្រៅប្រព័ន្ធតុលាការ ក្រោយពីជម្លោះបានកើតឡើង ដោយភាគីជម្លោះធ្វើកិច្ចសន្យាដឹងឮជាពិសេសមួយ ដើម្បីប្រើការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការមួយនេះ។ ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការក៏ជាយន្តការដែលធ្វើឱ្យភាគីមានភាពងាយស្រួលក្នុងការដំណើរការនីតិវិធីនៃការដាក់ពាក្យបណ្ដឹង។ វិធានទូទៅនៃការដោះស្រាយវិវាទជាដំបូងភាគីតត្រូវព្យាយាមធ្វើការចរចារវាងវិវាទដែលបានកើតឡើងជាមុនសិន តែបើសិនជាការលើកយកការចរចា*នៅ*តែមិនទទួលបានផលនោះ ភាគីនៃវិវាទក៏ត្រូវបន្តនីតិវិធីទីពីរ គឺជាការសម្រុះសម្រួលវិវាទទាំងនៅថ្នាក់ស្រុក/ខណ្ឌ និងថ្នាក់ខេត្ត/ក្រុងមុននឹងបញ្ជូនរឿងនោះមកគណៈកម្មការថ្នាក់ជាតិ ប៉ុន្តែវិធីសាស្ត្រនេះនូវតែមិនអាចធ្វើឱ្យគូភាគីទទួលយកដំណោះ

ស្រាយតាមរបៀបនេះទៀត ភាគីវិវាទក៏អាចបន្តវិធីបន្តទៀតបានរហូតដល់ខ្លួនទទួលបាននូវដំណោះស្រាយមួយដ៏ល្អមួយសម្រាប់ភាគីនៃវិវាទនោះ។

### ២.១.១.ការចរចា

យន្តការនៃការដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការតាមរយៈការចរចា ដែលការចរចានេះកើតឡើងនៅពេលដែលភាគីព្យាយាមដោះស្រាយវិវាទ ដោយខ្លួនឯងផ្ទាល់តែម្តង ឬតាមរយៈតំណាងរបស់ពួកគេ។ ព្រោះថាការចរចា គឺជាវិធីសាស្ត្រមួយក្នុងការដោះស្រាយវិវាទមួយដែលធ្វើឱ្យគូភាគីអាចយល់ស្របទៅនឹងការព្រមស្តាប់ ចម្លើយរវាងគ្នានិងគ្នា ស្វែងរកដំណោះស្រាយមួយដែលអាចធ្វើឱ្យគូភាគីអាចបញ្ចប់វិវាទនោះបាន។ ប៉ុន្តែការចរចាអាចរក្សាភាពជាឯកជនរបស់ភាគី និងអាចនាំឱ្យមានការផ្លាស់ប្តូរទស្សនៈស្មោះត្រង់រវាងគ្នាបានច្រើន។ ក្នុងដំណើរការចរចានេះភាគីនីមួយៗព្យាយាមពន្យល់ពីអ្វីដែលពួកគេចង់បាន ឬត្រូវការអោយភាគីម្ខាងទៀតព្រមព្រៀងដោះស្រាយវិវាទដោយវិធីដោយពេញចិត្តបំផុត។ ការចរចា គឺជាវិធីដំបូង និងជាទម្រង់ដ៏ទូទៅបំផុតនៃវិធីដោះស្រាយវិវាទយ៉ាងច្រើនបំផុតត្រូវបានដោះស្រាយ។ ក្នុងករណីមួយទៀតនោះ ប្រសិនបើជាភាគីទាំងពីរ មានជម្លោះខ្លាំងក្លា មិនអាចដោះស្រាយវិវាទដោយសន្តិវិធីបាន ការចរចាដោះស្រាយវិវាទគឺមិនមានជោគជ័យនោះទេ ភាគីត្រូវបន្តនីតិវិធីបន្តទៀត។

### ២.១.២.សន្ធានកម្ម ឬការសម្រុះសម្រួល

សន្ធានកម្ម ឬការសម្រុះសម្រួល សំដៅចំពោះការដោះស្រាយវិវាទ ដោយមានជំនួយពីភាគីទីបី ដែលដាក់ឱ្យអនុវត្តវិធានជាមូលដ្ឋានស្នើជូនជាមតិ និងស្នើឡើងនូវដំណោះស្រាយ ក៏ប៉ុន្តែភាគីទីបីនោះមិនមានអំណាចសម្រេចឱ្យភាគីវិវាទណាមួយទទួលយកការសម្រេចរបស់ខ្លួននោះទេ។ ភាគីអព្យាក្រឹត្យ ឬភាគីទីបីអាចចូលជួបជាមួយនឹងភាគីវិវាទម្នាក់ម្តងៗដាច់ដោយឡែកពីគ្នា និងទាំងជួបរួមគ្នាដើម្បីជួបភាគីវិវាទឱ្យសម្រេចបាននូវកិច្ចព្រមព្រៀងមួយ។ សន្ធានការីដើរតួនាទីជាអ្នកលើកទឹកចិត្តដល់ភាគីឱ្យគាត់និយាយពីបញ្ហាវិវាទរបស់គាត់ និងព្យាយាមជួយភាគីនីមួយៗឱ្យពិនិត្យមើលឱ្យបានច្បាស់លាស់ ថាតើរឿងវិវាទដែលពួកគាត់លើកឡើងសមនឹងទទួលបានលទ្ធផលបែបណា ប្រសិនបើវិវាទនោះត្រូវបញ្ជូនទៅតុលាការ។ តែសន្ធានការី តែងតែដាក់ជូនសំណើរបស់ភាគីវិវាទដោយផ្ទាល់ដើម្បីដោះស្រាយវិវាទនោះ ។ ភាគីអាចយល់ព្រមទទួលយកសេចក្តីស្នើយោបល់ទាំងនេះដែលអាចបង្កើតបានជាមូលដ្ឋានមួយសម្រាប់ការពិភាក្សាបន្ថែមទៀត ដែលនាំឱ្យមានដំណោះស្រាយរួមមួយ។ ដែលអាចឱ្យភាគីទាំងពីរទទួលយកបាននូវដោះស្រាយមួយនោះ តែក្នុងនោះភាគីអាចជ្រើសរើសអ្នកសម្រុះសម្រួលក្នុងករណីវិវាទរបស់ខ្លួនផងដែរ។ ប៉ុន្តែបើគូភាគីមិនអាចទទួលយកនូវការដោះស្រាយមួយនេះរបស់អ្នកសម្រុះសម្រួល

នោះទេភាគីអាចដាក់ពាក្យបណ្តឹងនោះ ដើម្បីបន្តនីតិវិធីបន្តទៀត តែការដាក់ពាក្យបណ្តឹងមិនតម្រូវឱ្យបង់ប្រាក់ក្នុងការធ្វើបណ្តឹងនោះទេ។

### ២.១.៣.ការដោះស្រាយវិវាទដោយគណៈកម្មការសុរិយោដីថ្នាក់ស្រុក/ខណ្ឌ

ចំពោះការទទួលពាក្យបណ្តឹង និងការឆ្លើយតបពាក្យបណ្តឹងរបស់បុគ្គលគ្រប់រូបដែលមានវិវាទពាក់ព័ន្ធនឹងដីធ្លីមិនទាន់ចុះបញ្ជីសុរិយោដី ដែលពួកគាត់មានសិទ្ធិដាក់ពាក្យបណ្តឹងដោយផ្ទាល់ទៅគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ។ បន្ទាប់មក គណៈកម្មការសុរិយោដីនឹងមានការជូនដំណឹងអំពីបណ្តឹងទៅភាគីចុងចម្លើយ ឬបុគ្គលដែលមានផលប្រយោជន៍ពាក់ព័ន្ធនឹងវិវាទដើម្បីឆ្លើយតបក្នុងរយៈពេល៣០ថ្ងៃ បន្ទាប់ពីទទួលបានសេចក្តីជូនដំណឹងនេះ[22]។ ចំពោះការស៊ើបអង្កេតបន្ទាប់ពីបានទទួលពាក្យបណ្តឹងនោះ គណៈកម្មការសុរិយោដីថ្នាក់ស្រុកខណ្ឌ នឹងមានការចាត់មន្ត្រីឱ្យធ្វើការចុះស៊ើបអង្កេតនៅក្នុងករណីវិវាទដែលមានឡើងនោះ ដើម្បីជួបជាមួយគូភាគីវិវាទ សាក្សី អាជ្ញាធរមូលដ្ឋាន និងធ្វើការវាស់វែងកំណត់ព្រំប្រទល់ដី និងទំហំដីឱ្យបានច្បាស់លាស់ ដើម្បីងាយស្រួលក្នុងការរកដំណោះស្រាយជូនគូវិវាទ។ បន្ទាប់ពីបញ្ចប់ការស៊ើបអង្កេតគណៈកម្មការសុរិយោដីនឹងពិនិត្យមើលថាតើករណីវិវាទនោះស្ថិតក្នុងសមត្ថកិច្ចដោះស្រាយរបស់ខ្លួនឬទេ? បើសិនករណីនោះមិនស្ថិតនៅក្នុងសមត្ថកិច្ចបណ្តឹងនោះត្រូវបានច្រានចោល ហើយត្រូវជូនដំណឹងទៅដល់គូភាគីនៃវិវាទជាលាយលក្ខណ៍អក្សរ។ ប៉ុន្តែក្នុងករណីដែលភាគីវិវាទមិនពេញចិត្តចំពោះការច្រានចោលរបស់គណៈកម្មការសុរិយោដីនោះ ភាគីវិវាទនោះអាចប្តឹងទៅគណៈកម្មការសុរិយោដីថ្នាក់លើ បន្ទាប់ក្នុងរយៈពេល៣០ថ្ងៃ បន្ទាប់ពីភាគីទទួលបានសេចក្តីជូនដំណឹងជាទម្រង់បែបបទច្រានចោលពាក្យបណ្តឹងនោះ។ ប្រភេទវិវាទមួយចំនួនត្រូវតែបញ្ជូនដោយផ្ទាល់ទៅគណៈកម្មការសុរិយោដីខេត្តក្រុង ឬគណៈកម្មការថ្នាក់ជាតិ[23]។ ចំពោះករណីទាំងនោះមាន៖

- មានវិវាទទំនាស់ផលប្រយោជន៍រវាងភាគីជាមួយ និងប្រធាននៃគណៈកម្មការសុរិយោដីថ្នាក់ស្រុក/ខណ្ឌ ឬអង្គភាពថ្នាក់ខេត្ត/ក្រុង ដែលក្នុងករណីនោះវិវាទនឹងត្រូវគេដាក់ជូនទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិបន្ទាប់ទៀត។
- មានកាលៈទេសៈធ្ងន់ធ្ងរដែលធ្វើឱ្យវិវាទ មិនអាចដោះស្រាយបាននៅកម្រិតជាក់លាក់ណាមួយដូចជា៖
    - ➢ ជនម្នាក់ទាមទារដីច្រើនក្បាល ដែលជាកម្មវត្ថុនៃការប្តឹងទាមទាររបស់ភាគីតូចតាចមួយចំនួនដែរ
    - ➢ ភាគីម្ខាងនៃវិវាទ ជាអាជ្ញាធរមានឋានៈខ្ពស់
    - ➢ ករណីមានវិវាទ ពាក់ព័ន្ធនឹងផលប្រយោជន៍របស់ប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក-ខណ្ឌ

---

[22]តាមមាត្រា៧ នៃអនុក្រឹត្យលេខ ៤៧ និងប្រការ២០ នៃប្រកាសលេខ ១១២ នៃច្បាប់ភូមិបាលឆ្នាំ២០០១

[23]ប្រការ២០ នៃប្រកាសស្តីពី គោលការណ៍ណែនាំ និងនីតិវិធីរបស់គណៈកម្មការសុរិយោដី

- ➢ វិវាទពាក់ព័ន្ធទៅនឹងដីសាធារណៈរបស់រដ្ឋ
- មានករណីជាបន្ទាន់ ដូចជា មានការគំរាមកំហែងដោយហិង្សា ឬធ្វើការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិដែលករណីនោះតម្រូវឱ្យមានកិច្ចអន្តរាគមន៍ជាបន្ទាន់។

នៅពេលដែលមានបញ្ហាដូចដែលបានរៀបរាប់ខាងលើ និងបញ្ហាផ្នែកយុត្តាធិការ គណៈកម្មការនោះត្រូវតែងតាំងក្រុមសម្រុះសម្រួល ដើម្បីចាប់ផ្ដើមធ្វើការជាមួយភាគីវិវាទដើម្បីឈានទៅដល់ការដោះស្រាយមួយប្រកបដោយភាពសុក្រឹត្យចំពោះភាគីនៃវិវាទនោះ[24]។

❖ **សិទ្ធិមានជំនួយការភាគី**

ជំនួយការភាគីមិនអាចនិយាយក្នុងនាមភាគីបានទេ នៅពេលជួបជាមួយភាគីវិវាទផ្សេងទៀត ឬក្រុមអ្នកសម្រុះសម្រួស ភាគីវិវាទទាំងនោះមានសិទ្ធិអមដោយអ្នកជំនួយការភាគី។ ជំនួយការភាគី អាចជា មេធាវី ឬជាបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល ឬជនម្នាក់ដែលភាគីទុកចិត្ត។ តួនាទីរបស់ជំនួយការនោះគឺផ្ដល់កិច្ចពិគ្រោះយោបល់ដល់ភាគីអំពីដំណើរការប្រព្រឹត្តទៅនៃវិវាទនោះ។ ទោះបីជាយ៉ាងណាក៏ដោយជំនួយការមិនអាចនិយាយតាងនាមឱ្យភាគី ឬនិយាយជំនួសភាគីនៅពេលណាមួយនៃដំណើរការសម្រុះសម្រួលវិវាទបានឡើយ [25]។

❖ **នៅពេលមានការព្រមព្រៀង**

នៅពេលដែលឈានដល់កិច្ចព្រមព្រៀងដីត្រូវចុះបញ្ជី ប្រសិនបើភាគីអាចឈានទៅដល់កិច្ចព្រមព្រៀងមួយក្នុងករណីនោះ ក្រុមអ្នកសម្រុះសម្រួលត្រូវធ្វើរបាយការណ៍លម្អិតនៃកិច្ចព្រមព្រៀងនោះ ដោយរួមបញ្ចូលទាំងផែនទី ឬដ្យាក្រាម ដែលចាំបាច់សម្រាប់បញ្ជាក់ពីលក្ខខណ្ឌព្រមព្រៀងដែលភាគីដោះស្រាយគ្នា។ បន្ទាប់មក ក្រុមអ្នកសម្រុះសម្រួលនឹងបញ្ជូនរបាយការណ៍នៃការព្រមព្រៀង ដែលបានចុះហត្ថលេខាដោយក្រុមអ្នកសម្រុះសម្រួលនោះ និងភាគីទៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលថ្នាក់ស្រុក/ខណ្ឌ និងគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង (មាត្រា ១១ នៃអនុក្រឹត្យ លេខ៤៧)។ ការិល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលថ្នាក់ស្រុក/ខណ្ឌ និងបញ្ជាក់សេចក្ដីលម្អិតនៃការព្រមព្រៀងរបស់ភាគី។ បន្ទាប់ពីទទួលបានការបញ្ជាក់ពីភាគីទាំងអស់ ដីធ្លីនិងត្រូវបានគេចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីធ្លីតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនោះ[26]។

[24] ប្រការ២២ នៃប្រកាសលេខ ១១២ ដនស ប្រក ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០២២ ស្ដីពី គោលការណ៍ណែនាំ និងនីតិវិធីរបស់គណៈកម្មការសុរិយោដី

[25] ប្រការ២៣ នៃប្រកាសលេខ ១១២ នៃប្រកាស ស្ដីពី គោលការណ៍ណែនាំ និងនីតិវិធីរបស់គណៈកម្មការសុរិយោដី

[26] ប្រការ២៧ នៃប្រកាសលេខ ១១២ ដនស ប្រក ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២ ស្ដីពី គោលការណ៍ណែនាំ និងនីតិវិធីរបស់គណៈកម្មការសុរិយោដី

❖ **នៅពេលដែលគ្មានការព្រមព្រៀង**

ក្នុងករណីដែលភាគីមិនអាចឈានទៅដល់ការព្រមព្រៀង វិវាទនឹងត្រូវបានគេដាក់ទៅការិយាល័យសុរិយោដីថ្នាក់ខេត្ត/ក្រុង ដើម្បីធ្វើការសម្រុះសម្រួលបន្តទៅទៀត[27]។ របាយការណ៍ផ្លូវការនឹងត្រូវបានគេបញ្ជូនផងដែរទៅឱ្យគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង រួមទាំងឯកសារដែលពាក់ព័ន្ធ និងភស្តុតាងដែលភាគីបានផ្តល់ជូន និងដែលប្រមូលបានក្នុងពេលស៊ើបអង្កេត ព្រមទាំងរបាយការណ៍ដែលបានរៀបចំដោយក្រុមអ្នកសម្រុះសម្រួលនូវសេចក្តីសង្ខេបអំពីដំណើរការនៃការសម្រុះសម្រួលវិវាទនោះ ដោយមិនបញ្ចូលការប្រជុំជាសំងាត់ ឬមតិយោបល់ដែលត្រូវរក្សាជាការសំងាត់ឡើយ ( ប្រការ២៨ នៃប្រកាសលេខ១១២ )។ ទោះបីជាក្រុមអ្នកសម្រុះសម្រួលអាចចូលរួមផ្តល់មតិយោបល់ក្នុងរបាយការណ៍ក៏ដោយ ក៏មតិយោបល់នោះ មិនអាចយកមកអនុវត្តចំពោះភាគី ឬចំពោះអ្នកសម្រុះសម្រួលផ្សេងទៀតបានទេ ជាពិសេសនៅលើបញ្ហាវិវាទដែលជាប់ពាក់ព័ន្ធទៅនឹងលក្ខណៈនៃវិវាទ ឬទាក់ទងទៅនឹងភស្តុតាងដែលបានដាក់ជូន។

## ២.១.៤.ការដោះស្រាយវិវាទដោយគណៈកម្មការសុរិយោដីរាជធានី/ខេត្ត

បន្ទាប់ពីទទួលបានការបញ្ជូនករណីវិវាទពី គណៈកម្មការសុរិយោដីថ្នាក់ស្រុក/ខណ្ឌ នៅពេលរកដំណោះស្រាយជូនគូវិវាទមិនបាននោះ ក៏បញ្ជូនបន្តមកគណៈកម្មការសុរិយោដីថ្នាក់រាជធានី/ខេត្ត ជាអ្នកមានសមត្ថកិច្ចដោះស្រាយបន្ត គណៈកម្មការថ្នាក់នេះនឹងព្យាយាមធ្វើការសម្រុះសម្រួលបន្តទៀតតាមនីតិវិធីដែលមានកំណត់នៅក្នុងច្បាប់ដែលបានចូលជាធរមានរួចហើយនោះ។ ចំពោះគណៈកម្មការសុរិយោដីថ្នាក់ខេត្ត/ក្រុង ដោះស្រាយវិវាទពីរប្រភេទដែលទាក់ទងវិវាទប្រភេទទីមួយរួមមាន៖ ករណីវិវាទទាំងឡាយដែលបានបញ្ជូនមកដោយផ្ទាល់ពីគណៈកម្មការសុរិយោដីថ្នាក់ស្រុក/ខណ្ឌ ដោយសារតែគណៈកម្មការសុរិយោដីស្រុក/ខណ្ឌ មិនមានអំណាចធ្វើការសម្រុះសម្រួលវិវាទទាំងនោះដែលមានហេតុផល និងប្រភេទវិវាទទីពីរ រួមមាន៖ ករណីវិវាទដែលបញ្ជូនដែលបានបញ្ជូនមកពីគណៈកម្មការសុរិយោដីស្រុក/ខណ្ឌ ដោយសារភាគីវិវាទមិនអាចឈានទៅដល់កិច្ចព្រមព្រៀង។ ប៉ុន្តែចំពោះករណីវិវាទទីពីរនេះ ការសម្រុះសម្រួលដោយគណៈកម្មការសុរិយោដីថ្នាក់ខេត្ត/ក្រុង គឺផ្តល់ឱ្យភាគីវិវាទនូវឱកាសមួយលើកឡើងដើម្បីសម្រុះសម្រួលវិវាទនោះ ហើយដើម្បីឱ្យឈានទៅដល់ការដោះស្រាយមួយដែលជាប្រយោជន៍ទៅវិញទៅមក។ ចំពោះការសម្រុះសម្រួលនៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុមគឺដូចគ្នាសុទ្ធសាធទៅនឹងដំណើការដោះស្រាយវិវាទនៅថ្នាក់ស្រុក/ខណ្ឌដែលបានធ្វើការរៀបរាប់ខាងលើ ហើយផ្តល់ឱ្យភាគីវិវាទនូវឱកាសម្តងទៀតដើម្បីសម្រុះសម្រួលវិវាទ និងឈានទៅដល់ការព្រមព្រៀងដែលបំរើផលប្រយោជន៍ទៅវិញទៅមក

[27] មាត្រា១១ នៃអនុក្រឹត្យលេខ ៤៧ អនក្រ បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពី ការរៀបចំ និងប្រព្រឹត្តទៅនៃ គណៈកម្មការសុរិយោដី

ទាំងសងខាង។ ហើយរាល់ដំណោះស្រាយនឹងត្រូវកត់ត្រាទុក និងត្រូវបញ្ជូនទៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ចំណែកឯវិវាទដែលមិនអាចដោះស្រាយបាននឹងត្រូវដាក់ជូនគណៈកម្មការសុរិយោដីថ្នាក់ជាតិ[28]។ ក្នុងរយៈ៦០ថ្ងៃ បន្ទាប់ពីបានទទួលបណ្តឹងវិវាទរបស់គណៈកម្មការសុរិយោដីរាជធានី/ខេត្ត ត្រូវរៀបចំកិច្ចប្រជុំរដ្ឋបាលរវាងគណៈកម្មការសុរិយោដីខេត្ត ក្រុង និងភាគីវិវាទ[29]។ តែបើការសម្រុះសម្រួលមិនអាចទទួលបានជោគជ័យទេនោះ គណៈកម្មការសុរិយោដីថ្នាក់រាជធានី/ខេត្ត ត្រូវធ្វើនីតិវិធីដោយឡែកផ្សេងទៀត គឺការធ្វើ សេចក្តីសម្រេច។ បើភាគីណាមួយមិនសុខចិត្តចំពោះសេចក្តីសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់រាជធានី/ខេត្ត ក្នុងរយៈពេល៣០ថ្ងៃ នៃថ្ងៃធ្វើការបន្ទាប់ពីទទួលបានសេចក្តីសម្រេច ឬទទួលបានព័ត៌មានអំពីសេចក្តីសម្រេច ភាគីវិវាទនោះមានសិទ្ធិសុំប្តឹងឱ្យ គណៈកម្មការសុរិយោដីថ្នាក់ជាតិធ្វើសវនាការជាថ្មីបាន។

### ២.១.៥.ការដោះស្រាយវិវាទដោយគណៈកម្មការសុរិយោដីថ្នាក់ជាតិ

គណៈកម្មការសុរិយោដីថ្នាក់ជាតិ ជាអាជ្ញាធរសុរិយោដីមានសមត្ថកិច្ចចេញសេចក្តីសម្រេចលើវិវាទដីភោគៈទាំងឡាយណាដែលគណៈកម្មការសុរិយោដីថ្នាក់ក្រោម និងគណៈកម្មការរដ្ឋបាលពុំអាចសម្រេចបាន។ ជាពិសេសគណៈកម្មការសុរិយោដីថ្នាក់ជាតិមានយុត្តាធិការពេញលេញក្នុងការធ្វើសេចក្តីសម្រេចទទួលស្គាល់ភោគី ឬកម្មសិទ្ធិករស្របច្បាប់[30] ប៉ុន្តែក្នុងនោះក៏មានចូលរួមពីសំណាក់ប្រធាន និងសមាជិកផ្សេងៗទៀតក្នុងការដោះស្រាយវិវាទនោះផងដែរ។ ក្នុងករណីដែលបានទទួលការបញ្ជូនករណីវិវាទពីគណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត ឬគណៈរដ្ឋបាល គណៈកម្មសុរិយោដីថ្នាក់ជាតិនឹងព្យាយាមធ្វើការសម្រុះសម្រួលបន្ត តែបើការសម្រុះសម្រួលមិនអាចទទួលបានជោគជ័យទេ គណៈកម្មការសុរិយោដីថ្នាក់ជាតិនឹងបើសវនការសម្រេចក្នុងករណីវិវាទនោះ។ គូភាគីមានសិទ្ធិប្តឹងតវ៉ានឹងសេចក្តីសម្រេច របស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ទៅតុលាការសាលាដំបូងរាជធានី/ខេត្តក្នុងរយៈពេល ៣០ថ្ងៃ ក្រោយពីបានទទួលសេចក្តីសម្រេចនេះ។ ប៉ុន្តែក្នុងករណីវិវាទទាំងឡាយណាដែលតម្រូវឱ្យមានការសម្រេចចិត្ត ឬដំណើរការដោះស្រាយវិវាទជាបន្ទាន់ (ភាគីត្រូវដាក់បណ្តឹងសុំឱ្យធ្វើការអន្តរាគមន៍ជាបន្ទាន់) ដូចជា ករណីដែលមានការគំរាមគំហែង ឬការភ័យខ្លាចដោយមិនសមហេតុផលពី ការបង្កអគ្គីភ័យ ការប្រើកម្លាំង ឬការបំភិតបំភ័យ ភាគីវិវាទអាចស្នើសុំទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិ ឱ្យចាត់វិធានការបណ្តោះ

---

[28] មាត្រា៧ នៃអនុក្រឹត្យលេខ ៤៧ អនក្រ បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពី ការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី និងប្រការ២០ នៃប្រកាសលេខ ១១២ ដនស ប្រក ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២ ស្តីពី គោលការណ៍ណែនាំ និងនីតិវិធីរបស់គណៈកម្មការសុរិយោដី

[29] មាត្រា១៥ និងមាត្រា១៦ នៃអនុក្រឹត្យ ៤៧ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅគណៈកម្មការសុរិយោដី

[30] ប្រការ៣១ នៃប្រកាសស្តីពី គោលការណ៍ណែនាំ និងនីតិវិធីរបស់គណៈកម្មការសុរិយោដី

អាសន្នដើម្បីការពារផលប្រយោជន៍របស់គូភាគីនៅពេលដែលមានវិវាទកំពុងដោះស្រាយ[31]។ ទោះបីជាស្ថិតនៅក្នុងស្ថានភាពនេះក៏ដោយ ក៏ភាគីអាចប្ដឹងដោយផ្ទាល់ទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិបានផងដែរ។ សេចក្ដីសម្រេចបណ្ដោះអាសន្នត្រូវមានខ្លឹមសារ ជាការរក្សាស្ថានភាពដដែល។ ដោយសេចក្ដីសម្រេចនេះ ជាវិធានការដ៏ល្អដើម្បីអនុវត្ត និងទទួលបាននូវការអន្តរាគមន៍ពីអាជ្ញាធរដែលមានសមត្ថកិច្ច ដូចជា នគរបាល និងកងរាជអាវុធហត្ថជាដើមនោះ។ ប៉ុន្តែចំពោះ អាជ្ញាធរមានសមត្ថកិច្ចដែលបានព្រងើយកន្តើយ ឬបណ្ដោយឱ្យសាមញ្ញជនណាម្នាក់ប្រព្រឹត្តដោយមានការរំលោភលើសិទ្ធិរបស់ភាគីណាមួយនោះ អាជ្ញាធរនោះត្រូវតែទទួលការផ្ដន្ទាទោសពិន័យជាប្រាក់ពី ១-១០លានរៀល និងត្រូវទទួលទោសរដ្ឋបាលថែមទៀតផងដែរ។ ក្នុងនោះដែរ ក្រោយពេលបើកសវនការគណៈកម្មការនេះមិនតម្រូវឱ្យគោរពតាមវិធានភស្តុតាង ឬនីតិវិធីទេ គ្រាន់ទៅតែធានាឱ្យគូភាគីមានឱកាសបង្ហាញសក្ខីកម្ម និងភស្តុតាងរបស់ខ្លួនដោយយុត្តិធម៌ និងសមធម៌។ ផ្ទុយទៅវិញបើគ្មានការជំទាស់នឹងភស្តុតាង ឬព័ត៌មានផ្សេងៗទៀត ដែលភ្ជាប់មកជាមួយពាក្យបណ្ដឹងនោះទេ គណៈកម្មការសុរិយោដីថ្នាក់ជាតិសន្និដ្ឋានតាមផ្លូវច្បាប់ និងមូលដ្ឋាននៃអង្គហេតុដើម្បីចេញសេចក្ដីសម្រេចរបស់ខ្លួន។ សេចក្ដីសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ និងក្លាយជាស្ថាពរនៅក្រោយ រយៈពេល៣០ថ្ងៃ បន្ទាប់ពីបញ្ជូនទៅគូភាគីទាំងអស់។ ក្នុងនោះដែរ ភាគីអាចប្ដឹងជំទាស់បានតែត្រូវដាក់ជូនទៅតុលាការក្នុងរយៈពេល ៣០ថ្ងៃ បន្ទាប់ពីសេចក្ដីសម្រេចជាលាយលក្ខណ៍អក្សររបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវបានបញ្ជូនដល់ភាគីវិវាទ[32]។ នៅពេលដែលសេចក្ដីសម្រេចបាន ដល់សុពលភាពអាចអនុវត្តបាន គណៈកម្មការសុរិយាដីថ្នាក់ជាតិ ត្រូវផ្ញើសេចក្ដីសម្រេចនោះទៅឱ្យមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី/ខេត្ត ដើម្បីធ្វើការចាត់ចែងចុះបញ្ជីក្បាលដីតាមនីតិវិធីដែលបានកំណត់នោះ។

យុត្តាធិការរបស់គណៈកម្មសុរិយោដី គឺជាការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការក្នុងន័យដោះស្រាយវិវាទលើដីដែលមិនទាន់បានចុះបញ្ជីសុរិយាដីរវាងភាគី និងភាគី។ គណៈកម្មការសុរិយោដីបានពង្រីកការដោះស្រាយដោយប្រើប្រាស់តាមការដោះស្រាយវិវាទចល័តដែលកន្លងមកតាមរយៈក្រុមចល័តនេះ វិវាទដីធ្លីដែលមាននៅតាមក្រុងស្រុក/ខណ្ឌ មួយចំនួនត្រូវបានដោះស្រាយរួចស្ទើរតែទាំងស្រុង។ ជាងនេះទៅទៀត គណៈកម្មការសុរិយោដីថ្នាក់ជាតិក៏បានធ្វើប្រតិភូកម្មមុខងារធ្វើសេចក្ដីសម្រេចទៅឱ្យប្រធានគណៈកម្មការរាជធានី/ខេត្ត រួមទាំងការណែនាំក្នុងការអនុវត្តផងដែរ។ ជាពិសេសទំនាស់ធំៗដែលកើតឡើងរវាងប្រជាពលរដ្ឋច្រើនគ្រួសារដែលគ្មានអំណាចជាមួយនឹងក្រុមហ៊ុនដែលជាអាជ្ញាធរមានឋានៈខ្ពស់ ឬអ្នកមានខ្នងបង្អែកធំនៅតែបង្ហាញឱ្យឃើញនូវភាពអយុត្តិធម៌

[31] អនុក្រឹត្យលេខ៤៧ អនក្រ បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្ដីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី៖ មាត្រា១០

[32] ប្រកាសលេខ ១១២ ដនស ប្រក ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០២ ស្ដីពី គោលការណ៍ណែនាំ និងនីតិវិធីរបស់គណៈកម្មការសុរិយោដី៖ មាត្រា៣៩

កាន់តែធ្ងន់ធ្ងរថែមទៀត។ ដោយភាគីក្រុមហ៊ុនទាំងនោះបានប្រើអំពើហិង្សាឈូសឆាយរំលោភយកដីរបស់ប្រជាពលរដ្ឋ ដែលជាភាគីគ្មានអំណាចនោះ ធ្វើឱ្យពួកគេទទួលរងនូវការចោទប្រកាន់ និងការចាប់ខ្លួនជាដើម។ ប៉ុន្តែទោះបីជារដ្ឋបានខិតខំដោះស្រាយយ៉ាងណាក៏ដោយ ក៏មិនអាចបញ្ចប់វិវាទឱ្យអស់ទាំងស្រុងនោះដែរ ហើយករណីវិវាទមួយចំនួនបានធ្វើឱ្យប្រជាពលរដ្ឋទទួលរងនូវការឈឺចាប់ ដែលកើតចេញពីភាពអយុត្តិធម៌ដែលពួកគាត់ទទួលបាននោះ។

### ២.១.៦.អាជ្ញាកណ្តាល

ការដោះស្រាយវិវាទ គឺមានដំណោះស្រាយជាច្រើនដែលភាគីជម្លោះអាចជ្រើសរើសការដោះស្រាយមួយណាដែលខ្លួនគិតថាត្រឹមត្រូវអាចផ្តល់យុត្តិធម៌ ចំណេញពេលវេលា អាចរក្សាទំនាក់ទំនងរវាងភាគីវិវាទបាន មានភាពជាឯកជនច្រើន ចំណាយថ្លៃតិច និងនីតិវិធីអាចបត់បែនបានងាយស្រួលសម្រាប់ខ្លួននោះ។ ជាគោលការណ៍ការដោះស្រាយវិវាទមួយដែលធ្វើតាមវិធីមជ្ឈត្តការ ឬមជ្ឈត្តវិនិច្ឆ័យ ឬអាជ្ញាកណ្តាល ត្រូវធ្វើទៅតាមវិធានដែលបានគ្រប់គ្រងទៅលើការដោះស្រាយវិវាទតាមរយៈអាជ្ញាកណ្តាលនៃប្រទេសកម្ពុជា។ អាជ្ញាកណ្តាលកើតឡើងនៅពេលដែលភាគីជម្លោះជ្រើសរើសភាគីអព្យាក្រឹត្យម្នាក់ឱ្យធ្វើការដឹកនាំនីតិវិធីផ្លូវការពិនិត្យមើលភាគីទាំងពីរ ហើយនៅទីបញ្ចប់ធ្វើសេចក្តីសម្រេចដោយ អាស្រ័យលើច្បាប់ដែលបានកំណត់ផងដែរ។ ពោលការដោះស្រាយដែលធ្វើឡើងដោយអាជ្ញាកណ្តាល វាមានលក្ខណៈដូចជាការដោះស្រាយតាមតុលាការដែរ ដោយការដោះស្រាយនេះធ្វើឡើងជារូបភាពសវនាការ និងមានសិទ្ធិចេញសេចក្តីសម្រេចដូចគ្នា គ្រាន់តែសេចក្តីសម្រេចរបស់អាជ្ញាកណ្តាលតែការចេញសេចក្តីសម្រេចនេះមិនមានលក្ខណៈដូចគ្នានឹងសេចក្តីសម្រេចរបស់តុលាការឡើយ (ប្រសិនបើមានមជ្ឈត្តករច្រើនជាងមួយ) ធ្វើការសម្រេចសេចក្តី ឬចេញសេចក្តីសម្រេចឱ្យគូភាគីដោយផ្អែកលើការពិនិត្យភស្តុតាងទឡ្ហីករណ៍ និងច្បាប់ទាំងឡាយ។ ចំពោះភាពខុសគ្នារវាងអាជ្ញាកណ្តាល និងសន្ទានកម្ម គឺមជ្ឈត្តករមានអំណាចច្រើនជាងសន្ទានការីក្នុងការក្តាប់ដំណើរការ និងលទ្ធផលនៃដោះស្រាយដែលអាចមាន។ ក្នុងករណីដែលភាគីវិវាទអាចបញ្ចប់វិវាទដោយការដោះស្រាយតាមរយៈការដោះស្រាយដែលធ្វើដោយអាជ្ញាកណ្តាល ដែលភាគីទាំងពីរបានធ្វើការជ្រើសរើសនោះ ដោយភាគីទាំងពីរមានការព្រមព្រៀងគ្នាយកការដោះស្រាយដោយរបៀបនេះហើយព្រោះភាគីទាំងគិតថាដំណោះស្រាយនេះវាអាចផ្តល់នូវភាពត្រឹមត្រូវតាមការចង់បានរបស់ខ្លួនហើយ ដោយជៀសវាងការប្តឹងផ្តល់គ្នាបន្តទៀត។ ប៉ុន្តែបើ ភាគីណាមួយមិនយល់ព្រមនូវការដោះស្រាយតាមអាជ្ញាកណ្តាលនោះទេ ភាគីនោះក៏អាចបន្តនីតិវិធី ឬជ្រើសរើសការដោះស្រាយមួយដែលមានការដំណោះស្រាយជាច្រើននោះបាន។

### ២.១.៧.គុណសម្បត្តិ និងគុណវិបត្តិនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

❖ **គុណសម្បត្តិ**

- ភាពមិនលម្អៀង៖ ប្រព័ន្ធនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការភាគច្រើនអនុញ្ញាតឱ្យភាគីជ្រើសរើសស្ថាប័នដោះស្រាយវិវាទ
- ពេលវេលា៖ ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ គឺមានពេលវេលាឆាប់រហ័សជាងការដោះស្រាយវិវាទតាមប្រព័ន្ធតុលាការ ព្រោះការដោះស្រាយនេះឱ្យភាគីវិវាទយល់ព្រមបញ្ចប់ជម្លោះទៅតាមការសម្រុះសម្រួល ឬការសម្រេច តាមការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការណាមួយខាងលើ ជាការសម្រេច។
- ភាពអាថ៌កំបាំង៖ប្រព័ន្ធដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ភាគច្រើនអនុញ្ញាតឱ្យរក្សាការសម្ងាត់ចំពោះដំណើរការក្តី ហើយនិងឧបាស្រ័យបានល្អ។ ផ្ទុយទៅវិញការរក្សាការសម្ងាត់អាចជារឿងពិបាកនៅក្នុងដំណោះស្រាយវិវាទតាមតុលាការ ព្រោះថាកំណត់ត្រាជាទូទៅត្រូវបានបើកចំហជាសាធារណៈ។
- សោហ៊ុយចំណាយក្នុងវិវាទ៖ ជាទូទៅដំណោះស្រាយវិវាទតាមតុលាការត្រូវចំណាយសោហ៊ុយច្រើនជាងដំណោះស្រាយវិវាទក្រៅតុលាការ ដោយសារហេតុផលខ្លះៗ ដូចជាការដោះស្រាយវិវាទតាមផ្លូវតុលាការមានរយៈពេលយូរ ភាគីត្រូវការជួលសេវាមេធាវី។ ចំណែកការដោះស្រាយវិវាទតាមប្រព័ន្ធតុលាការវិញ គឺចាំបាច់ជួលមេធាវីក្នុងការដំណើរការនីតិវិធីជំនួស។

❖ **គុណវិបត្តិ**

- ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ភាគច្រើន អាចដោះស្រាយវិវាទដីធ្លីណាដែលមិនសូវមានវិវាទធ្ងន់ធ្ងរ ឬវិវាទដោយការយល់ច្រឡំ ឬវិវាទណាដែលមិនធ្វើឱ្យបាត់បង់ផលប្រយោជន៍ច្រើនរបស់ភាគីវិវាទតែប៉ុណ្ណោះ។
- ចំពោះវិវាទដែលមានលក្ខណៈស្មុគស្មាញ ធ្វើឱ្យខាតបង់ផលប្រយោជន៍ច្រើនរបស់ភាគីវិវាទណាមួយនោះគឺភាគច្រើនការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ មិនមានសមត្ថកិច្ចគ្រប់គ្រាន់ក្នុងការដោះស្រាយទេ។ មួយវិញទៀត ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ មិនមានអានុភាពចាប់បង្ខំឱ្យភាគីវិវាទទទួលយកសេចក្តីសម្រេច ដែលកើតចេញពីការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការបានឡើយ។

## ២.២.ការដោះស្រាយវិវាទដីធ្លីតាមប្រព័ន្ធតុលាការ

ស្ថាប័នតុលាការ គឺជាស្ថាប័នដែលឯករាជ្យដែលមានសមត្ថកិច្ចដោះស្រាយគ្រប់រឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផងដែរ ហើយចំពោះរឿងក្តីវិវាទទាក់ទងនឹងដីធ្លីដែលមិនបានចុះបញ្ជីសុរិយោដីរួចក៏ស្ថិតក្នុងសមត្ថ

កិច្ចរបស់តុលាការផងដែរ[33]។ លើសពីនេះទៅ តុលាការ គឺជាស្ថាប័នដែលធានានូវសិទ្ធិសេរីភាពជូនប្រជាពលរដ្ឋតាមរយៈការដាក់ពាក្យបណ្ដឹង ដើម្បីឱ្យស្ថាប័ននេះធ្វើការដោះស្រាយនិងស្វែងរកយុត្តិធម៌ជូនពួកគាត់។ ប៉ុន្តែក្នុងតុលាការយោធាគឺជាគ្មានសមត្ថកិច្ចទៅការដោះស្រាយវិវាទដីធ្លីនោះទេ ដោយសារតែតុលាការយោធាដោះស្រាយតែវិវាទដែលទាក់ទងរវាងយោធា និងយោធាតែប៉ុណ្ណោះ។

នៅក្នុងនោះដែលភាពខុសគ្នានៃយុត្តាធិការរបស់តុលាការ និងគណៈកម្មការសុរិយោដី ត្រូវបានកំណត់ដោយប្រកាសអន្តរក្រសួងលេខ០២ ប្រករ០៣ ចុះនៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៣ រវាងក្រសួងយុត្តិធម៌ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ប្រកាសនេះបានកំណត់អំពីតួនាទីរបស់តុលាការក្នុងការដោះស្រាយជម្លោះដីធ្លី ចំពោះដីដែលមិនទាន់បានចុះបញ្ជីរួច និងជម្លោះកិច្ចសន្យាលើដីដែលមិនទាន់បានចុះបញ្ជីដូចជា៖ មរតក ទិញលក់ និងបញ្ចាំជាដើម។ ក្នុងករណីនេះ តុលាការត្រូវធ្វើការដោះស្រាយតាមនីតិវិធីរបស់តុលាការដោយផ្អែកលើភស្តុតាងនានា មានប័ណ្ណសម្គាល់កម្មសិទ្ធិដីធ្លី និងកិច្ចសន្យាជាដើម អាស្រ័យទៅតាមប្រភេទនៃជម្លោះ។

បន្ថែមពីនេះទៀត តុលាការក៏មានយុត្តាធិការដោះស្រាយជម្លោះដីធ្លីដែលមិនបានចុះបញ្ជីផងដែរ ក្នុងករណីបន្តដោះស្រាយបន្ទាប់អំពីគណៈកម្មការសុរិយោដីថ្នាក់ជាតិ។ មានន័យថា បន្ទាប់ពីគណៈកម្មការសុរិយោដីថ្នាក់ជាតិបានចេញសេចក្តីសម្រេចរបស់ខ្លួនរួចមក ភាគីជម្លោះមានសិទ្ធិប្ដឹងទៅតុលាការឱ្យធ្វើការត្រួតពិនិត្យវិញ ផ្នែកច្បាប់លើការសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិនោះ ភាគីដែលបានប្ដឹងសុំឱ្យមានការពិនិត្យឡើងវិញនូវផ្នែកច្បាប់ ត្រូវធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីបណ្ដឹងទៅលេខាធិការដ្ឋាននៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ ដើម្បីឱ្យលេខាធិការដ្ឋានរៀបចំក្នុងការធានាការពារលើសេចក្តីសម្រេចរបស់ខ្លួនចំពោះតុលាការ[34]។ ប្រសិនបើតុលាការរកឃើញថាគណៈកម្មការសុរិយោដីមិនបានអនុវត្តតាមនីតិវិធីសមរម្យ ឬដោយវិវាទអំពីផលប្រយោជន៍ ឬដោយមិនបានផ្តល់ហេតុផលឱ្យបានសមរម្យ ឬដោយអនុវត្តលើសពីសមត្ថកិច្ចការរបស់នោះតុលាការត្រូវធ្វើសំណុំរឿងក្តីនេះ ទៅគណៈកម្មការសុរិយោដីនេះត្រូវតែចាត់វិធានការអនុវត្តតាមសំណូមពររបស់តុលាការ។ តុលាការត្រូវធ្វើសេចក្តីសម្រេច ដោយយោងទៅតាមសេចក្តីសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ឬកែប្រែទៅតាមហេតុផលសមរម្យ រួចចេញសាលក្រម ឬសាលដីការជាស្ថាពរ ហើយសាលក្រមនេះត្រូវធ្វើជាច្បាប់ចម្លងមកគណៈកម្មសុរិយោដីជាតិដើម្បីចាត់ចែងដំណើរការនីតិវិធីនៃការចុះបញ្ជីដីជាបន្ត។

[33] មាត្រា២៣ នៃអនុក្រឹត្យលេខ ៤៧ អនក្រ បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី

[34] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣៖ មាត្រា១២៨ថ្មី

នីតិវិធីក្នុងការដោះស្រាយវិវាទដីធ្លីតាមផ្លូវតុលាការ មានលក្ខណៈដូចទៅនឹងការដោះស្រាយវិវាទរដ្ឋប្បវេណីផ្សេងៗទៀតដែរ ដូចជាវិវាទកិច្ចសន្យាលក់ ទិញ វិវាទរដ្ឋបាល និងវិវាទការងារផងដែរ។ នីតិវិធីនៃការដោះស្រាយប្រភេទនេះ គឺត្រូវអនុវត្តតាមក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាដែលបានចុះនៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៦។ វិវាទដីធ្លីដែលត្រូវបានដោះស្រាយដោយតុលាការ គឺត្រូវគោរពនូវគោលការណ៍ចំពោះដីធ្លីដែលបានចុះបញ្ជីសុរិយាដីរួចហើយ ដូចដែលបានរៀបរាប់ខាងលើ និងត្រូវតែអនុវត្តតាមនីតិវិធីដែលមានបញ្ញត្តិទុកក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។ ប៉ុន្តែការកំណត់សមត្ថកិច្ចតាមរយៈការប្រកាសអន្តរក្រសួងរវាងគណៈកម្មការសុរិយាដី និងតុលាការទាក់ទងនឹងការដោះស្រាយទំនាស់ជួបប្រទះនូវការខ្វែងគំនិតគ្នា។ ជាការលំបាកនាំឱ្យមានការចោទប្រកាន់ថាមានការជ្រៀតជ្រែកដែនសមត្ថកិច្ចដោយភាគីម្ខាងសំអាងលើច្បាប់កំពូល និងភាគីម្ខាងទៀតសំអាងលើការប្រកាសអន្តរក្រសួងនៅក្នុងការដោះស្រាយទំនាស់ដីដែលមាន ឬគ្មានប័ណ្ណកម្មសិទ្ធិដីធ្លីនោះ។

### ២.២.១.នីតិវិធីបណ្តឹង

#### ២.២.១.១.ការដាក់ពាក្យបណ្តឹង និងទម្រង់ពាក្យបណ្តឹង

- **ការដាក់ពាក្យបណ្តឹង**

នីតិវិធីបណ្តឹង ត្រូវបានធ្វើឡើងក្នុងគោលបំណងស្វែងរកភាពយុត្តិធម៌នៅពេលដែលមានវិវាទកើតឡើង។ អ្នកដែលអាចធ្វើបណ្តឹងបានត្រូវតែជានីតិជន ឬជនដែលមានសមត្ថភាពធ្វើសកម្មភាពដោយខ្លួនឯង ជនមិនស្ថិតក្រោមហិតូបត្ថម្ភ ឬជនមិនស្ថិតក្រោមអាណាព្យាបាលទូទៅ និងអនីតិជនដែលទទួលបានអត្តាធិនភាព ព្រោះជនទាំងនេះត្រូវបានច្បាប់ទទួលស្គាល់នូវសិទ្ធិ និងករណីយកិច្ច ក្នុងការបំពេញកាតព្វកិច្ចតាមផ្លូវច្បាប់ដោយមិនត្រូវការយល់ព្រមពីអាណាព្យាបាលឡើយ។ ចំពោះជនដែលខ្វះសមត្ថភាពក្នុងការធ្វើបណ្តឹងដូចជា អនីតិជន ជននៅក្រោមហិតូបត្ថម្ភ ជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅ អាចធ្វើបណ្តឹងបានតាមរយៈអ្នកតំណាងស្របច្បាប់ដែលច្បាប់បានកំណត់ (អាណាព្យាបាលទូទៅ ហិតូបត្ថម្ភកៈ) ឬអ្នកតំណាងតាមអាណត្តិជាដើម។

- **ទម្រង់ពាក្យបណ្តឹង**

ពាក្យបណ្តឹងត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ពី៖

- ឈ្មោះ សញ្ជាតិ ថ្ងៃខែឆ្នាំកំណើត និងអាស័យដ្ឋានរបស់គូភាគី និងរបស់អ្នកតំណាងដែលច្បាប់កំណត់

- ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ និងអង្គហេតុចាំបាច់បញ្ជាក់ការទាមទារ
- អង្គហេតុដែលជាមូលហេតុនៃការទាមទារ
- អង្គហេតុសំខាន់ៗដែលទាក់ទងទៅនឹងអង្គហេតុដែលជាមូលហេតុនៃការទាមទារ និងភស្តុតាង។

ក្រោយពីបំពេញគ្រប់លក្ខខណ្ឌខាងលើហើយ ត្រូវយកដាក់ជូនតុលាការដើម្បីឱ្យតុលាការ ចាប់ផ្តើមនីតិវិធីរបស់ខ្លួន ហើយភាគីដែលជាអ្នកដាក់ពាក្យបណ្តឹងត្រូវតែជាជនដែលមានសមត្ថភាពគ្រប់គ្រាន់តាមផ្លូវច្បាប់ ឬអ្នកតំណាងដែលច្បាប់បានកំណត់។

### ២.២.១.២.ការបង់ពន្ធលើពាក្យបណ្តឹង

ពេលដែលដាក់ពាក្យបណ្តឹង ភាគីដែលជាដើមបណ្តឹង ត្រូវបង់ពន្ធដែលមានចំនួនប្រាក់គណនាទៅតាមតម្លៃកម្មវត្ថុនៃបណ្តឹង។ការបង់ពន្ធត្រូវធ្វើដោយការបង់ជាប្រាក់នៅកន្លែងទទួលពាក្យបណ្តឹងនៃតុលាការ ចំពោះពាក្យសុំដែលមិនបានបង់ពន្ធនៅពេលដាក់ទេ ត្រូវចាត់ទុកថាជាពាក្យបណ្តឹងមិនស្របច្បាប់[35]។ ក្រៅពីនោះភាគីត្រូវបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធដើម្បី ឱ្យតុលាការធ្វើការពិនិត្យភស្តុតាង ការបញ្ជូនឯកសារ សោហ៊ុយធ្វើដំណើរ ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ និងសោហ៊ុយស្នាក់នៅដែលចាំបាច់សម្រាប់ចៅក្រម និងក្រឡាបញ្ជី ក្នុងករណីត្រូវធ្វើការស្រាវជ្រាវអង្គហេតុ ឬសកម្មភាពផ្សេងទៀតដែលប្រព្រឹត្តទៅនៅក្រៅតុលាការ។ ប្រាក់ប្រដាប់ក្តីក្រៅពីពន្ធនេះ តុលាការបង្គាប់ឱ្យភាគីបង់ជាមុនដើម្បីដំណើរការនីតិវិធី ប្រសិនបើសាម៉ីខ្លួនមិនបានបង់ជាមុនទេនោះ តុលាការអាចមិនធ្វើនូវសកម្មភាពដែលចាំបាច់ត្រូវមានប្រាក់ប្រដាប់ក្តីនោះបាន[36]។

### ២.២.១.៣.ការពិនិត្យពាក្យបណ្តឹង និងការបញ្ជូនពាក្យបណ្តឹង

- **ការពិនិត្យពាក្យបណ្តឹង**

តុលាការ ជាអ្នកមានសមត្ថកិច្ចត្រួតពិនិត្យទៅលើពាក្យបណ្តឹងដែលភាគីបានដាក់មក ប្រសិនបើពាក្យបណ្តឹងមានភាពខ្វះខាត មិនទាន់បានបង់ពន្ធលើពាក្យបណ្តឹង ឬមិនមានភាពត្រឹមត្រូវនៅឡើយ តុលាការត្រូវកំណត់អំឡុងពេលសមរម្យ និងបង្គាប់ឱ្យកែតម្រូវចំណុចខ្វះខាតចំពោះពាក្យបណ្តឹងនោះ។ ករណីមានការបង្គាប់ឱ្យកែតម្រូវពាក្យ

[35] មាត្រា៦១នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[36] មាត្រា៦៣នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នា២០០៦

បណ្តឹងពីតុលាការ តែដើមចោទមិនបានមកកែតម្រូវចំណុចខ្វះទេ តុលាការអាចលើកពាក្យបណ្តឹងចោលតាមដីកាសម្រេច។ ប៉ុន្តែភាគីក៏អាចធ្វើការប្តឹងជំទាស់ទៅនឹងដីកាសម្រេចច្រានចោលរឿងក្តីនោះបានផងដែរ[37]។

- **ការបញ្ជូនពាក្យបណ្តឹង**

ពាក្យបណ្តឹង ត្រូវបញ្ជូនទៅចុងចម្លើយជាចាំបាច់ ព្រោះការបញ្ជូននេះគឺជាការឱ្យភាគីម្ខាងទៀតបានដឹងអំពីបណ្តឹងថាតើបុគ្គលណាជាអ្នកប្តឹង កម្មវត្ថុនៃបណ្តឹងជាអ្វី មធ្យោបាយតទល់របស់ អ្នកប្តឹងនោះជាដើម ហើយជាការផ្តល់ឱកាសឱ្យភាគីម្ខាងទៀតនោះ ឆ្លើយដោះសារ និងរៀបចំមធ្យោបាយការពារខ្លួន។ ហើយលុះត្រាតែបណ្តឹងនោះទៅដល់ចុងចម្លើយទើបបណ្តឹងនោះត្រូវបានចាត់ការ។ ចំពោះករណីដែលមិនអាចបញ្ជូនពាក្យបណ្តឹងបានមានដូចជា៖

- ករណីអាស័យដ្ឋានរបស់ចុងចម្លើយដែលដើមចោទផ្តល់មិនមានភាពច្បាស់លាស់
- ចុងចម្លើយជាអសមត្ថជនដែលគ្មានអ្នកតំណាងដែលច្បាប់កំណត់
- ចុងចម្លើយជាជនបរទេសដែលមានអភ័យឯកសិទ្ធិ ហើយបដិសេធ ការទទួលការ បញ្ជូនពាក្យបណ្តឹង[38]។

ក្រោយពីការបញ្ជូនពាក្យបណ្តឹង ទៅដល់ចុងចម្លើយហើយនោះទោះជាបណ្តឹងនោះមានការខ្វះខាត ឬមានលក្ខណៈមិនគ្រប់គ្រាន់ក៏ដោយ ក៏តុលាការមិនអាចចេញដីកាបង្គាប់ឱ្យលើកចោលពាក្យបណ្តឹងនោះបានទៀតឡើយ។

### ២.២.២.ដំណាក់កាលនៃការដោះស្រាយ

នៅពេលដែលតុលាការ បានពិនិត្យពាក្យបណ្តឹងឃើញថា ពុំមានកង្វះខាតនៃលក្ខខណ្ឌទេនោះ តុលាការនឹងកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទី១ ដែលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះ ត្រូវបានកំណត់ក្នុងអំឡុងពេល ៣០ថ្ងៃបន្ទាប់ពីថ្ងៃដែលពាក្យបណ្តឹងត្រូវបានដាក់ លើកលែងតែមានករណីពិសេសបើតុលាការយល់ឃើញថាចាំបាច់ នោះតុលាការអាចកំណត់អំឡុងពេលលើសពីនេះបានដើម្បីឱ្យចុងចម្លើយត្រៀមការពារខ្លួន ក៏ដូចជាជ្រើសតាំងមេធាវីរៀបចំឯកសារដែលចុងចម្លើយត្រូវដាក់លើកដំបូងជាអាទិ៍។ ហើយកោះហៅភាគីទាំងសងខាងឱ្យមានវត្តមាននៅក្នុងតុលាការ។ ការកោះហៅភាគីទាំងសងខាងមកដោះស្រាយក្នុងតុលាការ នេះជាយន្តការមួយដើម្បីធានាគោលការណ៍ចំពោះមុខ និងភាពឆាប់រហ័សហើយយុត្តធម៌។

[37] មាត្រា៧៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៧

[38] មាត្រា៧៩ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៧

### ២.២.២.១.នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការតម្រូវឱ្យគូភាគីទាំងសងខាងធ្វើការអះអាងចំពោះអំណះអំណាងរបស់ខ្លួន បំភ្លឺនូវចំណុចវិវាទនៃរឿងក្តីដែលគូភាគីមិនយល់ស្របគ្នា ក៏ដូចជារៀបចំភស្តុតាងដែលទាក់ទងនឹងចំណុចវិវាទនៃរឿងក្តីនោះ ដើម្បីអាចធ្វើការវិនិច្ឆ័យរឿងក្តី នៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ឱ្យបានល្អិតល្អន់[39]។ ហើយនីតិវិធីខាងលើត្រូវ ធ្វើឡើងនៅកាលបរិច្ឆេទដែលភាគីទាំងសងខាងអាចចូលរួមបាន ដោយមិនបាច់បើកជាសាធារណៈនោះទេ[40]។ នៅក្នុងដំណាក់កាលនេះតុលាការអាចសាកល្បងក្នុងការផ្សះផ្សា បើយល់ឃើញថាភាគីទាំងសងខាងអាចសះជាបាន ប៉ុន្តែករណីការផ្សះផ្សាមិនបានទទួលជោគជ័យ តុលាការអាចធ្វើការផ្សះផ្សាម្តងទៀតបានផងដែរព្រោះតុលាការអាចធ្វើការផ្សះផ្សាបាន ទោះបីជាបណ្តឹងស្ថិតក្នុងដំណាក់កាលណាក៏ដោយ[41] ។ មានករណីមួយចំនួនដែលតុលាការមិនអាចផ្សះផ្សានោះទេដូចជា៖ វិវាទដែលទាក់ទងនិងសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលជាកម្មវត្ថុនៃការទាមទារដោយការប្តឹងនោះ មិនអាចឱ្យគូភាគីដោះស្រាយដោយការព្រមព្រៀងគ្នាបានទេ។ ក្រោយពីបានបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលហើយ ភាគីមិនអាចដាក់មធ្យោបាយតទល់ ឬការពារខ្លួនថ្មីបានទៀតទ ប៉ុន្តែករណីដែលមធ្យោបាយនោះទាក់ទងនឹងចំណុចដែលតុលាការត្រូវស្រាវជ្រាវដោយឆន្ទានុសិទ្ធិរបស់ខ្លួន ឬមិនធ្វើឱ្យយឺតយ៉ាវដល់នីតិវិធីនៃបណ្តឹង នោះភាគីអាចដាក់មកតុលាការបាន។ នៅក្នុងកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនីមួយៗ តុលាការត្រូវធ្វើកំណត់ហេតុឱ្យបានច្បាស់លាស់ដោយបញ្ជាក់ចំណុចចាំបាច់មួយចំនួនដូចជា៖

- សញ្ញាណរឿងក្តី
- ឈ្មោះចៅក្រម ក្រឡាបញ្ជី គូភាគី អ្នកតំណាង និងជំនួយការ
- ពេលវេលា និងទីកន្លែង ដោយមានការចុះហត្ថលេខាទទួលខុសត្រូវលើកំណត់ហេតុនោះពីប្រធានក្រុមប្រឹក្សាជំនុំជម្រះ និងក្រឡាបញ្ជី[42]។

លើសពីនេះទៅទៀតខ្លឹមសារសង្ខេបមួយចំនួនត្រូវកត់ត្រាឱ្យបានច្បាស់លាស់៖

- ខ្លឹមសារសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ នឹងចម្លើយតបរបស់ចុងចម្លើយចំពោះការទាមទារនោះ

[39] មាត្រា១០៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[40] មាត្រា១០៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[41] មាត្រា៩៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

[42] មាត្រា១១៩ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

- ខ្លឹមសារនៃអង្គហេតុដែលអះអាង និងការស្នើសុំឱ្យពិនិត្យភស្តុតាង
- ការទទួលស្គាល់ ឬមិនទទួលស្គាល់របស់ភាគីចំពោះអង្គហេតុដែលអះអាងដោយភាគីម្ខាងទៀត
- ការដកពាក្យបណ្តឹង ការផ្សះផ្សា ការលះបង់ការទាមទា និងការទទួលស្គាល់ការទាមទារ
- ចំណុចដែលតុលាការបង្គាប់ឱ្យកត់ត្រា និងចំនុចដែលតុលាការអនុញ្ញាតឱ្យកត់ត្រា តាមការទាមទាររបស់ភាគី
- ការសម្រេចសេចក្តី ដែលបានធ្វើឡើងនៅកាលបរិច្ឆេទនោះ ដោយមិនធ្វើជាលាយលក្ខណ៍អក្សរ[43]។

ក្នុងករណីដែលភាគី ឬតតិយជនដែលពាក់ព័ន្ធប្តឹងតវ៉ា ចំពោះសេចក្តីកត់ត្រានៅក្នុងកំណត់ហេតុស្តីពីនីតិវិធីខាងលើត្រូវកត់សេចក្តីប្តឹងតវ៉ានោះក្នុងកំណត់ហេតុនោះផងដែរ។

### ២.២.២.២.នីតិវិធីទាញហេតុផលផ្ទាល់មាត់

នៅពេលដែលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបានចប់សព្វគ្រប់ហើយ តុលាការត្រូវកំណត់កាលបរិច្ឆេទដើម្បីធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ហើយត្រូវកោះហៅគូភាគីមកចូលរួមនៅកាលបរិច្ឆេទដែលភាគីទាំងសងខាងអាចមានវត្តមានបាន ។ ការទាញហេតុផលផ្ទាល់មាត់ត្រូវធ្វើឡើងនៅសាលសវនាការជាសាធារណៈ ប៉ុន្តែបើមានផលប៉ះពាល់ដល់សណ្តាប់ធ្នាប់ធូន់ធ្ងរនោះមិនត្រូវបានអនុញ្ញាតឡើយ។នៅក្នុងដំណាក់កាលនេះភាគីទាំងសងខាងអាចធ្វើការអះអាងបន្ថែមទៀតអំពីអង្គហេតុ និងដាក់ភស្តុតាងបន្តមកតុលាការបានប្រសិនបើមិននាំឱ្យមានភាពយឺតយ៉ាវ ឬអាក់អួលដល់នីតិវិធីរបស់តុលាការ។ ក្រោយពីបានពិនិត្យភស្តុតាង នៅក្នុងកាលបរិច្ឆេទធ្វើការទាញហេតុផលដោយផ្ទាល់មាត់ហើយ តុលាការអាចធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលជាថ្មីម្តងទៀតបាន ដោយដីកាសម្រេចករណីយល់ឃើញថាមានការចាំបាច់។ មុនពេលបញ្ចប់នីតិវិធីការទាញហេតុផលដោយផ្ទាល់មាត់តុលាការអាចឱ្យភាគីនីមួយៗធ្វើការទាញហេតុផលចុងក្រោយបាន[44]។ ហើយនៅគ្រប់កាលបរិច្ឆេទនីមួយៗតុលាការ ត្រូវឱ្យក្រឡាបញ្ជីធ្វើកំណត់ហេតុស្តីពីការទាញហេតុផលដោយផ្ទាល់មាត់ ហើយគូភាគីទាំងសងខាងអាចប្តឹងតវ៉ាចំពោះសេចក្តីកត់ត្រានៅក្នុងកំណត់ហេតុនោះបាន ហើយសេចក្តីប្តឹងតវ៉ាត្រូវកត់នៅក្នុងកំណត់ហេតុនោះផងដែរ។

នៅក្នុងកំណត់ហេតុស្តីពីការទាញហេតុផលដោយផ្ទាល់មាត់ ត្រូវកត់ត្រានូវចំណុចសំខាន់ដូចជា៖

[43] មាត្រា១១១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

[44] មាត្រា១១៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧

- សញ្ញាណរឿងក្តី
- ឈ្មោះចៅក្រម និងក្រឡាបញ្ជី
- ឈ្មោះតំណាងអយ្យការ ប្រសិនបើមាន
- ឈ្មោះភាគី អ្នកតំណាង អ្នកជំនួយការ និងអ្នកបកប្រែ
- ពេលវេលា និងទីកន្លែងនៃការទាញហេតុផលដោយផ្ទាល់មាត់
- ហេតុការណ៍ដែលត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ ឬហេតុការណ៍ និងមូលហេតុដែលមិនធ្វើជាសាធារណៈក្នុងករណីមិនធ្វើជាសាធារណៈ[45]។ ហើយប្រធានក្រុមប្រឹក្សាជំនុំជម្រះ និងក្រឡាបញ្ជីត្រូវចុះហត្ថលេខាក្នុងកំណត់ហេតុនោះ។

លើសពីនេះទៅទៀតខ្លឹមសារសង្ខេបមួយចំនួនត្រូវកត់ត្រាឱ្យបានច្បាស់លាស់៖

- ការដកពាក្យបណ្តឹង ការផ្សះផ្សា ការលះបង់ការទាមទារ ការទទួលស្គាល់ការ ទាមទារ និងការសារភាព
- សេចក្តីថ្លែងការណ៍របស់សាក្សី របស់ភាគីផ្ទាល់ខ្លួន និងរបស់អ្នកធ្វើកោសល្យវិច័យ
- ការធ្វើសម្បថ ឬមិនធ្វើសម្បថរបស់សាក្សីរបស់ភាគីផ្ទាល់ខ្លួន និងរបស់អ្នកធ្វើកោសល្យវិច័យ
- លទ្ធផលនៃការតតពិនិត្យ
  ចំណុចដែលតុលាការបង្គាប់ឱ្យកត់ត្រា និងចំណុចដែលតុលាការអនុញ្ញាតឱ្យកត់ត្រា តាមការទាមទាររបស់ភាគី
- ការសម្រេចសេចក្តីដែលធ្វើឡើងដោយមិនបានធ្វើជាលាយលក្ខណ៍អក្សរ
- ការប្រកាសសេចក្តីសម្រេច[46]។

### ២.២.២.៣.ការចេញសាលក្រម

ក្រោយបញ្ចប់ការវិនិច្ឆ័យដោយផ្អែកលើលទ្ធផល ដែលបានមកពីការទាញហេតុផលដោយ ផ្ទាល់មាត់ និងការពិនិត្យលើភស្តុតាង តុលាការត្រូវចេញសាលក្រម ដែលខ្លឹមសារនៃសាលក្រមនោះត្រូវស្របទៅនឹងការទាមទាររបស់ភាគីដែលបានស្នើសុំតែប៉ុណ្ណោះ តុលាការត្រូវសម្រេចសេចក្តីអំពីករណីយកិច្ចទទួលបន្ទុកប្រាក់ប្រដាប់ក្តីទោះបីជាគ្មានពាក្យសុំរបស់ភាគីក៏ដោយ។ហើយបើកផ្លូវសម្រាប់ឱ្យគ្រប់ភាគីធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់បាន ប្រសិនបើខ្លួនមិនសុខចិត្តទៅនឹងសេចក្តីសម្រេចដែលចេញដោយតុលាការ។ សាលក្រមនឹងមាន

[45] មាត្រា១១៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[46] មាត្រា១១៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

អានុភាពដោយការប្រកាស ដែលការប្រកាសសាលក្រមនេះត្រូវធ្វើឡើងក្នុងអំឡុងពេលមួយខែ គិតចាប់ពីថ្ងៃដែលបានបញ្ចប់ ការទាញហេតុផលដោយផ្ទាល់មាត់ អំឡុងពេលនេះជាការទុកឱកាសឱ្យតុលាការពិចារណាទាំងអង្គហេតុ និងអង្គច្បាប់ដើម្បីសរសេរសាលក្រមឱ្យបានល្អត្រឹមត្រូវ[47]។

## ២.២.៣.បណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់

បណ្ដឹងឧបាស្រ័យ ត្រូវបានធ្វើឡើងនៅពេលដែលភាគីណាមួយនៃគូវិវាទមិនពេញចិត្តទៅនឹងការសម្រេចសេចក្ដីរបស់តុលាការជាន់ទាប ហើយត្រូវធ្វើក្នុងរយៈពេលកំណត់មួយជាក់លាក់មុនពេលដែលសេចក្ដីសម្រេចរបស់តុលាការចូលជាស្ថាពរ។ បណ្ដឹងឧបាស្រ័យចែកចេញជា៖ បណ្ដឹងឧទ្ធរណ៍ និង បណ្ដឹងសាទុក្ខ។

### ២.២.៣.១.បណ្ដឹងឧទ្ធរណ៍

បណ្ដឹងឧទ្ធរណ៍ គឺជាបណ្ដឹងមួយដែលប្ដឹងជំទាស់ទៅនឹងសេចក្ដីសម្រេចរបស់សាលាដំបូង ហើយបណ្ដឹងនេះត្រូវធ្វើទៅតុលាការនៃបណ្ដឹងឧទ្ធរណ៍ក្នុងអំឡុងពេល ០១ខែ ដោយគិតចាប់ពីថ្ងៃដែលទទួលបានការបញ្ជូនសាលក្រម ហើយមិនអាចធ្វើការពន្យារពេលបាននោះទេ[48]។ ដើម្បីប្ដឹងឧទ្ធរណ៍ ភាគីត្រូវដាក់ពាក្យបណ្ដឹងឧទ្ធរណ៍ទៅតុលាការដើម ដោយពាក្យបណ្ដឹងនោះត្រូវសរសេរនូវចំណុចសំខាន់មួយចំនួនដូចខាងក្រោម៖

- ឈ្មោះ ឬនាមករណ៍ និងអាស័យដ្ឋានរបស់ភាគី រួមនឹងឈ្មោះ និងអាស័យដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់
- សញ្ញាណសាលក្រមនៃការជំនុំជម្រះលើកទី១ និងសេចក្ដីដែលប្ដឹងឧទ្ធរណ៍ចំពោះសាលក្រមនោះ។

ករណីមិនបានសរសេរច្បាស់លាស់អំពីមូលហេតុនៃការទាមទារឱ្យលុបចោល ឬផ្លាស់ប្ដូរនូវសាលក្រមនៃការជំនុំជម្រះលើកទី១ទេ ដើមបណ្ដឹងឧទ្ធរណ៍គប្បីដាក់លិខិតជាលាយលក្ខណ៍អក្សរ ដែលសរសេរអំពីចំណុចនោះទៅតុលាការនៃបណ្ដឹងឧទ្ធរណ៍ក្នុងរយៈពេល ៣០ថ្ងៃ គិតចាប់ពីថ្ងៃដែលបានដាក់ពាក្យបណ្ដឹងឧទ្ធរណ៍នោះ[49]។ ម្យ៉ាងទៀតភាគីក៏អាចដកបណ្ដឹងឧទ្ធរណ៍វិញបានផងដែរ មុនពេលដែលសាលដីកាចុងក្រោយរបស់តុលាការនៃបណ្ដឹងឧទ្ធរណ៍ ត្រូវបានប្រកាស ដោយត្រូវធ្វើជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ក៏បាននៅកាលបរិច្ឆេទនៃនីតិវិធីតុលាការ[50]។ នីតិវិធី នៃបណ្ដឹងឧទ្ធរណ៍មានភាពប្រហាក់ប្រហែល ទៅនឹងនីតិវិធីបណ្ដឹងរបស់សាលាដំបូង

[47] មាត្រា១៨៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[48] មាត្រា២៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦
[49] មាត្រា២៦៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦
[50] មាត្រា២៦៩ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

ផងដែរដោយ តុលាការត្រូវត្រួតពិនិត្យលើពាក្យបណ្ដឹង ប្រសិនមានការខ្វះខាតត្រូវឱ្យភាគីមកធ្វើការកែតម្រូវ ប៉ុន្តែបើភាគីមិនបានមកធ្វើការកែតម្រូវ ឬមិនទាន់បានបង់ពន្ធនោះតុលាការនឹងលើកបណ្ដឹងនោះចោលដោយដីកាសម្រេច។ ករណីមានបណ្ដឹងឧទ្ធរណ៍ ហើយសាលាឧទ្ធរណ៍បានលុបចោលសាលក្រម សាលាដំបូង នោះសាលាឧទ្ធរណ៍ត្រូវធ្វើការជម្រះដោយខ្លួនឯង។ តុលាការនៃបណ្ដឹងឧទ្ធរណ៍ អាចបញ្ជូនរឿងក្ដីត្រលប់ទៅសាលាដំបូងវិញបានបើមានភាពចាំបាច់ត្រូវការការទាញហេតុផលបន្ថែមទៀតអំពីរឿងក្ដីនោះ។ ក្នុងករណីរឿងក្ដីដែលដោះស្រាយខុសសមត្ថកិច្ចផ្ដាច់មុខ នោះតុលាការនៃបណ្ដឹងឧទ្ធរណ៍និងចេញសាលដីកាផ្ទេររឿងក្ដីនោះ ទៅតុលាការដែលមានសមត្ថកិច្ចវិញ។ បើយើងក្រឡេកមកមើល នីតិវិធីសម្រាប់ការជំនុំជម្រះនៅសាលាឧទ្ធរណ៍ គឺអនុលោមទៅតាមនីតិវិធីនៃសាលាដំបូង ដោយគ្រាន់តែផ្លាស់ប្ដូរសមាសភាពចៅក្រមតែប៉ុណ្ណោះ។

### ២.២.៣.២ បណ្ដឹងសាទុក្ខ

បណ្ដឹងសាទុក្ខអាចធ្វើទៅតុលាការកំពូលបាន ចំពោះសាលដីកាចុងក្រោយដែលត្រូវបានជំនុំជម្រះលើកទី២ ដោយសាលាឧទ្ធរណ៍និងសាលក្រមចុងក្រោយដែលត្រូវបានជំនុំជម្រះលើកទី១ ដោយសាលាដំបូង ដែលបានព្រមព្រៀងគ្នា មិនប្ដឹងឧទ្ធរណ៍នៅពេលតុលាការចេញសាលក្រមនោះ។ គោលបំណងនៃបណ្ដឹងសាទុក្ខ គឺធ្វើឡើងដើម្បីឱ្យមានភាពស្របគ្នាក្នុងការបកស្រាយច្បាប់ ការអនុវត្តច្បាប់ និងករណីយុត្តិសាស្ត្រ និងជាពិសេសការការពារសិទ្ធិដើមបណ្ដឹងសាទុក្ខ។ ដោយតុលាការកំពូលនឹងបកស្រាយនូវមាត្រាច្បាប់នានា កុំឱ្យមានការបកស្រាយផ្ទុយគ្នាជាហេតុនាំឱ្យមានជម្លោះផ្នែកច្បាប់កើតមានឡើង និងការអនុវត្តមិនស្របតាមគោលគំនិតនៃច្បាប់ជាដើម ហើយការបកស្រាយរបស់តុលាការកំពូលត្រូវយកធ្វើជាយុត្តិសាស្ត្រ ក្នុងការអនុវត្តសម្រាប់សាលាដំបូង និងសាលាឧទ្ធរណ៍។ ភាគីមានរយៈពេល៣០ថ្ងៃសម្រាប់ការធ្វើបណ្ដឹងសាទុក្ខ ដោយគិតចាប់ពីថ្ងៃទទួលបានការបញ្ជូនសាលក្រម ឬសាលដីកា ប្រសិនបើមានមូលហេតុដូចខាងក្រោមនេះ៖

- តុលាការដែលចេញសាលដីកា ឬសាលក្រម មិនត្រូវបានចាត់តាំងដោយស្របទៅតាមច្បាប់
- ចៅក្រម ដែលបានចូលរួមដោយច្បាប់ មិនអនុញ្ញាតឱ្យចូលរួមក្នុងការចេញសាលដីកា ឬសាលក្រម
- ភាពផ្ទុយនឹងបញ្ញត្តិស្ដីពីសមត្ថកិច្ចផ្ដាច់មុខរបស់តុលាការ
- ការខ្វះសិទ្ធិតំណាងដែលកំណត់ដោយច្បាប់ សិទ្ធិតំណាងដោយអាណត្តិ ឬការប្រគល់សិទ្ធិឱ្យអ្នកតំណាងធ្វើសកម្មភាព
- ភាពផ្ទុយពីបញ្ញត្តិស្ដីពីការបើកការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ

➢ សាលដីកា ឬសាលក្រមគ្មានសំអាងហេតុ ឬមានសំអាងហេតុតែផ្ទុយគ្នា[51]។

ហើយនីតិវិធីនៃតុលាការកំពូលមានលក្ខណៈពិសេសមួយចំនួនខុសពីសាលាឧទ្ធរណ៍ និងសាលាដំបូង ដោយតុលាការនេះទទួលដោះស្រាយតែលើអង្គច្បាប់ប៉ុណ្ណោះ ដោយពិនិត្យលើភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃសាលដីកាសាលាឧទ្ធរណ៍ និងសាលក្រមសាលាដំបូង។ ពាក្យបណ្តឹងសាទុក្ខ ត្រូវដាក់នៅតុលាការដើម ហើយតុលាការដើមដែលទទួលបណ្តឹងសាទុក្ខត្រូវបញ្ជូនឱ្យទៅតុលាការកំពូលដើម្បីធ្វើការត្រួតពិនិត្យ។ ករណីមានការខ្វះខាត តុលាការតម្រូវឱ្យភាគីធ្វើការកែតម្រូវ ប៉ុន្តែបើភាគីមិនបានមកធ្វើការកែតម្រូវទេនោះ តុលាការនឹងលើកបណ្តឹងនោះចោលដោយដីកាសម្រេច។ ក្រៅពីនេះតុលាការត្រូវបញ្ជូនពាក្យបណ្តឹងសាទុក្ខ និងលិខិតទទួលពាក្យបណ្តឹងទៅដើមបណ្តឹង និងចុងចម្លើយ។ ក្នុងដំណាក់កាលជំនុំជម្រះ តុលាការកំពូល អាចធ្វើការលើកចោលនូវបណ្តឹងសាទុក្ខប្រសិនបើយល់ឃើញថាមានលក្ខណៈមិនស្របច្បាប់ ហើយមិនអាចកែតម្រូវបាន។ តុលាការក៏អាចច្រានចោលបណ្តឹងសាទុក្ខបានផងដែរករណីដែលគ្មានមូលហេតុសម្រាប់ធ្វើបណ្តឹងនោះទេ ប្រសិនបើបណ្តឹងសាទុក្ខត្រឹមត្រូវតាមលក្ខខណ្ឌច្បាប់កំណត់ហើយនោះ តុលាការកំពូលត្រូវបដិសេធចោលនូវសាលក្រម ឬសាលដីកាដើមចោល ហើយបញ្ជូនរឿងក្តីទៅតុលាការដើម្បីធ្វើការជំនុំជម្រះ។ តុលាការកំពូលអាចបដិសេធចោលនូវសាលក្រម ឬសាលដីកាដើមហើយធ្វើការវិនិច្ឆ័យដោយខ្លួនឯងទាំងលើអង្គច្បាប់ និងអង្គហេតុ ប្រសិនបើតុលាការកំពូលយល់ឃើញថាតុលាការនៃការជំនុំជម្រះដើម មានកំហុសក្នុងការអនុវត្តរដ្ឋធម្មនុញ្ញ ច្បាប់ ឬលិខិតបទដ្ឋាននានា ឬការជំនុំជម្រះ ដើមនោះខុសសមត្ថកិច្ច។ នីតិវិធីសម្រាប់ការជំនុំជម្រះនៅតុលាការកំពូល គឺអនុលោមទៅតាមនីតិវិធីនៃសាលាដំបូង និងសាលាឧទ្ធរណ៍ ដោយគ្រាន់តែផ្លាស់ប្តូរសមាសភាពចៅក្រមតែប៉ុណ្ណោះ។

### ២.២.៣.៣.គុណសម្បត្តិ និងគុណវិបត្តិនៃការដោះស្រាយវិវាទតាមប្រព័ន្ធតុលាការ

- **គុណសម្បត្តិ**
  - ❖ ប្រព័ន្ធនៃការដោះស្រាយវិវាទប្រកបដោយគុណភាពយុត្តិធម៌ និងមានភាពស្មើគ្នានៅចំពោះមុខតុលាការ
  - ❖ ការដោះស្រាយវិវាទបានគ្រប់ករណីវិវាទមិនថាករណីវិវាទនោះតូចឬធំឡើយ
  - ❖ ការចំណាយពេលវេលាក្នុងការដោះស្រាយវិវាទតាមប្រព័ន្ធតុលាការ ចំពោះនីតិវិធីក្នុងការដោះស្រាយត្រូវការប្រើប្រាស់ពេលវេលារាងយូរបន្តិចមែន តែសេចក្តីសម្រេចនីមួយៗដែលចេញមក

[51] មាត្រា២៨៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦

មានលក្ខណៈជាត្រឹមត្រូវតាមផ្លូវច្បាប់ច្បាស់លាស់ និងមានភាពងាយស្រួលក្នុងការដែលយើងទុកជាភស្តុតាងការពារខ្លួននៅពេលក្រោយទៀត

❖ ការដោះស្រាយវិវាទតាមប្រព័ន្ធតុលាការមានអានុភាពចាប់បង្ខំ ឱ្យភាគីជម្លោះទទួលយកសេចក្តីសម្រេចមួយនេះ ដែលកើតចេញពីការដោះស្រាយមួយនេះបានទេ។

- **គុណវិបត្តិ**

❖ ការចំណាយថវិកា និងពេលវេលាច្រើនក្នុងដំណាក់កាលនីតិវិធីដោះស្រាយនីមួយៗ ដែលធ្វើឱ្យភាគីមានការលំបាកក្នុងការបន្តនីតិវិធីតាមផ្លូវមួយនេះ។

❖ ការដោះស្រាយវិវាទតាមប្រព័ន្ធតុលាការមានលក្ខណៈស្មុគស្មាញ ព្រោះនីតិវិធីទាមទារច្រើន ការដោះស្រាយមានលក្ខណៈចាប់បង្ខំឱ្យភាគីជម្លោះ ត្រូវតែទទួលយកសេចក្តីសម្រេចមួយនេះជាដាច់ខាត ដែលហេតុធ្វើឱ្យភាគីមានការលំបាកក្នុងការទទួលយកនូវអ្វីដែលខ្លួនមិនបានធ្វើ។

# សេចក្ដីសន្និដ្ឋាន

កំណើននៃការកើនឡើងរបស់មនុស្សឥតឈប់ឈរ ជាមួយនឹងភាពនៃការរីកចម្រើននៃការអភិវឌ្ឍដល់ឥតឈប់ឈរក្នុងប្រទេសនីមួយៗនោះ ប៉ុន្តែទន្ទឹងនឹងភាពរីកចម្រើនទាំងអស់នោះ នៅពីក្រោយតែងតែមាននូវបញ្ហាដែលប្រទេសជាច្រើននៅក្នុងពិភពលោក បូករួមទាំងប្រទេសកម្ពុជាផងដែរបានជួបប្រទះ។ ចំពោះបញ្ហាទាក់ទងទៅនឹង ការដោះស្រាយវិវាទដីធ្លី គឺនៅតែមានភាពស្មុគស្មាញ និងនៅតែបង្កជាការព្រួយបារម្ភយ៉ាងខ្លាំងដល់រដ្ឋាភិបាលក្នុងការដោះស្រាយ ដោយហេតុថាប្រទេសកម្ពុជាបានឆ្លងកាត់នូវបញ្ហាសមង្គ្រាមស៊ីវិលជាច្រើនលើកច្រើនសារ ធ្វើឱ្យប្រជាពលរដ្ឋមានការបំលាស់ទីលំនៅ និងមួយចំនួនទៀតបានស្លាប់ ហើយពិការថែមទៀតផង។ ដោយសារតែប្រជាពលរដ្ឋបានឆ្លងកាត់នូវរបបមួយដ៏ឃោឃៅ គឺជារបបខ្មែរក្រហមដែលនៅក្នុងសម័យការនោះបានលុបបំបាត់នូវរាល់កម្មសិទ្ធិឯកជនទាំងឡាយរួមទាំងកម្មសិទ្ធិទៅលើដីធ្លីផងដែរនោះ។ បញ្ហានាសម័យកាលនោះបានបង្កឱ្យមានភាពលំបាកជាខ្លាំងទៅដល់រាជរដ្ឋាភិបាល នាសម័យកាលក្រោយៗមកទៀត ក្នុងការទទួលស្គាល់ការកាន់កាប់ដីធ្លីជាច្រើន ដូចជា កត្តាសង្គម ជាពិសេសកត្តាប្រជាពលរដ្ឋខ្លួនឯងផ្ទាល់។ ដែលបណ្ដាលមកពីភាពលោភលន់មិនចេះឈប់ឈរ ចង់បានរបស់ទ្រព្យសម្បត្តិដែលជារបស់អ្នកដទៃមកធ្វើជាកម្មសិទ្ធិរបស់ខ្លួនដោយមិនខ្វល់ថា នៅក្រោយនៃការចង់បានរបស់យើងធ្វើឱ្យអ្នកណាខ្លះត្រូវលំបាក និងទទួលរងនូវភាពអយុត្តិធម៌នោះឡើយ។ ជាងនោះទៅទៀត ការចង់បានធ្វើឱ្យការរស់នៅរបស់ប្រជាពលរដ្ឋរស់នៅប្រកបដោយភាពច្រណែនឈ្នានីសគ្នាមិនចេះឈប់ទេ បុគ្គលខ្លះព្រោះតែភាពចង់បានរបស់ខ្លួនហួសពេកបានទៅបង្កជាភាពចលា*ចល*មួយអ្នកដទៃឬអ្នកជិតខាង រហូតដល់ធ្វើឱ្យកើតមានជាជម្លោះដល់ការប្រើប្រាស់អំពើហិង្សា និងការប្ដឹងផ្ដល់គ្នាថែមទៀតផង។ ការកើនឡើងនៃជម្លោះពាក់ព័ន្ធទៅនឹងវិវាទដីធ្លីនូវតែជាបញ្ហាដែលត្រូវតែយកចិត្តទុកដាក់ឱ្យបានខ្ពស់ក្នុងការរកដំណោះស្រាយជូនប្រជាពលរដ្ឋ ដើម្បីលុបបំបាត់ភាពគ្មានជម្រកដែលជាបញ្ហាមួយក្នុងចំណោមបញ្ហាជាច្រើនទាំងនោះដែរ។

ដោយមានការយល់ឃើញពីភាពចាំបាច់នៃការដោះស្រាយវិវាទដីធ្លីនៅកម្ពុជា នៅតែមានភាពស្មុគស្មាញនៅឡើយ ទើបក្រុមយើងខ្ញុំបានលើកយកនូវប្រធានបទនេះមកធ្វើការបកស្រាយ ដើម្បីជាទន់ក្នុងការធ្វើការសិក្សាស្រាវជ្រាវបន្ថែម។

ស្របតាមស្ថានភាពប្រទេសកម្ពុជានាពេលបច្ចុប្បន្នមូលហេតុដែលជាបញ្ហាបង្កឱ្យមានវិវាទនោះ គឺមានច្រើនតែបញ្ហាដែលធំជាងគេនោះ គឺបណ្ដាលមកពីភាពក្រីក្រ។ ដោយសារតែភាពគ្មានជម្រក គ្មានមុខរបរចិញ្ចឹមជីវិត ទើបធ្វើឱ្យពួកគាត់ធ្វើការបំពានលើច្បាប់ ដើម្បីជាប្រយោជន៍ផ្ទាល់ខ្លួននោះ។ ម៉្យាងវិញទៀតដោយសារតែតម្លៃដីមានតម្លៃខ្ពស់នេះដែរ ដែលធ្វើឱ្យប្រជាពលរដ្ឋមួយចំនួនបានលក់ដីនោះ រួចទៅធ្វើការកាន់កាប់ដីរបស់រដ្ឋ

ដោយខុសច្បាប់ ដល់ពេលរដ្ឋត្រូវដីទាំងនោះមកធ្វើជាប្រយោជន៍សាធារណៈវិញ ពេលនោះប្រជាពលរដ្ឋដែលរស់នៅលើដីនោះមិនព្រមប្រគល់ដីមកឱ្យរដ្ឋវិញនោះ បញ្ហាទាំងនោះហើយដែលធ្វើឱ្យវិវាទកើតមានឡើង។ លើសពីនេះទៅទៀត ក៏ជាឱកាសរបស់ជនខិលខូចមួយចំនួនឆ្លៀតឱកាសនេះធ្វើការរំលោភបំពានទៅលើប្រជាពលរដ្ឋដែលពួកគាត់ខ្វះនូវការយល់ដឹង ដែលជាហេតុធ្វើឱ្យគាត់បាត់បង់សិទ្ធិកាន់កាប់ដីធ្លីរបស់គាត់ទៅឱ្យជនទាំងនោះ។

សរុបសេចក្តីមក ការដោះស្រាយវិវាទដីធ្លីនៅកម្ពុជា ក៏នូវតែជាបញ្ហា ទោះបីជាកម្ពុជាបានបង្កើតនូវក្របខណ្ឌច្បាប់សម្រាប់ធ្វើការដោះស្រាយវិវាទនោះក៏ដោយ ក៏បញ្ហានោះនៅតែជាកង្វល់មួយសំខាន់ដដែល។ ប៉ុន្តែបញ្ហាប្រឈមទាំងនោះអាចនឹងត្រូវបានដោះស្រាយតាមរយៈការពង្រឹងសមត្ថភាព និងឯករាជ្យភាពរបស់តុលាការ និងព្រមពង្រឹងនូវយន្តការដោះស្រាយវិវាទមួយប្រកបដោយយុត្តិធម៌ តម្លាភាព លើកកម្ពស់ការយល់ដឹង ជាពិសេសផ្សព្វផ្សាយជាសាធារណៈដល់ប្រជាពលរដ្ឋ អំពីការទទួលបានយន្តការដោះស្រាយវិវាទដីធ្លី ដែលរាជរដ្ឋាភិបាលបានដាក់ឱ្យប្រើប្រាស់នោះ។ វិវាទដីធ្លីមួយនេះអាចត្រូវបានកាត់បន្ថយទៅបាន លុះត្រាតែមានការចូលរួមសំណាក់ពីប្រជាពលរដ្ឋ និងរដ្ឋាភិបាល ចំពោះវិវាទដែលបានកើតឡើងនោះ។ ជួយគ្នាក្នុងការរកដំណោះស្រាយមួយដែលអាចជួយកាត់បន្ថយនូវការប្តឹងផ្តល់គ្នា និងវិវាទដែលអាចឈានទៅដល់ការប្រើប្រាស់អំពើហិង្សា ដែលអាចធ្វើឱ្យមានការកាប់សម្លាប់គ្នានិងគ្នាកើតឡើង។

# អនុសាសន៍

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទ ការដោះស្រាយវិវាទដីធ្លីនៅកម្ពុជា រួចមក ឃើញថា បញ្ហាជាច្រើនពាក់ព័ន្ធនឹងប្រភពដើមនៃវិវាទ បញ្ហាប្រឈម រហូតដល់ការឈានទៅរកដំណោះស្រាយល្អៗ ក្នុងការឆ្ពោះទៅរកការលុបបំបាត់វិវាទដីធ្លីទាំងអស់នៅកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជា ដែលមានសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាប្រមុខដឹកនាំដ៏ឆ្នើម ដឹកនាំប្រទេសកម្ពុជាទាំងមូលឆ្ពោះទៅរកសន្តិភាព និងការអភិវឌ្ឍ បានខិតខំយកចិត្តទុកដាក់រៀបចំឱ្យមានគណៈកម្មការគ្រប់ជាន់ថ្នាក់ក្នុងការដោះស្រាយវិវាទជូនប្រជាពលរដ្ឋ រៀបចំប្រព័ន្ធគតិយុត្តនានា ដំណើរការចុះបញ្ជីដីធ្លីតាមប្រព័ន្ធបច្ចេកវិទ្យាទំនើប តាមសម័យកាលនៃបដិវត្តន៍ ឧស្សាហកម្មឌីជីថល។ ការដោះស្រាយវិវាទដីធ្លីនៅកម្ពុជា គឺជាបញ្ហាមួយដែលគួរឱ្យយកចិត្តទុកដាក់ ហើយត្រូវការចូលរួមពីប្រជាពលរដ្ឋម្នាក់ៗទៅ រួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជាយើង ក្នុងការកាត់បន្ថយឱ្យបាននូវវិវាទដីធ្លីទាំងអស់នោះ។

តាមរយៈនេះ ទោះបីជាមានការចាត់នូវវិធានការក្នុងការទប់ស្កាត់ក៏ដោយ ក៏មិនទាន់បានលេច ចេញជាលទ្ធផលល្អប្រសើរដូចដែលបានរំពឹងទុកនោះទេ ពីព្រោះសកម្មភាពនៃការអនុវត្តន៍កន្លងមកនេះ បានជួបប្រទះនូវការលំបាក និងបញ្ហាប្រឈមមួយចំនួនដូចជាកង្វះបច្ចេកទេស ធនធានមនុស្ស ក៏ដូចជាហិរញ្ញវត្ថុជាដើម។

ដូចនេះដើម្បីចូលរួមចំណែករកដំណោះស្រាយ ទប់ស្កាត់ និងកាត់បន្ថយនូវវិវាទដីធ្លីនៅកម្ពុជា ឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធិភាព ក្នុងនាមយើងខ្ញុំជានិស្សិតថ្នាក់បរិញ្ញាបត្រមួយរូប នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាញនីតិសាស្ត្រ ជំនាន់ទី២២ សូមចូលរួមជាអនុសាសន៍មួយចំនួនជាអាទិ៍៖

- ពន្លឿនការចុះបញ្ជីដីធ្លីលក្ខណៈជាប្រព័ន្ធ ដោយរួមទាំងដីសម្បទានសង្គមកិច្ច ដីរបស់ក្រុមហ៊ុន ដែលបានវិនិយោគ និងដីសហគមន៍ឱ្យមានតម្លាភាព និងប្រសិទ្ធិភាព ប្រកបដោយគណនីភាពសង្គម។
- ពន្លឿនការកំណត់តំបន់ និងការផ្តល់សម្បទានដីសង្គមកិច្ចជូនដល់ប្រជាពលរដ្ឋក្រីក្រគ្មានដី និងខ្វះខាតដីដើម្បីកាត់បន្ថយទំនាស់។
- ផ្តល់អាណត្តិឱ្យបានច្រើនជាងនេះដល់អាជ្ញាធរមូលដ្ឋានក្នុងការដោះស្រាយវិវាទដីធ្លី និងផ្តល់វគ្គបណ្តុះបណ្តាល។
- ធានាការផ្តល់ជូននូវសំណងសមរម្យគ្រប់គ្រាន់ជូនដល់សហគមន៍ដែលរងផលប៉ះពាល់ និងសហគមន៍ដែលរងផលប៉ះពាល់យល់ព្រមទទួល។

- រៀបចំឱ្យមានកិច្ចពិគ្រោះយោបល់ ដែលមានន័យ មានការចូលរួមជាសាធារណៈជាមួយនឹងសហគមន៍ដែលរងផលប៉ះពាល់ នៅពេលដែលគម្រោងអភិវឌ្ឍត្រូវបានរៀបចំ។
- រៀបចំក្រុមការងារដោះស្រាយវិវាទចល័ត ដើម្បីសម្រួលដល់ការងារដោះស្រាយវិវាទឱ្យមានប្រសិទ្ធភាព និងកាត់បន្ថយបាននូវវិវាទដីធ្លី។
- ធានានូវប្រព័ន្ធតុលាការដែលឯករាជ្យមិនស្ថិតក្រោមឥទ្ធិពលនយោបាយ និងអ្នកមានអំណាចធំៗមួយចំនួន។
- ចូលរួមធ្វើការទប់ស្កាត់ បង្ការការពារធ្វើយ៉ាងណាឱ្យទំនាស់ដីធ្លីស្ថិតក្នុងកម្រិតអប្បបរមា ហើយឈានដល់ការលុបបំបាត់ចោលទាំងស្រុងនូវវិវាទដីធ្លីនៅក្នុងប្រទេសកម្ពុជា។

# ឯកសារយោង

## ច្បាប់

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ ។
- ច្បាប់ភូមិបាល ឆ្នាំ២០០១

## លិខិតបទដ្ឋានគតិយុត្ត

- ក្រមរដ្ឋប្បវេណីនៃព្រះរាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែវិច្ឆការ ឆ្នាំ២០០៧។
- ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦។
- ព្រះរាជក្រឹត្យលេខ ០៤/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។
- ព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/០៩៧ ចុះថ្ងៃទី២៦ ខែកុម្ភះ ឆ្នាំ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ។
- អនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី។
- អនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែមិនា ឆ្នាំ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច។
- អនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ។
- អនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលនៃអនុក្រឹត្យ ស្តីពីសម្បទានដីសេដ្ឋកិច្ច។
- ប្រកាសលេខ ១១២ ដនស/ប្រក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០២ ស្តីពីគោលការណ៍ណែនាំ និងនីតិវិធីរបស់គណៈកម្មការសុរិយោដី។
- ប្រកាសអន្តរក្រសួងលេខ ០២ ប្រករ ០៣ ចុះថ្ងៃទី២៦ ខែវិច្ឆកា ឆ្នាំ២០០៣ ស្តីពីការកំណត់ភារកិច្ចរបស់តុលាការ និងគណៈកម្មការសុរិយោដីពាក់ព័ន្ធ និងរឿងវិវាទដីធ្លី។
- ព្រះរាជាក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីក្រមរដ្ឋប្បវេណី។
- អនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីនីតិវិធីនៃកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី។

## គេហទំព័រ

- https://sopheaksrey.files.wordpress.com/2012/04/thesis-tri-hang-2012.pdf